# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី១ : ព្រះវិញ្ញាណបរិសុទ្ធ

## សេចក្តីផ្តើម

យើងនឹងសិក្សាអំពីអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដែលជាមាគ៌ាមួយនៃជីវិត ។ អំណោយទាននៃព្រះវិញ្ញាណ បរិសុទ្ធមិនមែនគ្រាន់តែជាអ្វីដែលកើតឡើងបន្ទាប់ពីការច្រៀងចំរៀងថ្វាយបង្គំ និង មុនការអធិប្បាយនៅព្រឹកថ្ងៃអាទិត្យនោះទេ ។ អំណោយទានទាំងនោះគឺជាមាគ៌ានៃការរស់នៅ ។ នៅពេលយើងកើតជាថ្មី យើងបានរស់ឡើងវិញខាងវិញ្ញាណ ។ យើងមានព្រលឹង និង វិញ្ញាណ ។ ដូច្នេះ យើងគឺមនុស្សខាងវិញ្ញាណ ។ ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង យើងរស់នៅក្នុងព្រះវិញ្ញាណដែលអស្ចារ្យរបស់ព្រះជាម្ចាស់ ។

## គំរោងមេរៀន

### ១. ការស្គាល់ព្រះវិញ្ញាណបរិសុទ្ធ

ព្រះវិញ្ញាណបរិសុទ្ធគឺជាមនុស្សដ៏ពិតប្រាកដ ។ យើងត្រូវស្គាល់ព្រះអង្គដោយផ្ទាល់ និង ដោយភាពស្និតស្នាល ។ លោកប៉ុលបានសរសេរអំពីសេចក្តីរួបរួមគ្នាជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ (២កូរិនថូស ១៣:១៤) ។

ក. មាគ៌ាថ្មីនៃការរស់នៅ

១. អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធផ្តល់មាគ៌ាថ្មីនៃការរស់នៅដល់គ្រិស្តបរិស័ទដែលពេញដោយព្រះវិញ្ញាណ ។ យើងត្រូវតែឈានជើងចេញពីតំបន់នៃការរស់នៅតាមបែបធម្មតា ហើយដើរលើ "ទឹកខាងវិញ្ញាណ" ដូចដែលលោកពេត្រុសបានឈានជើងចេញពីទូក ហើយដើរលើទឹកសំដៅទៅព្រះយេស៊ូដែរ ។ យើងត្រូវតែរស់នៅខាងវិញ្ញាណ ហើយប្រើអំណោយទានទាំងប្រាំបួនរបស់ព្រះអង្គនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។

២. "នោះព្រះវិញ្ញាណនៃព្រះយេហូវ៉ានឹងមកសណ្ឋិតលើអ្នក បណ្តាលជាខ្លាំង អ្នកនឹងទាយជាមួយនឹងគេដែរ ហើយអ្នកនឹងបានប្រែទៅជាមនុស្សថ្មីវិញ" (១សាំយូអែល ១០:៦) ។

៣. "អំណាចនៃការមានព្រះជន្មឡើងវិញគឺសម្រាប់អស់អ្នកទាំងឡាយណាដែលជឿ" (អេភេសូរ ១:១៩-២០) ។

ខ. ព្រះយេស៊ូត្រូវបានបំពេញព័ន្ធកិច្ចដោយព្រះវិញ្ញាណបរិសុទ្ធ

១. យោងតាម ភីលីព ២:៥,៨ នៅពេលព្រះយេស៊ូបានយាងមកលើផែនដីនេះ ព្រះអង្គបានបន្ទាបអង្គកាយរបស់ព្រះអង្គដោយយាងមកយកជាតិជាមនុស្ស ។ ព្រះអង្គបានលះបង់សិទ្ធិ និង អភ័យឯកសិទ្ធិជាព្រះជាម្ចាស់របស់ព្រះអង្គជាបណ្តោះអាសន្ន ហើយបានរស់នៅលើផែនដីនេះក្នុងនិស្ស័យជាមនុស្ស ។ គ្មានការអស្ចារ្យណាមួយត្រូវបានគត់ត្រានៅក្នុងកំឡុងពេលសាមសិបឆ្នាំដំបូងនៃជីវិតរបស់ព្រះអង្គទេ ។ នៅពេលព្រះអង្គទទួលពិធីបុណ្យជ្រមុជទឹកពីលោកយ៉ូហាន យោងតាមម៉ាកុស ១:១០,១១ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើព្រះអង្គ ។ ភ្លាមនោះ ការអស្ចារ្យបានចាប់ផ្តើមកើតឡើងនៅក្នុងព័ន្ធកិច្ចរបស់ព្រះអង្គ ។

២. "កាលកំពុងតែយាងឡើងពីទឹកមក ស្រាប់តែឃើញមេឃរបើក និង ព្រះវិញ្ញាណយាងចុះមកសណ្ឋិតលើទ្រង់មានរូបដូចជាព្រាប" (ម៉ាកុស ១:១០) ។

៣. ព្រះគ្រិស្ត ដែលជាគំរូរបស់យើង និង ដែលត្រូវបានចាក់ប្រេងតាំងដោយព្រះវិញ្ញាណបរិសុទ្ធ បានចាប់ផ្តើមរប្រើអំណោយទានដ៏អស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

៤. "ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំអោយផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំអោយមកដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ និង សេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយអោយដោះមនុស្សដែលត្រូវគេជិះជាន់អោយរួច " (លូកា ៤:១៨) ។

គ. អំណាចដូចគ្នានេះគឺសម្រាប់យើងក្នុងពេលបច្ចុប្បន្ន

១. "សូមទ្រង់ប្រទានអោយបងប្អូនយល់ទៀតថា ឫទ្ធានុភាពដ៏អស្ចារ្យបំផុតដែលព្រះអង្គសម្តែងមកជាប្រយោជន៍ដល់យើងជាអ្នកជឿមានទំហំធំធេងយ៉ាងណាស្របតាមមហិទ្ធិឫទ្ធិនៃព្រះចេស្តាដ៏ខ្លាំងក្លាដែលទ្រង់បានសម្តែងក្នុងអង្គព្រះគ្រិស្ត ។ ព្រះអង្គបានសម្តែងមហឫទ្ធិនេះដោយប្រោសព្រះគ្រិស្តអោយមានព្រះជន្មរស់ឡើងវិញ និង អោយគង់នៅខាងស្តាំព្រះអង្គនៅស្ថានសួគ៌" (អេភេសូរ ១:១៩-២០) ។

២. "ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលបានប្រោសអោយព្រះយេស៊ូអោយមានព្រះជន្មរស់ឡើងវិញសណ្ឋិតនៅក្នុងបងប្អូនមែននោះ ព្រះជាម្ចាស់ដែលបានប្រោសព្រះគ្រិស្តអោយមានព្រះជន្មរស់ឡើងវិញ ទ្រង់ក៏នឹងប្រទានអោយរូបកាយរបស់បងប្អូន ដែលរមែងតែងតែស្លាប់នេះមានជីវិតតាមរយៈព្រះវិញ្ញាណដែលសណ្ឋិតនៅក្នុងបងប្អូននោះដែរ (រ៉ូម ៨:១១) ។ ព្រះយេស៊ូមានបន្ទូលនៅក្នុងលូកា ២៤:៤៩ ថា "ដរាបដល់ព្រះចេស្តាពីស្ថានលើបានមកគ្របដណ្តប់លើអ្នករាល់គ្នា" ។

៣. ព្យាការីយ៉ូអែលបានព្យាករណ៍ថា "ក្រោយមកទៀត យើងនឹងចាក់បង្ហូរព្រះវិញ្ញាណរបស់យើងមកលើមនុស្សលោកទាំងអស់ ។ កូនប្រុសកូនស្រីរបស់អ្នករាល់គ្នានឹងអធិប្បាយ ពួកចាស់ទុំរបស់អ្នករាល់គ្នានឹងយល់សុបិននិមិត្ត ហើយពួកយុវជននឹងនិមិត្តឃើញការអស្ចារ្យ ។ ក្រោយមក សូម្បីតែអ្នកបំរើប្រុសស្រី ក៏យើងនឹងចាក់បង្ហូរព្រះវិញ្ញាណរបស់ពួកយើងទៅលើពួកគេដែរ" (យ៉ូអែល ២:២៨-២៩) ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា "ដរាបដល់ព្រះចេស្តាពីស្ថានលើបានមកគ្របដណ្តប់លើអ្នករាល់គ្នា" (លូកា ២៤:៤៩) ។

## ២. ពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ

លោកយ៉ូហានបានមានប្រសាសន៍ថា "ខ្ញុំធ្វើពិធីជ្រមុជអោយអ្នករាល់គ្នាក្នុងទឹក ប៉ុន្តែ លោកដែលមានកម្លាំងខ្លាំងជាងខ្ញុំជិតមកដល់ហើយ ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង លោកនឹងធ្វើពិធីជ្រមុជអោយអ្នករាល់គ្នាក្នុងព្រះវិញ្ញាណបរិសុទ្ធ និង ដោយភ្លើងវិញ" (លូកា ៣:១៦) ។

ព្រះយេស៊ូបានលាន់មាត់ថា "នៅប៉ុន្មានថ្ងៃទៀត អ្នករាល់គ្នានឹងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធវិញ" (កិច្ចការ ១:៥) ។

<u>ការធ្វើជាស្មរបន្ទាល់</u>របស់ព្រះអង្គពិតជាមានអំណាចខ្លាំងណាស់ ។

"ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណបរិសុទ្ធ មកសណ្ឋិតលើអ្នករាល់គ្នា ។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និង រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី" (កិច្ចការ ១:៨) ។

ក. ការនោះបានចាប់ផ្តើមឡើងនៅថ្ងៃបុណ្យទីហាសិប

១. "នៅថ្ងៃបុណ្យទីហាសិប ពួកសាវ័កបានរួមប្រជុំទាំងអស់គ្នា នៅកន្លែងតែមួយ ។ រំពេចនោះស្រាប់តែមានឮសូរសន្ធឹកពីលើមេឃ ដូចខ្យល់បក់បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ ។ ពួកសាវ័កបានឃើញហាក់ដូចជាមានអណ្តាតភ្លើងបែកចេញពីគ្នាចុះមកសណ្ឋិតលើពួកគេ ម្នាក់ៗ

។ អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយចាប់ផ្តើមនិយាយភាសាផ្សេងៗពីគ្នាតាមព្រះវិញ្ញាណប្រោសប្រទានអោយ" (កិច្ចការ ២:១-៤) ។

២. ការអស្ចារ្យបានកើតឡើងតាមរយៈភាសាដទៃដែលពួកគេនិយាយ ។

៣. លោកពេត្រុសបានប្រកាសប្រាប់អ្នកដទៃទៀតថា "បងប្អូននឹងទទួលព្រះវិញ្ញាណបរិសុទ្ធដែលជាអំណោយទានរបស់ព្រះជាម្ចាស់" (កិច្ចការ ២:៣៨) ។

ខ. អ្នកស្រុកសាម៉ារីបានទទួលព្រះអំណោយទាននេះ

១. "កាលពួកសាវ័កនៅក្រុងយេរូសាឡិមបានឮថា ស្រុកសាម៉ារីបានទទួលព្រះបន្ទូលហើយ នោះគេចាត់ពេត្រុស និង យ៉ូហានអោយទៅឯពួកអ្នកនោះ ។ លុះអ្នកទាំងពីបានចុះទៅដល់ហើយ នោះក៏អធិស្ឋានអោយគេ ប្រយោជន៍អោយគេបានទទួលព្រះវិញ្ញាណបរិសុទ្ធ ដ្បិតព្រះវិញ្ញាណមិនទាន់ចុះមកសណ្ឋិតលើពួកគេណាមួយនៅឡើយ ។ គេគ្រាន់តែបានទទួលបុណ្យជ្រមុជទឹកដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូប៉ុណ្ណោះ ។ ដូច្នេះ អ្នកទាំងពីរក៏ដាក់ដៃលើគេ ហើយគេបានទទួលព្រះវិញ្ញាណបរិសុទ្ធដែរ" (កិច្ចការ ៨:១៤-១៧) ។

២. នេះគឺជាអំណោយទាន ។ យើងមិនចាំបាច់ស្វះស្វែងដើម្បីទទួលឡើយ ។

គ. សាសន៍ដទៃបានទទួលអំណោយទាននេះ

១. "កាលពេត្រុសកំពុងតែអធិប្បាយនៅឡើយ នោះព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមកសណ្ឋិតលើអស់អ្នកដែលកំពុងតែស្តាប់ព្រះបន្ទូល ឯពួកអ្នកដែលជឿក្នុងចំណោមពួកកាត់ស្បែកទាំងប៉ុន្មានដែលមកជាមួយនឹងពេត្រុស គេក៏មានសេចក្តីអស្ចារ្យជាខ្លាំងពីដំណើរដែលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធបានចាក់មកលើពួកសាសន៍ដទៃដូច្នេះដែរ ដ្បិតគេឮអ្នកទាំងនោះនិយាយភាសាដទៃ ហើយសរសើរតម្កើងដល់ព្រះ" (កិច្ចការ ១០:៤៤- ៤៦) ។

២. អ្វីដែលយើងត្រូវធ្វើក្នុងពេលបច្ចុប្បន្ននេះគឺ ទទួលអំណោយទាននោះ ។

ឃ. អ្នកក្រុងអេភេសូរបានទទួលអំណោយទាននោះ

"កាលបងប្អូនចាប់ផ្តើមជឿនោះ តើបងប្អូនទទួលព្រះវិញ្ញាណបរិសុទ្ធហើយឬនៅ? គេតបមកលោកវិញថា "យើងខ្ញុំមិនដែលទាំងឮថាមានព្រះវិញ្ញាណបរិសុទ្ធផង!" ។ លោកសួរគេទៀតថា "ដូច្នេះ តើបងប្អូនបានទទួលពិធីជ្រមុជទឹកណា?" ។ គេតបថា "ពិធីជ្រមុជទឹករបស់លោកយ៉ូហាន" ។ លោកប៉ុលក៏មានប្រសាសន៍ថា "លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកអោយអ្នករាល់គ្នាដែលកែប្រែចិត្តគំនិត ទាំងមានប្រសាសន៍ប្រាប់ប្រជាជនអោយជឿលើព្រះអង្គដែលយាងមកក្រោយលោក គឺព្រះយេស៊ូនេះហើយ" ។ ក្រោយបានឮលោកប៉ុលមានប្រសាសន៍ដូច្នោះ ពួកសាវ័កក៏ទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ ។ លោកប៉ុលបានដាក់ដៃលើគេ ព្រះវិញ្ញាណបរិសុទ្ធក៏យាងមកសណ្ឋិតលើគេ ហើយគេនាំគ្នានិយាយភាសាចំឡែកអស្ចារ្យ និង អធិប្បាយផង" (កិច្ចការ ១៩:២-៦) ។

## ៣. ការទូលសូមអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

"ក្នុងចំណោមអ្នករាល់គ្នា បើកូនសុំត្រី មិនដែលមានឪពុកណាយកពស់អសិរពិសអោយវាទេ បើកូនសុំពងមាន់ក៏ពុំដែលមានឪពុកណាយកខ្យាដំរីអោយវាដែរ ។ សូម្បីតែអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ ក៏ចេះអោយរបស់ល្អៗទៅកូន ចុះចំណង់ឯព្រះបិតាដែលគង់នៅឯស្ថានសួគ៌ តើព្រះអង្គនឹងប្រទានព្រះវិញ្ញាណបរិសុទ្ធអោយអស់អ្នកដែលទូលសូមពីព្រះអង្គយ៉ាងណាទៅទៀត " (លូកា ១១:១១-១៣) ។

ព្រះបិតាដែលគង់នៅស្ថានសួគ៌របស់យើងត្រៀមជាស្រេចដើម្បីប្រទានអំណោយទានមកអោយយើង ។

ក. ការនិយាយភាសាដទៃ

១. ភស្តុតាងនៃការនិយាយភាសាដែលគេមិនស្គាល់តែងតែកើតឡើងជាមួយនឹងការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

២. ព្រះយេស៊ូបានមានព្រះបន្ទូលថា នេះគឺជាទីសំគាល់ដែលនឹងជាប់ជាមួយអស់អ្នកដែលជឿ . "......គេនិយាយភាសាថ្មី" ( ម៉ាកុស ១៦:១៧) ។

៣. លោកប៉ុលបានសរសេរថា លោកបាននិយាយភាសារបស់ទេវតា ( ១កូរិនថូស ១៣:១) ។

៤. លោកប៉ុលបានពន្យល់ថា ការនេះកើតឡើងដោយសារព្រះវិញ្ញាណបរិសុទ្ធតាមរយៈវិញ្ញាណរបស់លោក មិនមែនតាមរយៈគំនិតរបស់លោកឡើយ ។

ក. ពួកទេវតាមិនដែលខ្វះពាក្យសំដីក្នុងការសរសើរតម្កើងព្រះជាម្ចាស់ឡើយ ។

ខ. "បើខ្ញុំអធិស្ឋានជាភាសាដទៃ នោះគឺជាវិញ្ញាណខ្ញុំដែលអធិស្ឋាន តែឥតមានប្រយោជន៍ប្រាជ្ញា ខ្ញុំសោះ" ( ១កូរិនថូស ១៤:១៤) ។

៥. "យ៉ាងណាមិញ ព្រះវិញ្ញាណក៏យាងមកជួយយើងដែលទន់ខ្សោយនេះដែរ ដ្បិតយើងពុំដឹងអធិស្ឋានដូចម្ដេច ដើម្បីអោយបានសមនោះឡើយ តែព្រះវិញ្ញាណផ្ទាល់ទ្រង់ទូលអង្វរអោយយើងដោយព្រះសូរសៀង ដែលគ្មាននរណាអាចថ្លែងបាន ។ រីឯព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណទូលអង្វរអោយប្រជាជនបរិសុទ្ធស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ " (រ៉ូម ៨:២៦-២៧) ។

ក. យើងត្រូវទទួលយកព្រះបន្ទូល ហើយអធិស្ឋានដោយព្រះវិញ្ញាណ ។

ខ. "ចូរទទួលការសង្គ្រោះយកមកធ្វើជាមួកដែក និង យកព្រះបន្ទូលរបស់ព្រះជាម្ចាស់មកធ្វើជាដាវរបស់ព្រះវិញ្ញាណ ។ ចូរអធិស្ឋានគ្រប់ពេលវេលាតាមការណែនាំរបស់ព្រះវិញ្ញាណដោយប្រើទាំងពាក្យអធិស្ឋាន ទាំងពាក្យអង្វរគ្រប់យ៉ាង ហើយប្រុងស្មារតីទូលអង្វរព្រះជាម្ចាស់ដោយចិត្តព្យាយាមបំផុតសម្រាប់ប្រជាជនបរិសុទ្ធទាំងអស់..." ( អេភេសូរ ៦:១៧-១៨) ។

ខ. យើងត្រូវចាប់ផ្ដើមនិយាយភាសាដទៃ

១. នៅពេលយើងពេញដោយព្រះវិញ្ញាណបរិសុទ្ធ យើងក៏ត្រូវចាប់ផ្ដើមនិយាយភាសាដទៃ មិនមែនភាសារបស់យើងនោះទេ ។

ក. "អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានអោយ" ( កិច្ចការ ២:៤) ។

ខ. មានពីរភាគីគឺ : ភាគីព្រះជាម្ចាស់ និង ភាគីមនុស្ស ។

២. គ្រប់ភាសាទាំងអស់គឺជាពាក្យពេជន៍ដែលត្រូវបានបង្កើតឡើងដោយសារការផ្សំគ្នារបស់សម្លេងផ្សេងៗគ្នា ។ ប្រសិនបើព្រះវិញ្ញាណជួយយើង និង បណ្ដាលចិត្តយើងដូចថ្ងៃបុណ្យទីហាសិបយើងត្រូវតែចាប់ផ្ដើមនិយាយ ប៉ុន្ដែ មិនមែននិយាយជាភាសាដែលយើងស្គាល់នោះទេ ។ យើងត្រូវតែចាប់ផ្ដើមនិយាយភាសាដទៃអោយឮៗ ដូចពួកអ្នកជឿកាលពីជំនាន់មុនដែរ ។

៣. នៅពេលយើងចាប់ផ្ដើមផ្ដោតការចាប់អារម្មណ៍របស់យើងទៅលើព្រះយេស៊ូ ដោយការទូលសុំ និង ការទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធតាមរយៈសេចក្ដីជំនឿ យើងត្រូវចាប់ផ្ដើមនិយាយជាភាសាដទៃ ដូចពួកអ្នកជឿជំនាន់មុនបានធ្វើនៅថ្ងៃបុណ្យទីហាសិបដែរ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងចាប់ផ្ដើមប្រទានសមត្ថភាពនេះដល់យើង ។ ពេលយើងចាប់ផ្ដើមនិយាយភាសាដទៃ ព្រះជាម្ចាស់នឹងប្រទានសមត្ថភាពក្នុងការនិយាយភាសាដទៃនេះដល់យើង ។ ពេលយើងមានសេចក្ដីជំនឿ ការអស្ចារ្យនឹងកើតឡើងតាមរយៈការនិយាយភាសាចំឡែករបស់យើង ។

ចូរអធិស្ឋានសេចក្ដីអធិស្ឋាននេះ

ព្រះបិតាដែលគង់នៅឯស្ថានសួគ៌អើយ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ព្រះអំណោយទាននៃការសង្គ្រោះរបស់ព្រះអង្គ ! ប៉ុន្តែ ព្រះបិតាអើយ ទូលបង្គំចង់បានអំណោយទានទាំងអស់ដែលព្រះអង្គមានសម្រាប់ទូលបង្គំ ! ទូលបង្គំចង់បានអំណោយទាននៃវិញ្ញាណបរិសុទ្ធ ! ទូលបង្គំត្រូវការអំណាចនេះនៅក្នុងជីវិតរបស់ទូលបង្គំ ! ព្រះយេស៊ូអើយ ទូលបង្គំសូមអោយព្រះអង្គធ្វើពិធីជ្រមុជទឹកអោយទូលបង្គំក្នុងព្រះវិញ្ញាណបរិសុទ្ធ ! ទូលបង្គំទទួលអំណោយទាននេះតាមរយៈសេចក្ដីជំនឿ ! ឥឡូវនេះ ព្រះបិតាអើយ ទូលបង្គំសូមលើកដៃឡើងសរសើរតម្កើងព្រះអង្គ ។ ទូលបង្គំសូមបើកមាត់អោយធំ និង ចាប់ផ្ដើមសរសើរតម្កើងព្រះអង្គ ប៉ុន្តែ មិនមែនតាមរយៈភាសាដែលទូលបង្គំស្គាល់នោះទេ ។ ទូលបង្គំនឹងចាប់ផ្ដើមសរសើរតម្កើងដូចជាពួកអ្នកជឿជំនាន់ដំបូងបានធ្វើនៅថ្ងៃបុណ្យទីហាសិបដែរ ។ ព្រះបិតាអើយ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលព្រះវិញ្ញាណបរិសុទ្ធនឹងផ្ដល់សមត្ថភាពដល់ទូលបង្គំក្នុងការធ្វើដូច្នេះ !

ពេលដៃរបស់លោកអ្នកលើកឡើងដើម្បីសរសើរតម្កើងព្រះជាម្ចាស់ សូមចាប់ផ្ដើមសរសើរតម្កើងព្រះអង្គចុះ ។ សូមចាប់ផ្ដើមសរសើរតម្កើងព្រះអង្គដោយលឺៗ ។ ទន្លេនៃជីវិតចាប់ផ្ដើមហូរចេញពីលោកអ្នក នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធចាប់ផ្ដើមបណ្ដាលចិត្តលោកអ្នក ។

គោលបំណរបស់ភាសានៃស្ថានសួគ៌គឺ :

ការសរសើរតម្កើង
"ដូច្នេះ តើខ្ញុំត្រូវធ្វើដូចម្ដេច ? ខ្ញុំនឹងអធិស្ឋានដោយប្រើវិញ្ញាណរបស់ខ្ញុំ ហើយខ្ញុំក៏នឹងអធិស្ឋានដោយប្រើប្រាជ្ញារបស់ខ្ញុំផងដែរ ។ ខ្ញុំនឹងច្រៀងដោយប្រើវិញ្ញាណរបស់ខ្ញុំ ហើយខ្ញុំនឹងច្រៀងដោយប្រើប្រាជ្ញារបស់ខ្ញុំផងដែរ" (១កូរិនថូស ១៤:១៥) ។

ការអធិស្ឋាន
"រីឯបងប្អូនវិញ បងប្អូនជាទីស្រឡាញ់អើយ ចូរកសាងគ្នាទៅវិញទៅមក ដើម្បីជំនឿបរិសុទ្ធបំផុតរបស់បងប្អូន ចូរអធិស្ឋានតាមព្រះវិញ្ញាណបរិសុទ្ធ" (យូដាស ១:២១) ។

- ជីវិតរបស់លោកអ្នកនឹងមិននៅដដែលនោះឡើយ ។ នៅពេលលោកអ្នកសរសើរតម្កើងព្រះជាម្ចាស់ និង អធិស្ឋានដោយព្រះវិញ្ញាណបរិសុទ្ធ ទន្លេនៃជីវិតដែលអស្ចារ្យនឹងចាប់ផ្ដើមហូរចេញពីលោកអ្នក ។

## ការពិភាក្សាជាក្រុម

១. ចូរចំណាយពេលអធិស្ឋានសម្រាប់អស់អ្នកដែលមិនទាន់បានទទួលពិធីជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងក្រុមរបស់លោកអ្នក ។

២. ចំពោះអស់អ្នកដែលបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធរួចហើយ សូមចំណាយពេលអធិស្ឋាន និង សរសើរតម្កើងព្រះជាម្ចាស់ជាភាសានៃស្ថានសួគ៌របស់ពួកគេ ។

៣. ឥឡូវនេះ មេដឹកនាំការបង្រៀនគួរតែចំណាយពេលដើម្បីផ្តល់យោបល់ដល់អ្នកដែលទើបតែទទួលការជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ ។ ចូរផ្តល់យោបល់ដល់ពួកគេស្តីអំពីរបៀបបន្តប្រើប្រាស់អំណោយទាននេះ ។

## ការសិក្សាខ្លួនឯង

ចូរសិក្សាខគម្ពីរទាំងនេះ ហើយសរសេរជាពាក្យផ្ទាល់ខ្លួនថាតើអ្វីជាទីសំគាល់ដែលគួរតែនៅជាប់ជាមួយនឹងអ្នកដែលទើបនឹងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ ។

កិច្ចការ ២:១-៤

កិច្ចការ ៨:៤-៤០

កិច្ចការ ១០:៤៤-៤៦

កិច្ចការ ១៩:២-៦

ម៉ាកុស ១៦:១៧

១ កូរិនថូស ១៤:១៤

# ការរស់នៅដោយអស្ចារ្យ
## មេរៀនទី២ : អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

### សេចក្តីផ្តើម

នៅក្នុងមេរៀនទីមួយ យើងបានទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ហើយយើងបានចាប់ផ្តើមនិយាយភាសាដទៃ ។ នៅពេលការទាំងនេះបានកើតឡើង នោះយើងបានឆ្លងកាត់ច្រកទ្វារឆ្ពោះទៅកាន់ភាពអស្ចារ្យហើយ ។ នៅពេលយើងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ និង និយាយភាសាដទៃ លោកអ្នកឈានចូលទៅក្នុងភាពអស្ចារ្យហើយ ។ នៅមេរៀននេះ យើងនឹងបន្តទៅសិក្សាអំពីអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

### គំរោងមេរៀន

### ១. សារៈសំខាន់នៃអំណោយទាន

សាវ័កប៉ុលបានបង្ហាញពីសារៈសំខាន់នៃអំណោយទានរបស់ព្រះវិញ្ញាណបរិសុទ្ធសម្រាប់ពួកអ្នកជឿទាំងអស់នៅពេលលោកបានសរសេរថា "បងប្អូនអើយ ខ្ញុំចង់អោយបងប្អូនជ្រាបយ៉ាងច្បាស់អំពីព្រះអំណោយទានរបស់ព្រះ វិញ្ញាណ " (១កូរិនថូស ១២:១) ។

ក. អំណោយទានទាំងប្រាំបួនយ៉ាងត្រូវបានបើកបង្ហាញ

១. លោកប៉ុលបានបង្រៀនអំពីភាពខុសគ្នា សកម្មភាព និង ការបង្ហាញអោយឃើញ នៃអំណោយទាននិមួយៗក្នុងចំណោមអំណោយទានទាំងប្រាំបួនរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

> "រីឯអំណោយទាននោះមានផ្សេងៗពីគ្នា តែគឺជាព្រះវិញ្ញាណដដែលទេ ហើយក៏មានមុខងារផ្សេងៗពីគ្នា តែគឺជាព្រះអម្ចាស់ដដែលដែរ ព្រមទាំងមានរបៀបធ្វើផ្សេងៗពីគ្នាទៀត តែគឺជាព្រះដដែលនោះឯង ដែលទ្រង់ធ្វើគ្រប់ទាំងអស់ក្នុងមនុស្សទាំងអស់ ហើយទ្រង់ប្រទានអោយព្រះវិញ្ញាណសម្តែងមកក្នុងគ្រប់គ្នា ដើម្បីអោយបានកើតផល ដ្បិតទ្រង់ប្រទានអោយម្នាក់មានពាក្យសំដីនៃប្រាជ្ញាវាងវៃដោយសារព្រះវិញ្ញាណ អោយម្នាក់ទៀតមានពាក្យសំដីនៃចំណេះចេះស្ទាត់តាមព្រះវិញ្ញាណដដែល ហើយអោយម្នាក់ផ្សេងទៀតមានសេចក្តីជំនឿដោយនូវព្រះវិញ្ញាណដដែល អោយមួយទៀតបានអស់ទាំងអំណោយទាន និង អាចប្រោសអោយជាដោយនូវព្រះវិញ្ញាណដដែល ។ អោយមួយទៀតបានសំដែងការឫទ្ធិបារមី និងអោយមួយទៀតចេះអធិប្បាយ ។ អោយមួយទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ ។ អោយមួយទៀតចេះនិយាយភាសាដទៃផ្សេងៗ ហើយអោយមួយទៀតចេះបកប្រែភាសាដទៃ" (១កូរិនថូស ១២:៤-១០) ។

ខ. ចំពោះអ្នកជឿទាំងអស់

ចូរកត់សំគាល់ថា លោកប៉ុលបានបង្រៀននៅក្នុងខប្រាំពីរថា អំណោយទានទាំងនេះគឺត្រូវបានប្រទានមកដើម្បីជាប្រយោជន៍ដល់អ្នកជឿទាំងអស់ ។ អ្នកជឿទាំងអស់នឹងមិនទទួលប្រយោជន៍ក្នុងទំហំដូចដែលព្រះជាម្ចាស់សព្វព្រះហឫទ័យអោយទទួលនោះទេ ប្រសិនបើអំណោយទានទាំងអស់នេះមិនមានដំណើរការនោះ ។ លោកប៉ុលក៏បានបង្រៀននៅក្នុងខគម្ពីរនេះផងដែរថា អំណោយទានទាំងប្រាំបួន

នេះត្រូវបានប្រទានមកអោយយើងម្នាក់ៗ ។ ខគម្ពីរនេះបង្ហាញប្រាប់យ៉ាងច្បាស់ថា អ្នកជឿគ្រប់គ្នាដោយមានជំនួយដ៏អស្ចារ្យពីព្រះវិញ្ញាណបរិសុទ្ធ អាច និង គួរតែប្រព្រឹត្តតាមអ្វីដែលព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងអោយធ្វើតាមរយៈអំណោយទានទាំងប្រាំបួន ។

គ. ការណែនាំចំពោះការប្រើប្រាស់ជាសាធារណៈ

១. គ្រិស្តបរិស័ទគ្រប់រូបគួរតែរួមចំណែកនៅក្នុងការប្រើអំណោយទាន នៅពេលពួកគេប្រជុំគ្នា ។ ដូចដែលផ្នែកផ្សេងៗនៃរូបកាយរបស់យើងបំពេញតួនាទីតាមរយៈការបញ្ជារបស់ស៊ីញ៉ាល់ដែលទទួលបានពីខួរក្បាល គ្រិស្តបរិស័ទគ្រប់រូបក៏ត្រូវតែប្រព្រឹត្តតាមអ្វី ដែលព្រះវិញ្ញាណបរិសុទ្ធដឹកនាំតាមរយៈអំណោយទានដែរ ។

២. "ប៉ុន្តែ មានព្រះវិញ្ញាណតែមួយដដែល ដែលបំពេញសកម្មភាពទាំងអស់ ហើយប្រទានអោយម្នាក់ៗមានព្រះអំណោយទានផ្សេងៗពីគ្នាតាមព្រះហឫទ័យរបស់ព្រះអង្គ ។ ព្រះគ្រិស្តប្រៀបបានទៅនឹងរូបកាយមួយដែលចែកចេញជាច្រើនផ្នែក ។ ទោះបីមានសរីរាង្គច្រើនយ៉ាងណាក៏ដោយ ក៏សរីរាង្គទាំងអស់ផ្សំគ្នាជារូបកាយតែមួយដែរ" (១កូរិនថូស ១២:១១-១២) ។

៣. "ព្រះជាម្ចាស់ផ្តល់សាក្សីភាពរួមជាមួយពួកគេ ដោយសំដែងទីសំគាល់ ឫទ្ធិបដិហារិយ៍ ការអស្ចារ្យគ្រប់យ៉ាង ព្រមទាំងចែកព្រះអំណោយទានរបស់ព្រះវិញ្ញាណបរិសុទ្ធ មកស្របតាមព្រះហឫទ័យព្រះអង្គផង" (ហេព្រើរ ២:៤) ។

៤. ការដែលយើងរៀនស្តាប់តាមព្រះវិញ្ញាណបរិសុទ្ធគឺសំខាន់ខ្លាំងណាស់ ។

## ២. ការលើកទឹកចិត្តអោយបំពេញព័ន្ធកិច្ចតាមរយៈអំណោយទាន

យើងត្រូវខំខ្នះខ្នែង និង ចង់អោយពួកយើងម្នាក់ៗពូកែក្នុងការប្រើអំណោយទានទាំងនេះ ប៉ុន្តែ មិនមែនដើម្បីអោយយើងមើលទៅល្អនោះទេ គឺដើម្បីអោយក្រុមជំនុំទាំងមូលមានការអភិវឌ្ឍន៍ ។

"រីឯបងប្អូនវិញ បើបងប្អូនចង់ប្រាថ្នាចង់បានព្រះអំណោយទានរបស់ព្រះវិញ្ញាណ ដូច្នេះ ត្រូវរកអោយបានច្រើនបរិបូរណ៏ទៅ ជាពិសេស រកព្រះអំណោយទានសម្រាប់កសាងក្រុមជំនុំ" (១កូរិនថូស ១៤:១២) ។

ក. ចំពោះការស្អាងក្រុមជំនុំ

១. ព្រះយេស៊ូបានមានបន្ទូលថា ព្រះអង្គនឹងស្អាងក្រុមជំនុំរបស់ព្រះអង្គ ។ ក្រុមជំនុំរបស់ព្រះអង្គនឹងត្រូវបានស្អាងឡើងនៅពេលដែលអំណោយទាំងនេះមានដំណើរការ ។ ជំនួសអោយការព្រងើយកន្តើយចំពោះអំណោយទានទាំងនេះ យើងត្រូវតែសិក្សា អនុវត្ត និង ហ្វឹកហាត់ខ្លួនយើងអោយចេះប្រើអំណោយទានទាំងនេះ រហូតយើងឈានដល់ចំណុចមួយដែលយើងអាចប្រើអំណោយទាននិមួយៗ និង អំណោយទានទាំងអស់ ។

២. យើងត្រូវតែមានបំណងប្រាថ្នាចង់អោយខ្លួនយើងមានភាពស្ទាត់ជំនាញក្នុងការប្រើអំណោយទានទាំងនេះក្នុងជីវិតរបស់យើង ។ នៅពេលដែលសេចក្តីត្រូវការកើតឡើងនៅក្នុងជីវិតរបស់មនុស្ស រឺ នៅក្នុងរូបកាយរបស់ព្រះគ្រិស្ត យើងគួរតែព្យាយាមប្រើអំណោយទាន ដែលល្អ

ប្រសើរបំផុត គឺអំណោយទានដែលអាចបំពេញសេចក្តីត្រូវការនោះប្រកបដោយប្រសិទ្ធិភាពបំផុត ។

៣. "បងប្អូនម្នាក់ៗបានទទួលព្រះអំណោយទានផ្សេងៗពីគ្នា ដូច្នេះ ចូរយកព្រះអំណោយទានទាំងនេះទៅបំរើអ្នកឯទៀតៗអោយសមនឹងនាទីរបស់បងប្អូន ជាអ្នកចាត់ចែងដ៏ល្អដែលចែកព្រះអំណោយទានគ្រប់បែបយ៉ាងរបស់ព្រះជាម្ចាស់" (១ ពេត្រុស ៤:១០) ។

ខ. ត្រូវសង្វាតចង់បានអំណោយទានទាំងនេះ

"ចូរប៉ងប្រាថ្នាចង់បានអំណោយទានណាដែលសំខាន់ជាងគេ ។ ក៏ប៉ុន្តែ ខ្ញុំចង់បង្ហាញប្រាប់បងប្អូនពីមាគ៌ាមួយទៀតដែលប្រសើរលើសលុបបំផុត" (១កូរិនថូស ១២:៣១) ។ វិធីដែលប្រសើរបំផុតក្នុងការប្រើអំណោយទានទាំងនេះគឺដោយសេចក្តីជំនឿ សេចក្តីសង្ឃឹម និង សេចក្តីស្រលាញ់ ដូចដែលមានពណ៌នានៅក្នុង ១កូរិនថូស ជំពូកទី១៣ ។ អំណោយទានមានដំណើរការដោយសារសេចក្តីជំនឿ ហើយនឹងនាំយកសេចក្តីសង្ឃឹមថ្មីមកអោយក្រុមជំនុំ និង ជីវិតរបស់មនុស្សដទៃទៀត ។ យើងត្រូវតែឆ្លុះឆ្លងដោយព្រោះសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះអ្នកដទៃ មិនមែនដោយព្រោះសេចក្តីអំនួតរបស់យើងនោះទេ ។

គ. ធ្វើអោយអំណោយទានមានសកម្មភាពឡើងវិញ

១. "ហេតុនេះហើយ បានជាខ្ញុំសុំរំលឹកដាស់តឿនអ្នកថា ចូរធ្វើអោយព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដែលអ្នកបានទទួលដោយខ្ញុំដាក់ដៃលើនោះ មានសកម្មភាពឡើងវិញ" (២ធីម៉ូថេ ១:៦) ។

២. "ខ្ញុំមានបំណងចង់ជួបបងប្អូនយ៉ាងខ្លាំងដើម្បីចែកព្រះអំណោយទានណាមួយរបស់ព្រះវិញ្ញាណជូនបងប្អូន អោយបងប្អូនបានមាំមួនឡើង...." ។ អំណោយទានទាំងនេះត្រូវបានចែករំលែក និង មានដំណើរការនៅក្នុងជីវិតរបស់លោកធីម៉ូថេតាមរយៈការដាក់ដៃរបស់លោកប៉ុល ។ ពេលនេះ វាគឺជាភារកិច្ចរបស់លោកធីម៉ូថេក្នុងការធ្វើអោយអំណោយទានទាំងនេះមានសកម្មភាព និង ឆ្លុះឆ្លងនៅក្នុងជីវិត និង ព័ន្ធកិច្ចរបស់លោក ។ តាមរយៈការធ្វើដូច្នេះ យើងនឹងរស់នៅ និង ដើរនៅក្នុងព្រះវិញ្ញាណ (រ៉ូម ១:១១) ។

៣. "យើងមិនត្រូវអួតបំប៉ោង រករឿងគ្នាទៅវិញទៅមក និង ឈ្នានីសគ្នានោះឡើយ" (កាឡាទី ៥:២៥) ។

## ៣. ប្រភេទទាំងបីនៃអំណោយទាន

អំណោយទានទាំងប្រាំបួនរបស់ព្រះវិញ្ញាណបរិសុទ្ធគឺជាឧបករណ៍ដ៏សំខាន់ក្នុងការបំពេញព័ន្ធកិច្ចសម្រាប់អ្នកជឿគ្រប់ៗគ្នា ។ ដើម្បីយល់ដឹងអោយបានច្បាស់អំពីមុខងារ និង របៀបដែលអំណោយទានទាំងនោះមានដំណើរការនៅក្នុងជីវិតរបស់យើងម្នាក់ៗ យើងបានបែងចែកអំណោយទានទាំងនេះជាបីប្រភេទគឺ :

ក. អំណោយទានបញ្ចេញជាសម្លេង (ការនិយាយ)

- អំណោយទានបញ្ចេញជាសំលេង (អំណោយទាននៃសួរស័ព្ទ) គឺជាការសម្តែងអោយ

ឃើញពីព្រះវិញ្ញាណបរិសុទ្ធដែលមានបន្ទូលដោយអស្ចារ្យមកកាន់យើង រឺ តាមរយៈយើង ។ នៅពេលការនេះកើតឡើង អ្នកជឿត្រូវបានធ្វើអោយរឹងមាំ លើកទឹកចិត្ត និង កំសាន្តចិត្ត ប៉ុន្តែ មិនមែនថ្កោលទោសនោះឡើយ ។

អំណោយទានដែលស្ថិតនៅក្នុងប្រភេទអំណោយទានបញ្ចេញជាសម្លេងនេះគឺ :

១. អំណោយទាននៃការនិយាយភាសាដទៃ
២. អំណោយទាននៃការបកប្រែភាសាដទៃ
៣. អំណោយទាននៃការថ្លែងព្រះបន្ទូល

ខ. អំណោយទាននៃការបើកសំម្តែង ( ការស្តាប់)

- អំណោយទាននៃនៃការបើកសម្តែងត្រូវបានបង្ហាញអោយឃើញនៅពេលដែលព្រះជាម្ចាស់បើកសម្តែងដោយអស្ចារ្យពីអត្តសញ្ញាណ និស្ស័យ ឬ សកម្មភាពនៃវិញ្ញាណ ឬនៅពេលព្រះអង្គបើកសំដែងដោយអស្ចារ្យពីចំណេះដឹង ឬប្រាជ្ញាបង្ហាញដល់ប្រជារាស្ត្ររបស់ព្រះអង្គ ។ ការបើកសំដែងនេះកើតឡើងនៅក្នុងគំនិតរបស់យើងតាមរយៈវិញ្ញាណរបស់យើង ហើយមានទំរង់ជាការគិត អារម្មណ៍ ការយល់សប្តិ និង និម្មិត្ត ។

អំណោយទានដែលស្ថិតនៅក្នុងប្រភេទអំណោយទាននៃការបើកសម្តែងគឺ :

១. អំណោយទាននៃការសង្កេតស្គាល់អស់ទាំងវិញ្ញាណ
២. អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ
៣. អំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់

គ. អំណោយទាននៃអំណាច ( ការធ្វើការ)

- អំណោយទាននៃអំណាចត្រូវបានបង្ហាញអោយឃើញតាមរយៈការដែលព្រះជាម្ចាស់បើកអោយសេចក្តីជំនឿ និង អំណាចដែលខុសពីធម្មតារបស់ព្រះអង្គធ្វើការ ឬ ហូរតាមរយៈយើង ។

អំណោយទានដែលស្ថិតនៅក្នុងប្រភេទអំណោយទាននៃអំណាចគឺ :

១. អំណោយទាននៃសេចក្តីជំនឿ
២. អំណោយទាននៃការប្រោសអោយជា
៣. អំណោយទាននៃការធ្វើការអស្ចារ្យ

## ៤. ការនិយាយភាសាដទៃ :មនុស្សនិយាយទៅកាន់ព្រះជាម្ចាស់ រឺ ព្រះជាម្ចាស់មានបន្ទូលមកកាន់មនុស្ស

ខគម្ពីរបង្ហាញអោយឃើញពីភាពខុសគ្នារវាងការនិយាយភាសាដទៃដែលអ្នកជឿទាំងអស់ទទួលបាននៅពេលពួកគេបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ និង អំណោយទាននៃការនិយាយភាសាចដទៃដែលតាមរយៈអំណោយទាននេះ ព្រះរាជសាររបស់ព្រះជាម្ចាស់នឹងត្រូវបានប្រទានមកអោយពួកអ្នកជឿតាមរបៀបដ៏អស្ចារ្យ ។ មួយគឺជាភាសានៃការសរសើរតម្កើង និង ការអធិស្ឋានទៅកាន់ព្រះជាម្ចាស់ ឯមួយទៀតគឺជាព្រះរាជសាររបស់ព្រះជាម្ចាស់មកកាន់

មនុស្ស ។ នៅថ្ងៃបុណ្យទីហាសិប ពួកគេទាំងអស់គ្នាបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយពួកគេបានចាប់ផ្តើមនិយាយ ភាសាដទៃ នៅពេលដែលព្រះវិញ្ញាណប្រទានអំណោយទានដែលបញ្ចេញជាសម្លេងដល់ពួកគេ (កិច្ចការ ២:៤) ។

ក. ភាសារបស់ទេវតា រឺ ភាសារបស់មនុស្ស

១. ការនិយាយភាសាដទៃនេះអាចជាភាសានៃស្ថានសួគ៌ដែលជាភាសារបស់ទេវតា (១ កូរិនថូស ១៣:១) រឺ ជាភាសារបស់មនុស្សដែលអ្នកនិយាយមិនអាចយល់ តែអ្នកស្តាប់អាចយល់បាន ។

២. "ពេលសូរសន្ធឹកលាន់ឮយ៉ាងខ្លាំងដូច្នោះ មហាជននាំគ្នារត់មកមើល ហើយភ្ញាក់ផ្អើលក្រៃលែង ព្រោះម្នាក់ៗបានឮពួកសាវ័កនិយាយភាសារបស់ខ្លួន ។ អ្នកទាំងនោះងឿងឆ្ងល់ខ្លាំងណាស់ គេស្ងើចសរសើរទាំងពោលថា "អ្នកដែលកំពុងនិយាយនេះ សុទ្ធតែជាអ្នកស្រុកកាលីឡេទេតើ ។ ចុះហេតុដូចម្តេចបានជាយើងឮគេនិយាយភាសារបស់យើងរៀងៗខ្លួនទៅវិញដូច្នេះ ?".....ទាំងជនជាតិយូដា ទាំងអ្នកចូលសាសនាយូដា ទាំងអ្នកមកពីកោះក្រែត ទាំងជនជាតិអារ៉ាប់ យើងបានឮគេថ្លែងអំពីស្នាព្រះហស្ថដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ជាភាសាយើងទាំងអស់គ្នាផ្ទាល់!" (កិច្ចការ ២:៦-៨, ១១) ។

ខ. ភាសាដទៃ : ការសរសើរតម្កើងព្រះជាម្ចាស់

- គ្រប់អ្នកជឿដែលពេញដោយព្រះវិញ្ញាណ និង ដែលនិយាយភាសាដទៃ ដើម្បីជាភស្តុតាងបង្ហាញថាគេបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធត្រូវបន្តនិយាយ និង ច្រៀងសរសើរព្រះជាម្ចាស់ជាភាសាដទៃរបស់ពួកគេនោះជារៀងរាល់ថ្ងៃ ។ តាមរយៈការធ្វើដូច្នេះ អ្នកនោះនឹងនិយាយសេចក្តីអាថ៌កំបាំងដោយនូវវិញ្ញាណរបស់ពួកគេ ។

  ក. "ដ្បិតអ្នកណាដែលនិយាយភាសាដទៃ នោះមិនមែននិយាយនឹងមនុស្ស គឺទូលនឹងព្រះវិញ ពីព្រោះគ្មាននរណាស្តាប់បានទេ ប៉ុន្តែ អ្នកនោះនិយាយជាសេចក្តីអាថ៌កំបាំងដោយនូវវិញ្ញាណ" (១ កូរិនថូស ១៤:២) ។

  ខ. យើងត្រូវបានកសាងឡើងដោយការនិយាយភាសាដទៃ ។ លោកប៉ុលបាននិយាយថា "អ្នកណានិយាយភាសាដទៃ នោះស្អាងតែខ្លួនឯងទេ " (១កូរិនថូស ១៤:៤) ។

គ. លោកប៉ុលបញ្ជាក់ពីសារៈសំខាន់នៃការនិយាយភាសាដទៃ ។

១. លោកប៉ុលបានសរសេរថា "ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ ដ្បិតខ្ញុំនិយាយភាសាដទៃជាច្រើនលើសជាងអ្នករាល់គ្នាទាំងអស់ " (១ កូរិនថូស ១៤:១៨) ។

២. លោកប៉ុលបានសរសេរទៀតថា "ខ្ញុំចង់អោយអ្នករាល់គ្នានិយាយភាសាដទៃទាំងអស់ដែរ ....." (១ កូរិនថូស ១៤:៥) ។ នៅក្នុងខទី ៣៩ លោកប៉ុលបានមានប្រសាសន៍ថា "ហើយកុំអោយឃាត់មិនអោយនិយាយជាភាសាដទៃនោះឡើយ" ។

ឃ. ភាសាដទៃ :ទីសំគាល់សម្រាប់អ្នកជឿ

១.	ភាសាដទៃគឺជាទីសំគាល់មួយ ដែលព្រះយេស៊ូបានមានបន្ទូល ។ "ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿគឺថា គេនឹងដេញអារក្សដោយនូវឈ្មោះខ្ញុំ ហើយនឹងចេះនិយាយភាសាថ្មី" (ម៉ាកុស ១៦:១៧) ។ ដូចដែលអ្នកជឿបានអធិប្បាយ និង ចែកចាយដំណឹងល្អដែរ ភាសាដទៃគឺជាទីសំគាល់ដ៏អស្ចារ្យមួយដែលបញ្ជាក់ពីព្រះបន្ទូលប្រាប់ដល់ពួកអ្នកដែលមិនជឿ ។

២.	អត្ថបទគម្ពីរនៅក្នុងកណ្ឌគម្ពីរម៉ាកុសនេះបញ្ចប់នៅត្រង់ ១៦:២០ ជាមួយនឹងពាក្យថា "ពួកសាវ័កនាំគ្នាចេញទៅប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែង ។ ព្រះជាម្ចាស់ធ្វើការជាមួយពួក គេ ទាំងបញ្ជាក់ព្រះបន្ទូលដោយសំដែងទីសំគាល់ផ្សេងៗជាប់ជាមួយផង" ។

៣.	មានព្រលឹងចំនួនបីពាន់ត្រូវបានដាក់អោយសណ្ឋិតលើពួកអ្នកជឿនៅពេលទីសំគាល់អស្ចារ្យនៃការនិយាយភាសាដទៃបានកើតឡើងនៅថ្ងៃបុណ្យទី៥០ ។

៤.	ភាសាដទៃគឺជាមាត់ផ្លូវឆ្ពោះទៅកាន់អំណោយទានដ៏អស្ចារ្យនៃព្រះវិញ្ញាណបរិសុទ្ធ ។

## ការពិភាក្សាជាក្រុម

១. ដោយផ្អែកលើ ១កូរិនថូស ១២:២៩-៣០ ចូរចែករំលែកទស្សនៈជាមួយគ្នាទៅវិញទៅមកស្តីអំពីឃ្លាមួយនៅក្នុងមេរៀននេះដែលសរសេរថា :

"អំណោយទានទាំងប្រាំបួននេះត្រូវបានប្រទានមកអោយយើងម្នាក់ៗ" ។

២. តើការប្រើអំណោយទានដែលល្អបំផុតមានន័យយ៉ាងដូចម្តេច ?

៣. តើអ្វីជាមធ្យោបាយប្រសើរបំផុតក្នុងការប្រើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ?

## ការសិក្សាដោយខ្លួនឯង

១. សូមអាន រ៉ូម ១:១១ និង ២ ធីម៉ូថេ ១:៦ ។ តើលោកអ្នកអាចធ្វើអោយអំណោយទានរបស់ព្រះជាម្ចាស់មានសកម្មភាពឡើងវិញនៅក្នុងខ្លួនរបស់លោកអ្នកយ៉ាងដូចម្តេចទៅ ?

២. ចូរសរសេរនិយមន័យផ្ទាល់ខ្លួនរបស់លោកអ្នកសម្រាប់អំណោយទានទាំងប្រាំបួនរបស់ព្រះវិញ្ញាណ :

ក. អំណោយទាននៃការនិយាយភាសាដទៃ

ខ. អំណោយទាននៃការបកប្រែភាសាដទៃ

គ. អំណោយទាននៃការថ្លែងទំនាយ

ឃ. អំណោយទាននៃការសង្កេតស្គាល់អស់ទាំងវិញ្ញាណ

ង. អំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់

ច. អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ

ឆ. អំណោយទាននៃសេចក្តីជំនឿ

ជ. អំណោយទាននៃការប្រោសអោយជា

ណ. អំណោយទាននៃការធ្វើការអស្ចារ្យ

# ការរស់ដោយអស្ចារ្យ
# មេរៀនទី៣ : អំណោយទានបញ្ចេញជាសម្លេង

## សេចក្តីផ្តើម

នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីរបៀបប្រើអំណោយទានបញ្ចេញជាសម្លេងរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ អំណោយទានទាំងនោះរួមមាន : អំណោយទាននៃការនិយាយភាសាដទៃ អំណោយទាននៃការបកប្រែភាសាដទៃ និង អំណោយកទាននៃការថ្លែងទំនាយ ។ ភាសាដទៃគឺជាភាសាសម្រាប់អធិស្ឋានដ៏អស្ចារ្យរបស់ពួកអ្នកជឿដែលពេញដោយព្រះវិញ្ញាណ ។

## គំរោងមេរៀន

១. *ភាសាដទៃ : ភាសាដ៏អស្ចារ្យសម្រាប់អធិស្ឋាន*

លោកប៉ុលបានសរសេរថា "ហេតុនេះហើយបានជាអ្នកណាដែលនិយាយភាសាដទៃ នោះត្រូវអធិស្ឋានសូមអោយចេះបកប្រែដែរ ។ បើខ្ញុំអធិស្ឋានជាភាសាដទៃ នោះគឺជាវិញ្ញាណខ្ញុំដែលអធិស្ឋាន តែឥតមានប្រយោជន៏ដល់ប្រាជ្ញាខ្ញុំសោះ ដូច្នេះ ត្រូវធ្វើដូចម្តេច ? ខ្ញុំត្រូវអធិស្ឋានដោយនូវវិញ្ញាណ ហើយត្រូវអធិស្ឋានដោយនូវប្រាជ្ញាផង ខ្ញុំនឹងច្រៀងដោយវិញ្ញាណ ហើយនឹងច្រៀងដោយប្រាជ្ញាដែរ" (១ កូរិនថូស ១៤:១៣-១៥) ។

នៅពេលខ្ញុំអធិស្ឋានជាភាសាដទៃដោយនូវវិញ្ញាណរបស់ខ្ញុំ ខ្ញុំបានឈានចូលទៅក្នុងការអធិស្ឋានមួយដែលអស្ចារ្យ មានអំណាច និង គ្មានព្រំដែន ។ ការអធិស្ឋានរបស់ខ្ញុំលែងស្ថិតនៅក្រោមដែនកំណត់នៃការខ្វះការយល់ដឹងរបស់ខ្ញុំទៀតហើយ ។ នៅពេលខ្ញុំអធិស្ឋានដោយនូវវិញ្ញាណ ព្រះវិញ្ញាណបរិសុទ្ធអធិស្ឋានតាមរយៈវិញ្ញាណរបស់ខ្ញុំ ដោយស្របទៅតាមបំណងព្រះហឫទ័យ ចំណេះដឹង និង ប្រាជ្ញារបស់ព្រះជាម្ចាស់ ។

"យ៉ាងណាមិញ ព្រះវិញ្ញាណក៏យាងមកជួយយើងដែលទន់ខ្សោយនេះដែរ ដ្បិតយើងពុំដឹងអធិស្ឋានដូចម្តេចដើម្បីអោយបានសមនោះឡើយ តែព្រះវិញ្ញាណផ្ទាល់ទ្រង់ទូលអង្វរអោយយើង ដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន ។ រីឯព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណទូលអង្វរអោយប្រជាជនបរិសុទ្ធស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់" (រ៉ូម ៨:២៦-២៧) ។

នៅពេលយើងអធិស្ឋានដោយនូវព្រះវិញ្ញាណ យើងអាចដឹងប្រាកដថា យើងមិនមែនកំពុងទូលសុំអ្វីដែលមិនត្រឹមត្រូវនោះឡើយ ។ យ៉ាកុបបានសរសេរថា "អ្នករាល់គ្នាក៏សូមដែរតែមិនបានទេ ដ្បិតសេចក្តីសំណូមនោះបែបអាក្រក់" (យ៉ាកុប ៤:៣) ។

ជាធម្មតា នៅពេលយើងអធិស្ឋានដោយវិញ្ញាណ អំណោយទាននៃការបកប្រែភាសាដទៃក៏ចាប់ផ្តើមធ្វើការដែរ ។ យើងក៏ចាប់ផ្តើមអធិស្ឋានដោយការបើកសម្តែងដ៏អស្ចារ្យ "ជាមួយនឹងការយល់ដឹង" ជាភាសារបស់យើង ។

នៅពេលយើងអធិស្ឋានជាភាសាដទៃ យើងមិនមែនអធិស្ឋានដោយការយល់ដឹងដែលមិនមានផលផ្លែ រឺ អធិស្ឋានអំពីបញ្ហាអ្វីមួយដោយសេចក្តីភ័យខ្លាចទៀតទេ ។ យើងកំពុងដកដាវនៃព្រះវិញ្ញាណ ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយតែងតែអធិស្ឋានជាមួយនឹងពាក្យទូលអង្វរដោយព្រះវិញ្ញាណ (អេភេសូរ ៦:១៦-១៧) ។

ក. ព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈអំណោយទាននៃការនិយាយភាសាដទៃ

១. អំណោយទានដែលបញ្ចេញជាសម្លេងតែងនាំមកនូវកំលាំង ការលើកទឹកចិត្ត និង ការកំសាន្តចិត្តជំនួសអោយការដាក់ទោស ។

២. "ផ្ទុយទៅវិញ អ្នកណាអធិប្បាយ អ្នកនោះនិយាយទៅកាន់មនុស្សដើម្បីជួយកសាង ដាស់តឿន និង លើកទឹកចិត្តគេ" (១ កូរិនថូស ១៤:៣) ។

ខ. ត្រូវតែទទួលការវិនិច្ឆ័យ

១. ព្រះរាជសារដែលមកតាមរយៈអំណោយទាននេះគឺជាសេចក្តីដែលអាចខុសបានរបស់មនុស្ស ហើយវាមិនដែលត្រូវបានគេចាត់ថាមានអំណាចដូចជាបទគម្ពីរឡើយ ។ ដូច្នេះ អស់អ្នកដែលបានឮត្រូវធ្វើការវិនិច្ឆ័យថា តើព្រះរាជសារទាំងនោះគឺពិតជាព្រះរាជសារដែលពិតប្រាកដ និង ច្បាស់លាស់របស់ព្រះជាម្ចាស់មែនឬយ៉ាងណា ។

២. "រីឯការអធិប្បាយវិញ ត្រូវអោយពីរ ឬ បីនាក់ថ្លែង ហើយអ្នកដទៃទៀតត្រូវពិចារណាមើល" (១ កូរិនថូស ១៤:២៩) ។

គ. អត្ថន័យនៃអំណោយទាននៃការនិយាយភាសាដទៃ

អំណោយទាននៃការចេះនិយាយភាសាដទៃគឺជាការសំដែងចេញជាសម្លេងដ៏អស្ចារ្យនៃការបណ្តាលរបស់ព្រះវិញ្ញាណបរិសុទ្ធដោយប្រើប្រាស់សម្លេងធម្មតារបស់យើង ។ ព្រះជាម្ចាស់មានបន្ទូលមកកាន់ពួកអ្នកជឿតាមរយៈអំណោយទាននេះ នៅពេលដែលអំណោយទាននេះត្រូវបានប្រើជាមួយនឹងអំណោយទាននៃការចេះបកប្រែភាសាដទៃ ។ អ្នកជឿដែលប្រើអំណោយទាននេះមិនយល់ភាសាដែលគេនិយាយនោះទេ ។

ឃ. អំណោយទាននៃការបកប្រែភាសាដទៃ

១. ការសរសើរតម្កើងព្រះជាម្ចាស់ជាភាសាដទៃមិនត្រូវការការបកប្រែឡើយ ។ ប៉ុន្តែ នៅពេលព្រះជាម្ចាស់មានបន្ទូលមកកាន់ពួកអ្នកជឿតាមរយៈអំណោយទាននៃការនិយាយភាសាដទៃ ចាំបាច់ត្រូវអោយមានការបកប្រែពីសំណាក់ទាំងអ្នកដែលថ្លែងព្រះរាជសារជាភាសាដទៃ និង អ្នកដទៃ ។

២. " ហេតុនេះ បានជាអ្នកណាដែលនិយាយភាសាដទៃ នោះត្រូវអធិស្ឋានសូមអោយចេះបកប្រែដែរ" (១ កូរិនថូស ១៤:១៣) ។

៣. អំណោយទាននៃការបកប្រែភាសាដទៃគឺជាការពន្យល់ និង ការបង្ហាញដ៏អស្ចារ្យរបស់ព្រះវិញ្ញាណពីអត្ថន័យរបស់ព្រះរាជសារដែលថ្លែងមកជាភាសាដទៃ ជាភាសាផ្ទាល់ខ្លួនរបស់អ្នកស្តាប់ ។ នេះមិនមែនជាការប្រើប្រាស់ រឺ ជាការយល់ដឹងដោយគំនិតនោះឡើយ ប៉ុន្តែ ជាការប្រទានមកដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ។

៤. ការបកប្រែភាសាដទៃអាចមានតាមរយៈអ្នកជឿណាម្នាក់ ដែលព្រះជាម្ចាស់សព្វព្រះហប្ញទ័យអោយប្រើអំណោយទាននេះជាមួយនឹងគំនិត និម្មិត្ត រឺ គ្រាន់តែជាពាក្យចាប់ផ្តើម ។ នៅពេលយើងមាន

សេចក្តីជំនឿ ហើយចាប់ផ្តើមនិយាយ ព្រះជាម្ចាស់នឹងបំពេញមាត់របស់យើងដោយពាក្យពេជន៏ដែលមានជាហូរហែរហូតទាល់តែការបកប្រែព្រះរាជសារជាភាសាដទៃទាំងមូលត្រូវបានបញ្ចប់សព្វគ្រប់ ។

## ២. សេចក្តីណែនាំសម្រាប់ការប្រើអំណោយទានបញ្ចេញជាសម្លេងនៅក្នុងក្រុមជំនុំ

មានការភាន់ច្រឡំទាក់ទងនឹងសណ្តាប់ធ្នាប់ និង ការប្រើប្រាស់អំណោយទានបញ្ចេញជាសំលេងនៅក្នុងក្រុមជំនុំក្រុងកូរិនថូស ។ ការសរសេររបស់លោកប៉ុលបានបង្ហាញយ៉ាងច្បាស់ថា មានអ្នកជឿជាច្រើនបាននិយាយភាសាដទៃនៅពេលតែមួយដោយមិនទុកឱកាសអោយមានការបកប្រែភាសាដទៃ ។ ការនេះបានធ្វើអោយមានការភាន់ច្រឡំ ដែលជាហេតុបានធ្វើអោយលោកប៉ុលផ្តល់សេចក្តីណែនាំដ៏ច្បាស់លាស់សម្រាប់ការប្រើអំណោយទានបញ្ចេញជាសម្លេងនៅក្នុងការថ្វាយបង្គំរបស់ក្រុមជំនុំ ។

"បើមានអ្នកណានិយាយជាភាសាដទៃ នោះនិយាយបានតែពីរ ឬ បីនាក់យ៉ាងច្រើន ហើយម្នាក់ម្តង១ផង រួចត្រូវមានអ្នកមួយជាអ្នកបកប្រែ" (១ កូរិនថូស ១៤:២៧) ។

"ប៉ុន្តែ ក្នុងពួកជំនុំ ខ្ញុំចូលចិត្តនិយាយតែពាក្យ៥ម៉ាត់ដោយនូវប្រាជ្ញាខ្ញុំ ដើម្បីនឹងបង្រៀនដល់មនុស្សឯទៀតជាជាងនិយាយភាសាដទៃមួយម៉ឺនម៉ាត់វិញ ។ បើគ្មានអ្នកណាសម្រាប់បកប្រែទេ នោះត្រូវអោយគេនៅស្ងៀមក្នុងពួកជំនុំចុះ ហើយទូលដល់ព្រះដោយខ្លួនឯងវិញ" (១ កូរិនថូស ១៤:១៩, ២៨) ។

ប្រសិនបើព្រះរាជសារត្រូវបានប្រទានមកជាភាសាដទៃ ហើយគ្មានការបកប្រែទេនោះ វានឹងធ្វើអោយមានការភាន់ច្រឡំ ។ បើគ្មាននរណាម្នាក់ប្រើអំណោយទាននៃការបកប្រែភាសាដទៃទេនោះ ព្រះរាជសារគួរតែប្រទានមកជាភាសាមួយដែលគេអាចយល់បាន មិនមែនជាភាសាដទៃនោះទេ ។ តាមរបៀបនេះ អ្នកដែលថ្លែងព្រះបន្ទូលនឹងមានតំលៃកាន់តែខ្លាំងចំពោះក្រុមជំនុំ ។

"ខ្ញុំចង់អោយអ្នករាល់គ្នានិយាយភាសាដទៃទាំងអស់ដែរ តែស៊ូអោយអ្នករាល់គ្នាចេះអធិប្បាយជាជាង ដ្បិតអ្នកដែលអធិប្បាយនោះប្រសើរជាងអ្នកដែលនិយាយភាសាដទៃទៅទៀត លើកតែអ្នកនោះចេះបកប្រែផង ដើម្បីអោយពួកជំនុំបានស្អាងចិត្តឡើង" (១ កូរិនថូស ១៤:៥) ។

វាហាក់ដូចជាថា អ្នកជឿជាច្រើននៅក្នុងទីក្រុងកូរិនថូសបានសរសើរតម្កើងព្រះជាម្ចាស់អស់រយៈពេលយ៉ាងយូរជាភាសាដទៃនៅពេលដែលពួកគេថ្វាយបង្គំព្រះជាម្ចាស់ក្នុងក្រុមជំនុំ ។ លោកប៉ុលកំពុងពន្យល់ថា វាជាការល្អជាងសម្រាប់ពួកគេក្នុងការសរសើរតម្កើងព្រះជាម្ចាស់ជាភាសាផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែ នៅពេលពួកគេប្រជុំគ្នាហើយព្រះជាម្ចាស់ចង់មានព្រះបន្ទូលមកកាន់ពួកគេតាមរយៈអំណោយទាននៃការភាសាដទៃ នោះពួកគេគួរតែផ្តល់ព្រះរាជសារជាភាសាដទៃ រួចអនុញ្ញាតអោយព្រះជាម្ចាស់ប្រទានការបកប្រែ ។ រឺបើមិនដូច្នេះ វាមានតំលៃខ្លាំងជាងសម្រាប់ក្រុមជំនុំរបស់ពួកគេ ប្រសិនបើពួកគេផ្តល់ព្រះរាជសារនោះជាភាសាផ្ទាល់ខ្លួនរបស់ពួកគេតាមរយៈការអធិប្បាយ ។

## ៣. អំណោយទាននៃការថ្លែងទំនាយ

"ក្រោយមកទៀត យើងនឹងចាក់បង្ហូរព្រះវិញ្ញាណរបស់យើងមកលើមនុស្សលោកទាំងអស់ ។ កូនប្រុសកូនស្រីរបស់អ្នករាល់គ្នានឹងអធិប្បាយ..." (យ៉ូអែល ២:២៨) ។
"នោះព្រះវិញ្ញាណនៃព្រះយេហូវ៉ានឹងមកសណ្ឋិតលើអ្នក បណ្តាលជាខ្លាំង អ្នកនឹងទាយជាមួយនឹងគេដែរ ហើយអ្នកនឹងបានប្រែទៅជាមនុស្សថ្មីវិញ" (១ សាម៉ូអែល ១០:៦) ។

អំណោយទាននៃការទំនាយគឺជាការសំដែងចេញជាសំលេងនូវការបណ្តាលចិត្តដែលកើតឡើងដោយឯងៗ និង ដោយអស្ចារ្យជាភាសាដែលយើងស្គាល់ ហើយពង្រឹង លើកទឹកចិត្ត នឹង កំសាន្តចិត្តដល់ព្រះកាយរបស់ព្រះគ្រិស្ត ។ នេះគឺជាព្រះរាជសារផ្ទាល់របស់ព្រះជាម្ចាស់ដែលនឹងស្អាងបុគ្គល ឬ ក្រុមជំនុំទាំងមូល ។

តាមរយៈការថ្លែងទំនាយ យើងនិយាយអំពីបញ្ហាអ្វីមួយតែមួយផ្នែកប៉ុណ្ណោះ មិនមែនទាំងមូលដូចជាព្រះជាម្ចាស់នោះទេ ។ លោកប៉ុលបានសរសេរថា "សព្វថ្ងៃនេះ យើងចេះដឹងត្រឹមតែមួយផ្នែកប៉ុណ្ណោះ ហើយយើងក៏អធិប្បាយបានត្រឹមតែមួយផ្នែកប៉ុណ្ណោះដែរ" (១ កូរិនថូស ១៣:៩) ។

ក. ចំណង់ចង់ថ្លែងទំនាយ

លោកប៉ុលបានសរសេរថា : "ចូរដេញតាមសេចក្តីស្រឡាញ់ចុះ ហើយសង្វាតចង់បានអស់ទាំងអំណោយទានខាងឯវិញ្ញាណដែរ តែស៊ូអោយបានចេះអធិប្បាយជាដើម ......ខ្ញុំចង់អោយអ្នករាល់គ្នានិយាយភាសាដទៃទាំងអស់ដែរ តែស៊ូអោយអ្នករាល់គ្នាចេះអធិប្បាយជាជាង ដ្បិតអ្នកដែលអធិប្បាយនោះប្រសើរជាងអ្នកដែលនិយាយភាសាដទៃទៅទៀត លើកតែអ្នកនោះចេះបកប្រែផង ដើម្បីអោយពួកជំនុំបានស្អាងចិត្តឡើង......ដូច្នេះ បងប្អូនអើយ ចូរសង្វាតអោយចេះអធិប្បាយ........." (១ កូរិនថូស ១៤:១,៥,៣៩) ។

ខ. ត្រូវទទួលការវិនិច្ឆ័យ

"រីឯការអធិប្បាយវិញ ត្រូវអោយពីរ ឬ បីនាក់ថ្លែង ហើយអ្នកឯទៀតៗត្រូវពិចារណាមើល ។ បើមាននរណាម្នាក់ដែលអង្គុយក្នុងអង្គប្រជុំនោះ បានទទួលគំនិតអ្វីមួយពីព្រះជាម្ចាស់ ត្រូវអោយអ្នកកំពុងនិយាយផ្អាកសិន ដ្បិតបងប្អូនទាំងអស់គ្នាអាចអធិប្បាយម្នាក់ម្តងៗ ដើម្បីបានទទួលការអប់រំ និង ទទួលការលើកទឹកចិត្តគ្រប់ៗគ្នា ។ ព្រះអំណោយទានខាងការអធិប្បាយស្ថិតនៅក្រោមអំណាចរបស់អ្នកអធិប្បាយ" (១ កូរិនថូស ១៤:២៩-៣២) ។

## ៤. ការសាកល្បងប្រាំពីរយ៉ាងក្នុងការវិនិច្ឆ័យការថ្លែងទំនាយ

ក. តើការថ្លែងទំនាយនោះស្របតាមបទគម្ពីរដែររឺទេ ?

> "ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នាខុសពីដំណឹងល្អដែលយើងខ្ញុំបានប្រាប់ហើយ នោះអោយគេត្រូវបណ្តាសារចុះ" (កាឡាទី ១:៨) ។

ខ. តើអ្វីជាផលផ្លែនៅក្នុងជីវិតរបស់អ្នកថ្លែងទំនាយនោះ ?

> "ចូរប្រយ័ត្ននឹងពួកគ្រូក្លែងក្លាយ ដែលគេមកឯអ្នករាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់គេជាឆ្កែចចកដែលឆ្នក់ស៊ីវិញ ។ អ្នករាល់គ្នានឹងស្គាល់គេបានដោយសារផលគេបង្កើត" (ម៉ាថាយ ៧:១៥-១៦) ។

គ. តើការថ្លែងទំនាយនោះផ្តល់សេរីរុងរឿងដល់ព្រះជាម្ចាស់ដែរឬទេ ?

១.	"កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិត ។.......ទ្រង់នឹងតម្កើងខ្ញុំ ដ្បិតទ្រង់នឹងយកសេចក្តីដែលតំរូវពីខ្ញុំមកប្រាប់ដល់អ្នករាល់គ្នា" (យ៉ូហាន ១៦:១៣,១៤) ។

២.	"ដ្បិតការធ្វើបន្ទាល់ពីព្រះយេស៊ូ នោះហើយជាវិញ្ញាណនៃសេចក្តីទំនាយ" ( វិវរណៈ ១៩:១០)

ឃ. តើការថ្លែងទំនាយនោះបានសំរេចដែរទេ ?

"ប្រហែលជាអ្នកសួរថា តើធ្វើដូចម្តេចអោយដឹងថា ពាក្យណាមួយដែលមិនមែនមកពីព្រះជាម្ចាស់ ។ .ពេលព្យាការីម្នាក់ថ្លែងពាក្យក្នុងព្រះនាមរបស់ព្រះអម្ចាស់ តែមិនឃើញមានហេតុការណ៍អ្វីកើតឡើងដូចពាក្យគេប្រកាសទេ បានសេចក្តីថា ពាក្យនេះមិនមែនជាព្រះបន្ទូលរបស់ព្រះអម្ចាស់ទេ ។ ព្យាការីនេះហ៊ាននិយាយដោយចិត្តឯង........." (ចោទិយកថា ១៨:២១-២២) ។

ង. តើការថ្លែងទំនាយនោះដឹកនាំទៅរកព្រះជាម្ចាស់ រឺ ដឹកនាំអោយឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ?

"ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើមានព្យាការី ឬ គ្រូទាយឆុតណាម្នាក់ ប្រកាសអំពីទីសំគាល់ ឬ ឫទ្ធិបដិហារិយ៍អ្វីមួយ......អ្នកទៅជំពាក់ចិត្ត ឬ គោរពបំរើព្រះដទៃទៀត ដែលអ្នករាល់គ្នាពុំស្គាល់ កុំស្តាប់ពាក្យរបស់ព្យាការី ឬ គ្រូទាយឆុតនោះអោយសោះ......." (ចោទិយកថា ១៣:១,២,៣) ។

ច. តើការថ្លែងទំនាយនោះធ្វើអោយមានសេរីភាព ឬ ចំណង ?

"អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបំរើ អោយត្រូវភ័យខ្លាចទៀតឡើយ ...." (រ៉ូម ៨:១៥) ។

ឆ. តើអ្វីជាស្មបន្ទាល់ខាងក្នុងរបស់ព្រះវិញ្ញាណ ?

"រីឯអ្នករាល់គ្នាវិញ ព្រះដ៏បរិសុទ្ធបានចាក់ប្រេងមកលើអ្នករាល់គ្នា ហើយអ្នកក៏បានចេះដឹងទាំងអស់គ្នា" (១ យ៉ូហាន ២:២០) ។

ប្រសិនបើព្រះរាជសារនោះពិតះជាមកពីព្រះជាម្ចាស់មែន នោះប្រាកដជាមានស្មរបន្ទាល់ខាងក្នុងរបស់ព្រះវិញ្ញាណជាមិនខាន ។ ប្រសិនបើព្រះរាជសារនោះមិនបានបញ្ជាក់ពីអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលទៅកាន់វិញ្ញាណរបស់លោកអ្នកទេនោះ មុនពេលធ្វើសកម្មភាពអ្វីមួយ សូមរង់ចាំរហូតដល់សេចក្តីបញ្ជាក់បានមកដល់ ។ មិនត្រូវអនុញ្ញាតអោយនរណាម្នាក់ដែលអ្នកដឹកនាំខាងវិញ្ញាណរបស់លោកអ្នកមិនស្គាល់ថ្លែងទំនាយអំពីលោកអ្នកដោយមេដឹកនាំរបស់លោកអ្នកមិនបាននៅជាមួយលោកអ្នកដើម្បីនឹងវិនិច្ឆ័យការថ្លែងទំនាយនោះឡើយ ។

## ការសន្និដ្ឋាន"

**ការថ្លែងទំនាយ :**

សូមរង់ចាំរហូតដល់លោកអ្នកដឹងថា លោកអ្នកបានទទួលសេចក្តីទាំងនោះពីព្រះជាម្ចាស់ប្រាកដមែន ។ សូមរង់ចាំរហូតដល់ពេលកំណត់ដែលព្រះជាម្ចាស់អនុញ្ញាតអោយលោកអ្នកថ្លែងទំនាយ ។ សូមរង់ចាំរហូតដល់អ្នកដឹកនាំខាងវិញ្ញាណអាចវិនិច្ឆ័យការថ្លែងទំនាយនោះបាន ។ ចូរថ្លែងទំនាយជាភាសាធម្មតា ដែលគេប្រើក្នុងពេលបច្ចុប្បន្ននេះ ។ សូមជៀសវាងការប្រើអារម្មណ៍ហួសហេតុ និង ភាពច្រំដែល ។

"ព្រះអំណោយទានខាងការអធិប្បាយ ស្ថិតនៅក្រោមអំណាចរបស់អ្នកអធិប្បាយ" (១ កូរិនថូស ១៤: ៣២) ។

**ការស្អាងចិត្ត កំឡាចិត្ត និង កំសាន្តចិត្ត**

ដែលសំខាន់ជាងគេបំផុតនោះ សូមទទួលតែការថ្លែងទំនាយណាដែលប៉ះពាល់ដល់វិញ្ញាណរបស់លោកអ្នក ។ សូមចងចាំពាក្យរបស់លោកប៉ុលថា "ឯអ្នកដែលអធិប្បាយវិញ អ្នកនោះនិយាយនឹងមនុស្សសម្រាប់នឹងស្អាងចិត្ត កំឡាចិត្ត និង កំសាន្តចិត្ត" (១ កូរិនថូស ១៤:៣) ។

វាពិតជាអស្ចារ្យក្រៃលែងដែលព្រះជាម្ចាស់នៅតែមានបន្ទូលមកកាន់ប្រជារាស្ត្ររបស់ព្រះអង្គតាមរយៈអំណោយទានបញ្ចេញជាសំលេងរបស់ព្រះវិញ្ញាណបរិសុទ្ធ !

## ការពិភាក្សាជាក្រុម

១. ចូរបង្កើតជាក្រុមតូចៗ ហើយប្រើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដោយការនិយាយភាសាដទៃ ហើយអនុញ្ញាតអោយអ្នកដែលនិយាយនោះ ឬ អ្នកដទៃទៀតដែលស្ថិតនៅក្នុងក្រុមរបស់លោកអ្នកបកប្រែភាសាដទៃនោះ ។

២. ចំពោះអ្នកណាដែលមានព្រះរាជសារជាពាក្យទំនាយ គួរតែត្រូវបានលើកទឹកចិត្តអោយផ្តល់ព្រះរាជសារដល់ក្រុមតូចរបស់លោកអ្នក ។

## ការសិក្សាដោយខ្លួនឯង

១. ចូររៀបរាប់ពីគោលបំណងទាំងបីនៃការថ្លែងទំនាយនៅក្នុងការប្រជុំរបស់ក្រុមជំនុំដោយយោងតាម ១ កូរិនថូស ១៤:៣ ។

២. តើអ្នកណាជាអ្នកវិនិច្ឆ័យថា តើការថ្លែងទំនាយនោះមកពីព្រះជាម្ចាស់ ឬ មិនមែនមកពីព្រះជាម្ចាស់?

៣. យោងតាមអត្ថបទគម្ពីរខាងក្រោម ចូរសរសេរសេចក្តីណែនាំសម្រាប់ការប្រើអំណោយទានបញ្ចេញជាសំឡេងនៅក្នុងការប្រជុំរបស់ក្រុមជំនុំៈ

១ កូរិនថូស ១៤:២៧

១ កូរិនថូស ១៤:១៩,២៨

១ កូរិនថូស ១៤:៥

៤. យោងតាម ១ កូរិនថូស ១៤:១,៥,៣៩, តើអ្នកណាគួរតែនិយាយភាសាដទៃ បកប្រែភាសាដទៃ និងថ្លែងទំនាយ ?

៥. ចូរសរសេរសេចក្តីណែនាំដែលលោកអ្នកត្រូវតែគោរពតាម ប្រសិនបើលោកនឹងថ្លែងទំនាយ ?

# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី៤ : អំណោយទាននៃការបើកសម្តែង

## សេចក្តីផ្តើម

នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីអំណោយទាននៃការបើកសម្តែង ។ ព្រះជាម្ចាស់កំពុងមានព្រះបន្ទូល និង កំពុងបើកសម្តែងរឿងជាច្រើនដល់ប្រជារាស្ត្ររបស់ព្រះអង្គនាពេលបច្ចុប្បន្ននេះ ។

ព្រះជាម្ចាស់តែងតែប្រទានការបើកសម្តែងដល់ប្រជារាស្ត្ររបស់ព្រះអង្គតាមរយៈអំណោយទានមួយក្នុងចំណោម អំណោយទាននៃការបើកសម្តែងទាំងបីរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ អំណោយទាននៃការសង្កេតស្គាល់អស់ទាំងវិញ្ញាណ អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ និង អំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់គឺជាឧបករណ៍នៃព័ន្ធកិច្ចដ៏សំខាន់ដែលយើងត្រូវការក្នុងជីវិតប្រចាំថ្ងៃរបស់គ្រិស្តបរិស័ទ ។

## គំរោងមេរៀន

### ១. អំណោយទាននៃការសង្កេតស្គាល់អស់ទាំងវិញ្ញាណ

អំណោយទាននេះប្រហែលជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដែលយើងត្រូវការខ្លាំងបំផុត ប៉ុន្តែ យើងក៏ធ្វេសប្រហែសបំផុតដែរ ។ ព្រះយេស៊ូបានព្រមានថា "ដ្បិតនឹងមានមនុស្សក្លែងខ្លួនធ្វើជាព្រះគ្រិស្ត ព្រមទាំងមានព្យាការី ក្លែងក្លាយនាំគ្នាសំដែងទីសំគាល់ធំអស្ចារ្យ និង ឫទ្ធិបដិហារិយ៍ផ្សេងៗដើម្បីបញ្ឆោតមនុស្សរហូតដល់ទៅនាំពួកអ្នកដែលព្រះជាម្ចាស់បានជ្រើសរើសអោយវង្វេងថែមទៀតផងប្រសិនបើគេអាចធ្វើបាន"( ម៉ាថាយ ២៤:២៤) ។

គ្មានអ្វីអាចបញ្ឆោតយើងបានឡើយ ប្រសិនបើយើងរៀនប្រើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដ៏សំខាន់មួយនេះ ។

ពាក្យថា ការសង្កេតស្គាល់ (discerning) តែងតែត្រូវបានយល់ច្រលំជាមួយនឹងពាក្យថា ការសង្កេតស្គាល់ (discernment) ហើយអំណោយទាននេះត្រូវបានអ្នកខ្លះហៅដោយភាន់ច្រលំថា "អំណោយទាននៃការសង្កេតស្គាល់" ។ ការសង្កេតស្គាល់របស់មនុស្សគឺជាសកម្មភាពនៃគំនិត ឬ ជាផ្នែកមួយនៃព្រលឹង ។ ផ្ទុយទៅវិញ អំណោយទាននេះគឺជា អំណោយទានដ៏អស្ចារ្យដែលបានមកដោយសារការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធតាមរយៈព្រលឹងរបស់យើង ។

ភាសាក្រិកដែលត្រូវបានបកប្រែថា "ការសង្កេតស្គាល់" (discernment) មានន័យថា "ការញែកអោយដាច់ពីគ្នា" ។ ប្រហែលជាពាក្យដែលអាចពិពណ៌នាអំពីអំណោយទាននេះបានច្បាស់ជាងនេះគឺជាពាក្យថា "ការញែកអោយដាច់ពីគ្នារវាងវិញ្ញាណល្អ និង វិញ្ញាណអាក្រក់" ។

#### ក. និយមន័យនៃអំណោយទាននៃការសង្កេតស្គាល់

អំណោយទាននៃការញែកអោយដាច់ពីគ្នារវាងវិញ្ញាណល្អ និង វិញ្ញាណអាក្រក់ គឺជាការយល់ច្បាស់ដ៏អស្ចារ្យអំពីពិភពនៃវិញ្ញាណ ។ អំណោយទាននេះសម្តែងអោយឃើញពីវិញ្ញាណដែលស្ថិតនៅពីក្រោយ

មនុស្ស ស្ថានភាព សកម្មភាព ឬ ព្រះរាជសារណាមួយ ។ អំណោយទាននេះគឺជាការយល់ច្បាស់នៅក្នុងវិញ្ញាណរបស់លោកអ្នកដែលកើតឡើងដោយសារការបើកសម្តែងដ៏អស្ចារ្យស្តីអំពីប្រភព និស្ស័យ នឹងសកម្មភាពរបស់វិញ្ញាណណាមួយ ។

អំណោយទាននេះនឹងញែកអោយដាច់ពីគ្នា និង កំណត់អត្តសញ្ញាណរបស់វិញ្ញាណ ។ តាមរយៈការប្រើអំណោយទាននេះ យើងនឹងអាចកំណត់អត្តសញ្ញាណ :

១. ព្រះវត្តមានរបស់ព្រះជាម្ចាស់
២. ព្រះវត្តមាន និង មុខងាររបស់ព្រះវិញ្ញាណបរិសុទ្ធ
៣. វត្តមាន និង មុខងាររបស់ទេវតាបរិសុទ្ធ
៤. និស្ស័យរបស់វិញ្ញាណមនុស្ស
៥. វត្តមានរបស់មារសាតាំង
៦. វត្តមាន និង មុខងាររបស់វិញ្ញាណអាក្រក់

ខ. គោលបំណងនៃអំណោយទាននៃការសង្កេតស្គាល់

១. ប្រជារាស្ត្របរិសុទ្ធដែលជាប់ចំណងនឹងត្រូវបានដោះលែង
២. គំរោងការរបស់មារសាតាំងនឹងត្រូវបានគេស្គាល់
៣. ការពារប្រជាជនបរិសុទ្ធពីអំពើបាប
៤. អាចស្គាល់ការបើកសម្តែងក្លែងក្លាយ

គ. វិញ្ញាណបោកបញ្ឆោត

១. "តែព្រះវិញ្ញាណ ទ្រង់មានបន្ទូលយ៉ាងជាក់ច្បាស់ថា នៅគ្រាជាន់ក្រោយបង្អស់ អ្នកខ្លះនឹងលាចាកចេញពីសេចក្តីជំនឿ ដោយស្តាប់តាមវិញ្ញាណបញ្ឆោត និង សេចក្តីបង្រៀនរបស់ពួកអារក្ស ដោយសារពុតមាយារបស់ពួកអ្នកដែលពោលតែពាក្យកុហក ទាំងមានបញ្ញាចិត្តរលាក" (១ ធីម៉ូថេ ៤:១-២) ។

២. "ហើយពួកអាក្រក់ និង ពួកឆបោក គេនឹងមានជំនឿនជឿនទៅខាងសេចក្តីអាក្រក់កាន់តែខ្លាំងឡើង ទាំងនាំមនុស្សអោយវង្វេង ហើយត្រូវវង្វេងខ្លួនឯងផង" (២ធីម៉ូថេ ៣:១៣) ។

ឃ. ការល្បួងលវិញ្ញាណ

ង. វិញ្ញាណនៃសេចក្តីពិត និង វិញ្ញាណនៃកំហុសឆ្គង

## ២. មារសាតាំង ទេវតានៃពន្លឺ និង ពួកសាវ័កក្លែងក្លាយរបស់វា

លោកប៉ុលបានព្រមានថា "ដ្បិតមនុស្សយ៉ាងនោះជាសាវ័កក្លែងក្លាយ ជាអ្នកឆបោកដែលក្លែងខ្លួនធ្វើជាសាវ័កនៃព្រះគ្រិស្តទេ ហើយសេចក្តីនោះមិនជាការអស្ចារ្យឡើយ ព្រោះអារក្សសាតាំងក៏ក្លែងខ្លួនធ្វើជាទេវតានៃពន្លឺដែរ ដូច្នេះ បើអ្នកបំរើរបស់វាក្លែងខ្លួនធ្វើជាអ្នកបំរើសេចក្តីសុចរិតវិញ នោះមិនមែនជាការធំអ្វីទេ ឯចុងបំផុតរបស់គេនឹងបានត្រូវតាមអំពើដែលគេធ្វើដែរ" (២កូរិនថូស ១១:១៣-១៥) ។

ក.	ឧទាហរណ៍ : ស្ត្រីបំរើដែលធ្វើជាគ្រូទាយ

នៅពេលស្ត្រីបំរើជាគ្រូទាយបានដើរតាមលោកប៉ុល ទាំងនិយាយល្អជាច្រើនពីលោក លោកបានប្រើអំណោយទាននៃការញែកអោយដាច់ពីគ្នារវាងវិញ្ញាណល្អ និង វិញ្ញាណអាក្រក់ ហើយបានដឹងថាមាន "វិញ្ញាណនៃការទស្សទាយ" សណ្ឋិតនៅក្នុងខ្លួននាង ។ លោកបានបែរទៅនិយាយនឹងវិញ្ញាណនោះថា "អញបង្គាប់ឯងដោយនូវព្រះនាមព្រះយេស៊ូគ្រីស្ទអោយឯងចេញពីនាងនេះទៅ" (កិច្ចការ ១៦:១៦-១៨) ។

ខ.	ការដេញអារក្សចេញ

ព្រះយេស៊ូបានមានបន្ទូលថា យើង ដែលជាអ្នកជឿ គួរដេញអារក្សចេញ (ម៉ាកុស ១៦:១៧) ។ យោងតាម លូកា ១០:១៩-២០ ព្រះយេស៊ូបានប្រទានសិទ្ធិអំណាចដល់យើងដើម្បីអោយយើងជាន់លើពស់ ខ្យាដំរី និង ឈ្នះលើគ្រប់ទាំងអំណាចរបស់ខ្មាំងសត្រូវ តាមរយៈសិទ្ធិអំណាចនេះ គ្មានអ្វីអាចយាយីយើងបានឡើយ ។

## ៣.	អំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់

អំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់នេះគឺជាការបើកសម្តែងដ៏អស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធស្តីអំពី ហេតុការណ៍ បច្ចុប្បន្នកាល និង អតីតកាលរបស់មនុស្ស រឺ ស្ថានការណ៍ណាមួយ ដែលគំនិតធម្មតារបស់យើងមិនអាចស្វែងយល់បាន ។ ចំណេះចេះស្ទាត់នេះចូលមកក្នុងគំនិតរបស់យើងតាមរយៈវិញ្ញាណរបស់យើង ។ ចំណេះចេះស្ទាត់នេះតែងតែរារាំងរំខានដល់គំនិតធម្មតារបស់យើង ។ ចំណេះចេះស្ទាត់នេះចូលមកក្នុងទំរង់ជាគំនិត ពាក្យសំដី ឈ្មោះ អារម្មណ៍ និមិត្ត រឺ ជា "ការយល់ដឹងផ្នែកខាងក្នុង" ។ សូម្បីតែជាពាក្យដែលជាផ្នែកតូចមួយនៃប្រយោគក៏ដោយ ក៏ពាក្យសំដីនៃចំណេះចេះស្ទាត់ គឺជាផ្នែកតូចមួយនៃចំណេះដឹងដែលមកពីព្រះជាម្ចាស់ទាក់ទងនឹងស្ថានភាពនោះដែរ ។

ក.	គោលបំណងនៃអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់

"ការចេះដឹង" ដ៏អស្ចារ្យនេះ ពេលត្រូវបានបើកសម្តែងដល់ពួកអ្នកជឿ នឹងជួយដល់ពួកគេក្នុងការធ្វើអោយកាន់តែប្រសើរឡើងនូវគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ។ ការចេះដឹងនេះនឹងផ្តល់សិរីរុងរឿងដល់ព្រះជាម្ចាស់ មិនមែនមនុស្សទេ ។ ការចេះដឹងនេះនឹងជួយយើងអោយបំពេញពន្ធកិច្ចប្រកបដោយប្រសិទ្ធិភាព និង ភាពច្បាស់លាស់ ។ ការចេះដឹងនេះព្រមានយើងពីគ្រោះថ្នាក់ ផ្តល់ការលើកទឹកចិត្ត បើកបង្ហាញពីអំពើបាប និង ជួយអោយយើងមានជ័យជំនះក្នុងជីវិត និងពន្ធកិច្ចជាប្រចាំថ្ងៃរបស់យើង ។

ខ.	ព្រះយេស៊ូបានប្រើអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ (យ៉ូហាន ៥:១៩-២០)

១.	តើយើងអាចធ្វើកិច្ចការដែលអស្ចារ្យជាងព្រះយេស៊ូដោយរបៀបណា ?

២.	គន្លឹះដើម្បីធ្វើដូច្នេះបានគឺគ្រាន់តែរៀនប្រើអំណោយទាននៃការបើកសំម្តែង ។

គ. គំរូរបស់លោកប៉ុល

១. លោកប៉ុលបានប្រើអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ នៅពេលលោកបានឃើញដោយនូវវិញ្ញាណថាបុរសពិការជើងដែលនៅក្នុងក្រុងលីស្ត្រាមានសេចក្តីជំនឿគួរនឹងបានជា ។

២. "ប៉ុលក៏សំឡឹងមើលទៅគាត់ ឃើញថា គាត់មានសេចក្តីជំនឿល្មមដើម្បីអោយបានជា នោះក៏បន្លឺជាសម្លេងខ្លាំងថា ចូរក្រោកឈរអោយត្រង់ឡើង រួចអ្នកនោះក៏ស្ទុះឡើងដើរ" (កិច្ចការ ១៤:៩-១០) ។

៣. ពាក្យសំដីនៃចំណេះចេះស្ទាត់ស្តីអំពីបុគ្គលណាម្នាក់តែងកើតមាននៅក្នុងខ្លួនយើង នៅពេលយើងមើលទៅភ្នែករបស់គេ រឺ ប៉ះពាល់គេ ។ គន្លឹះចំបងគឺត្រូវរៀនស្តាប់ព្រះវិញ្ញាណបរិសុទ្ធ ហើយត្រូវជឿថា អំណោយទាននេះនឹងធ្វើការ ។

## ៤. អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ

អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ គឺជាការបើកសំដែងដ៏អស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធ ដោយផ្តល់អោយអ្នកជឿនូវប្រាជ្ញាដែលមកពីព្រះជាម្ចាស់ដើម្បីបន្តធ្វើសកម្មភាពអ្វីមួយដោយផ្អែកទៅលើចំណេះធម្មតា រឺ ចំណេះដឹងដ៏អស្ចារ្យ ។ អំណោយទាននេះនឹងបើកសម្តែងពីផែនការរបស់ព្រះជាម្ចាស់សម្រាប់ជីវិត និង ព័ន្ធកិច្ចរបស់យើង ។ អំណោយទាននេះបង្ហាញអោយឃើញថា តើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មួយណាដែលយើងត្រូវតែធ្វើនៅក្នុងពេលឥឡូវនេះ ក្នុងពេលបន្តិចទៀតនេះ និង ក្នុងពេលអនាគតដ៏ឆាប់ ឬ ដ៏យូរខាងមុខ ។ អំណោយទាននេះសំដែងពីអ្វីដែលមនុស្សម្នាក់ៗ រឺ មនុស្សទាំងអស់ដែលនៅក្នុងការប្រជុំត្រូវធ្វើ និង ពីរបៀបដើម្បីបំពេញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃតែងធ្វើការ និង ហូរជាមួយនឹងអំណោយទាននៃពាក្យសំដីនៃចំណេះ ចេះស្ទាត់ ។

ក. អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃមិនមែនជាអំណោយទានធម្មតានៃប្រាជ្ញានោះទេ។ អំណោយទាននេះគឺជាពាក្យ រឺ ជាឃ្លាមួយ ។ អំណោយទាននេះគឺជាផ្នែកមួយតែប៉ុណ្ណោះ មិនមែនទាំងមូលនោះទេ ។ លោកប៉ុលបានសរសេរថា "សព្វថ្ងៃនេះ យើងចេះដឹងត្រឹមតែមួយផ្នែកប៉ុណ្ណោះ ហើយយើងក៏អធិប្បាយបានត្រឹមតែមួយផ្នែកប៉ុណ្ណោះដែរ" (១ កូរិនថូស ១៣:៩) ។

ដូចគ្នាទៅនឹងអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ដែរ អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃនេះតែងតែរារាំងរំខានដល់គំនិតធម្មតារបស់យើង នៅពេលពាក្យសំដីនៃប្រាជ្ញាវាងវៃនេះចូលមកតាមរយៈវិញ្ញាណរបស់យើង ។ អំណោយទាននេះ នឹងមកក្នុងទំរង់ជាអារម្មណ៍ ឬ និម្មិត្ត ដែលក្នុងអារម្មណ៍ ឬ និម្មិត្តនោះ យើងនឹងឃើញខ្លួនយើងធ្វើរឿងអ្វីមួយតាមរបៀបណាមួយ មុនពេលដែលយើងធ្វើរឿងនោះជាក់ស្តែង ។

ខ. អំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ និង អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃធ្វើការដោយមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និត ។ ជួនកាលធ្វើអោយយើងលំបាកនៅក្នុងការញែកអោយដាច់ពីគ្នា ។ អំណោយទានមួយបើកសម្តែងពីហេតុការណ៍អ្វីមួយ ហើយអំណោយទានមួយទៀតផ្តល់នូវប្រាជ្ញាស្តីអំពី អ្វីដែលយើងត្រូវធ្វើទាក់ទងនឹងហេតុការនោះ ។

១. គំរូរបស់ព្រះយេស៊ូ: នៅពេលព្រះយេស៊ូកំពុងបំពេញពន្ធ័កិច្ចចំពោះស្ត្រីម្នាក់ដែលនៅក្បែរអណ្តូង

ទឹកព្រះអង្គបានត្រាស់ដឹងដោយព្រោះអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ថាស្ត្រីនោះមានប្ដីដល់ទៅប្រាំនាក់ ហើយបុរសដែលនាងកំពុងរស់នៅជាមួយក្នុងពេលបច្ចុប្បន្ននេះមិនមែនជាប្ដីរបស់នាងទេ ។ គំនិតធម្មតាពិតជានឹងជំរុញអោយយើងគប់ដុំថ្មសម្លាប់នាងជាមិនខាន ប៉ុន្តែព្រះយេស៊ូក៏បានទទួលអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃផងដែរស្ដីអំពីរបៀបដោះស្រាយជាមួយនឹងស្ត្រីនោះដើម្បីអោយនាង និង អ្នកដទៃទៀតអាចត្រូវបានសង្គ្រោះ (យ៉ូហាន ៤:១៩-២៩) ។

២. នៅពេលព្រះយេស៊ូបានទទួលដំណឹងថា ឡាសារដែលជាមិត្តរបស់ព្រះអង្គមានជំងឺ ព្រះអង្គបានដឹងតាមរយៈអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ថា លោកឡាសារបានស្លាប់បាត់ទៅហើយ ។ ប៉ុន្តែ ព្រះអង្គក៏បានដឹងតាមរយៈព្រះអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃផងដែរថា "ជំងឺនេះមិនមែនដល់ស្លាប់ទេ គឺសំរាប់ជាកិត្តិសព្ទដល់ព្រះវិញដើម្បីនឹងលើកដំកើងដល់ព្រះរាជបុត្រានៃព្រះដោយសារជំងឺនេះឯង" (យ៉ូហាន ១១:៤) ។ បន្ទាប់មក នៅក្នុងខ១៤ ព្រះអង្គមានបន្ទូលយ៉ាងច្បាស់ទៅកាន់ពួកគេថា "ឡាសារស្លាប់ហើយ" ។

   ក. ព្រះយេស៊ូបានត្រាស់ដឹងពីអ្វីដែលត្រូវធ្វើ និង អ្វីដែលត្រូវមានព្រះបន្ទូលដោយសារអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ ។
   ខ. ព្រះអង្គបានដឹងថា ព្រះអង្គត្រូវពន្យាពេលក្នុងការធ្វើដំណើរទៅកាន់ភូមិបេថានី (ដើម្បីប្រោសឡាសារអោយរស់ពីស្លាប់ឡើងវិញ) រយៈពេល៤ថ្ងៃ ហើយព្រះអង្គបានមានបន្ទូលទៅកាន់ម៉ាថាថា "ប្អូននាងនឹងរស់ឡើងវិញ" (យ៉ូហាន ១១:២៣) ។

៣. គំរូរបស់លោកពេត្រុស និង អ្នកដទៃទៀត

   ក. លោកពេត្រុសបានរៀបចំចេញដំណើរទៅកាន់ផ្ទះរបស់លោកកូនេលាស បើទោះបីជាលោកជាសាសដទៃក៏ដោយ ព្រោះលោកបានទទួលអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ដែលបានចូលមកក្នុងទំរង់ជានិមិត្តនៅពេលលោកកំពុងស្នាក់នៅលើដំបូលផ្ទះរបស់ជាងសំឡាប់ស្បែកម្នាក់ឈ្មោះ ស៊ីម៉ូនក្នុងភូមិយ៉ុបប៉េ ។

   ខ. លោកបានទទួលអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់មួយទៀត នៅពេលព្រះវិញ្ញាណមានបន្ទូលទៅកាន់លោកថា "មើលមានមនុស្សបីនាក់មករកអ្នក......" ការបើកសម្ដែងនេះបានបន្តជាពាក្យសំដីនៃប្រាជ្ញាវាងវៃថា "ចូរក្រោកឡើងចុះទៅ ហើយទៅជាមួយនឹងគេចុះ កុំប្រកាន់គេឡើយ ពីព្រោះគឺខ្ញុំហើយ ដែលចាត់អោយគេមក" (កិច្ចការ ១០:១៩-២០) ។

   គ. តាមរយៈអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ លោកអាណាញ៉ាសត្រូវបានបញ្ជូនអោយដើរទៅត្រង់ឆ្ពោះទៅរកផ្ទះរបស់បុរសម្នាក់ឈ្មោះយូដា ដើម្បីដាក់ដៃលើលោកប៉ុល ។ លោកអាកាប៊ូសត្រូវបានព្រមានអោយដឹងពីគ្រោះទុរ្ភិក្សដែលនឹងកើតឡើងក្នុងពេល ខាងមុខ និង ការឃុំឃាំងរបស់លោកប៉ុល ។ លោកប៉ុលត្រូវបានព្រមានអោយដឹងពីព្យុះ និង ការលិចទូក ។

គ. អំណោយទាននៃការបើកសម្ដែងរៀបចំខ្លួនយើងសំរាប់ព័ន្ធកិច្ចដែលប្រកបដោយប្រសិទ្ធិភាព ។ អំណោយទានទាំងនេះនឹងរៀបចំខ្លួនយើងសម្រាប់រឿងរ៉ាវដែលនឹងកើតឡើង ហើយក៏នឹងជួយសង្គ្រោះយើងផងដែរ ។

- នៅក្នុងមេរៀនដែលនិយាយអំពីអំណោយទាននៃអំណាច យើងនឹងឃើញពីរបៀបដែលអំណោយទាននៃការបើកសម្តែងបើកអោយមានអំណោយទាននៃសេចក្តីជំនឿ និង ការធ្វើការអស្ចារ្យ ហើយនិងពីរបៀបដែលអំណោយទានទាំងនេះធ្វើការរួមគ្នានៅក្នុងអំណោយទាននៃការប្រោសអោយជា។

## ការពិភាក្សាជាក្រុម

១. ចូរពិភាក្សាពីលក្ខណៈនៃវិញ្ញាណផ្សេងៗដែលមានដំណើរការនៅក្នុងស្ថានភាព រឺ ការប្រជុំអ្វីណាមួយ និង ពិភាក្សាអំពីរបៀបដែលយើងអាចញែកវិញ្ញាណទាំងនោះចេញពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ។ ចូរអោយជាឧទាហរណ៍ខ្លះៗ ។

២. នៅពេលយើងដឹងថា មានវិញ្ញាណអាក្រក់កំពុងធ្វើការនៅក្នុងស្ថានភាពអ្វីមួយ តើយើងត្រូវដោះស្រាយជាមួយវិញ្ញាញនោះដោយវិធីណា ?

៣. តើអ្នកជឿលើព្រះគ្រិស្ទអាចធ្វើការអស្ចារ្យជាងព្រះគ្រិស្ទបានដោយរបៀបណា បើយោងតាមយ៉ូហាន ១៤:១២ ?

៤. តើអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃធ្វើការជាមួយនឹងអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ដោយរបៀបណាទៅ ?

## ការសិក្សាដោយខ្លួនឯង

ចូរសិក្សាបទគម្ពីរខាងក្រោម ហើយសង្ខេបពីអំណោយទានដែលធ្វើការនៅក្នុងអត្ថបទគម្ពីរនិមួយៗ និង ប្រាប់ពីរបៀបដែលអំណោយទានទាំងនោះមានទំនាក់ទំនងរវាងគ្នានឹងគ្នា ។

យ៉ូហាន ៤:៥-២៦

កិច្ចការ ១០:១-២៣

កិច្ចការ ១៤:៦-១៨

# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី៥ : អំណោយទាននៃអំណាច

## សេចក្តីផ្តើម

អំណោយទាននៃអំណាច គឺជាការបង្ហាញពីអំណាចរបស់ព្រះជាម្ចាស់ដែលធ្វើការតាមរយៈយើង តាមរយៈអំណោយនៃជំនឿ អំណោយទាននៃការធ្វើការអស្ចារ្យ និង អំណោយទាននៃការប្រោសអោយជា ។

អំណោយទានបញ្ចេញជាសម្លេង និង អំណោយទាននៃអំណាចធ្វើការយ៉ាងជិតស្និតជាមួយនឹងអំណោយទាននៃការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធនៅពេលដែលអំណោយទានទាំងនេះហូរ និង ធ្វើការជាមួយគ្នាទៅវិញទៅមក ។ ដោយហេតុផលទាំងនេះ ទើបវាមានសារៈសំខាន់សំរាប់អ្នកជឿគ្រប់គ្នាក្នុងការហ្វឹកហាត់ និង ជំរុញលើកទឹកចិត្តអោយប្រើអំណោយទានទាំងប្រាំបួនរបស់វិញ្ញាណបរិសុទ្ធ ។

## គំរោងមេរៀន

## ១. អំណោយទាននៃសេចក្តីជំនឿ

អំណោយទាននៃសេចក្តីជំនឿគឺជាសេចក្តីជំនឿដ៏អស្ចារ្យមួយក្នុងពេលវេលា និង គោលបំណងដែលជាក់លាក់ណាមួយ ។ នេះគឺជាអំណោយទាននៃអំណាចដើម្បីសំរេចអោយបាននូវកិច្ចការណាមួយ ក្នុងស្ថានភាពណាមួយដែលលោកអ្នកស្ថិតនៅ និង ក្នុងពេលវេលាច្បាស់លាស់ណាមួយ ។

អំណោយទាននេះត្រូវបានប្រទានអោយភ្លាមៗ ឬ ក្នុងពេលអនាគតដ៏ឆាប់ នៅពេលយើងត្រូវការអំណោយទាននេះសម្រាប់កិច្ចការជាក់លាក់ណាមួយ ។ នៅពេលអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃត្រូវបានប្រទានអោយតាមរយៈការប្រាប់យើងពីរបៀបដែលកិច្ចការណាមួយគួរត្រូវបានបំពេញ អំណោយទាននេះនឹងបង្កើតអោយមានអំណោយទាននៃសេចក្តីជំនឿដើម្បីអោយយើងប្រើអំណោយទានដោយក្លាហាន ស្របតាមអ្វីដែលព្រះជាម្ចាស់បានរៀបចំផែនការសម្រាប់យើង ។

ក. ការទទួលអំណោយទាននៃសេចក្តីជំនឿ

អំណោយទាននេះត្រូវបានទទួលតាមរយៈការប្រើអំណោយទាននៃការបើកសម្តែង ។ អ្នកជឿនឹងមានសេចក្តីជំនឿដ៏អស្ចារ្យ នៅពេលអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាបើកសម្តែងពីអំណាចរបស់ព្រះជាម្ចាស់ ។ អំណោយទាននេះបើកអោយយើងអនុវត្តការបើកសម្តែងដែលយើងទើបនឹងទទួលបាននោះដោយក្លាហាន ។

ខ. អំណោយទាននៃសេចក្តីជំនឿត្រូវបានបង្ហាញ

ជារឿយៗ អំណោយទាននៃសេចក្តីជំនឿជាប់ទាក់ទងនឹងការប្រើអំណោយទាននៃការធ្វើការអស្ចារ្យ និង អំណោយទាននៃការប្រោសអោយជា ។ អំណោយទាននេះអាចត្រូវបានសម្តែងតាមរយៈការ

បញ្ញាដ៏មានអំណាច ។ ព្រះយេស៊ូមានបន្ទូលទៅកាន់ខ្យល់ព្យុះថា "ចូរស្ងប់ ហើយនៅស្ងៀមទៅ !" ព្រះអង្គមានបន្ទូលដោយខ្លាំងៗទៅកាន់ផ្នូររបស់មិត្តព្រះអង្គថា "ឡាសារអើយ ! ចេញមក!" ។

ពេលទទួលបានការបើកសម្តែងពីអ្វីដែលព្រះជាម្ចាស់ចង់ធ្វើតាមរយៈអំណោយទាននៃពាក្យសំដីនៃប្រាជ្ញា អ្នកជឿនឹងទទួលបានអំណោយទាននៃសេចក្តីជំនឿដើម្បីបញ្ចប់កិច្ចការដែលមាន ។ សេចក្តីជំនឿដ៏ពិសេសនេះត្រូវបានបើកសម្តែងនៅពេលគំរោងការស្តីអំពីរបៀបដំណើរការត្រូវបានបើកសម្តែងតាមរយៈអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ ។ អំណោយទាននេះបើកអោយអ្នកជឿប្រព្រឹត្តតាមអ្វីដែលព្រះជាម្ចាស់ប្រទានអោយពួកគេដោយក្លាហាន ។ នៅពេលអំណោយទាននៃសេចក្តីជំនឿកើតឡើង យើងមិនត្រូវជឿលើការតស៊ូណាមួយនោះឡើយ ។ យើងស្គាល់ពីអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់មានបន្ទូល ហើយយើងស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះអង្គទាក់ទងនឹងស្ថានភាពនេះ ។ យើងដឹងថាអំណាចរបស់ព្រះជាម្ចាស់ដែលសណ្ឋិតនៅក្នុងខ្លួនយើងរៀបតែនឹងសំដែងចេញមកក្រៅតាមរយៈការបើកបង្ហាញនៃអំណាចនោះ ។ យើងនិយាយដោយក្លាហាន និង បើកបង្ហាញពីអំណោយទានដ៏អស្ចារ្យនេះតាម រយៈការធ្វើការអស្ចារ្យ រឺ តាមរយៈអំណោយទាននៃការប្រោសអោយជា ។

គ. អំណោយទាននៃសេចក្តីជំនឿបើកអោយមានសេចក្តីក្លាហាន

ជារើយៗ អំណោយទាននៃសេចក្តីជំនឿនឹងអនុញ្ញាតអោយយើងធ្វើការប្រកាសដ៏ក្លាហានតាមរយៈការបើកសម្តែងដ៏អស្ចារ្យ ។

១. ព្រះយេស៊ូមានបន្ទូលទៅកាន់ដើមល្វាថា "កុំអោយឯងមានផ្លែទៀតឡើយ" (ម៉ាថាយ ២១:១៩) ។

២. លោកពេត្រុសមានប្រសាសន៍ទៅកាន់សាភីរ៉ាថា ".....ពួកអ្នកដែលកប់ខ្មោចប្តីអ្នក គេមកដល់មាត់ទ្វារហើយ គេនឹងសែងអ្នកយកទៅដែរ នោះស្រាប់តែនាងដួលដាច់ខ្យល់មួយរំពេច" (កិច្ចការ ៥:៩-១១) ។

៣. លោកប៉ុលមានប្រសាសន៍ទៅកាន់អេលីម៉ាសដែលជាគ្រូអាបធ្មប់នោះថា "នែ មនុស្សដែលពេញដោយកិច្ចកល និង សេចក្តីល្បិចគ្រប់យ៉ាង ជាកូននៃអារក្ស ហើយជាខ្មាំងសត្រូវដល់គ្រប់ទាំងសេចក្តីសុចរិតអើយ តើមិនព្រមឈប់បង្ខូចផ្លូវត្រង់របស់ព្រះជាម្ចាស់ទេឬអី មើលឥឡូវនេះ ព្រះហស្តនៃព្រះអម្ចាស់បានមកលើឯងហើយ ឯងនឹងត្រូវខ្វាក់ភ្នែក មើលមិនឃើញពន្លឺថ្ងៃជាយូរបន្តិច ។ នោះស្រាប់តែភ្នែករបស់គ្រូនោះបានទៅជាព្រិលៗ ហើយងងឹតសូន្យទៅ រួចក៏ដើរវិលវល់រកអ្នកណាអោយដឹកដៃ" (កិច្ចការ ១៣:១០-១១) ។

៤. គំរូរបស់ស្តេចដាវីឌ និង កូលីយ៉ាត

ក. យុវជនដាវីឌបានទទួលអំណោយទាននៃពាក្យសំដីនៃប្រាជ្ញា ដែលបើកអោយមានអំណោយទាននៃសេចក្តីជំនឿនៅពេលប្រឈមមុខជាមួយនឹងទាហានមាឌធំកូលីយ៉ាត ។ យុវជនដាវីឌទូលស្តេចសូលទាំងក្លាហានថា "សូមកុំអោយអ្នកណាស្លុតចិត្តដោយព្រោះវាឡើយ ទូលបង្គំជាបាវបំរើរបស់ទ្រង់នឹងសូមចេញទៅតយុទ្ធនឹងសាសន៍ភីលីស្ទីននោះ (១ សាមូអែល ១៧:៣២) ។

ខ. ដាវីឌឆ្លើយទៅវិញថា "ចំណែកឯងបានមកឯអញទាំងកាន់ដាវ កាន់លំពែង ហើយនឹងដែកពួយផង តែអញវិញ អញមកឯងដោយនូវព្រះនាមរបស់ព្រះយេហូវ៉ានៃពួកបរិវារគឺជាព្រះនៃពួកពលសាសន៍អ៊ីស្រាអែលដែលឯងបានប្រកួតនឹងគេនោះ" ។

គ. "នៅថ្ងៃនេះ ព្រះយេហូវ៉ានឹងប្រគល់ឯងមកក្នុងកណ្តាប់ដៃអញហើយ អញនឹងវាយឯង ហើយនឹងកាត់យកក្បាលឯងទៅ..." (១ សាមូអែល ១៧:៤៥-៤៦) ។

៥. គំរូនៃគុកភ្លើង (ដានីយ៉ែល ៣:១៦-១៨) ។

## ២. អំណោយទាននៃការធ្វើការអស្ចារ្យ

ការធ្វើការអស្ចារ្យគឺជាការធ្វើអន្តរាគមន៍ដ៏អស្ចារ្យចូលទៅក្នុងធម្មជាតិ ។ ការធ្វើការអស្ចារ្យនេះគឺជាការបង្ហាញពីអំណាចរបស់ព្រះជាម្ចាស់ ដែលតាមរយៈអំណាចនេះ ច្បាប់នៃធម្មជាតិនឹងត្រូវបានផ្លាស់ប្តូរ ពន្យាពេល ឬ គ្រប់គ្រង ។

ក. ដំណើរការនៃការធ្វើការអស្ចារ្យ

១. ការធ្វើការអស្ចារ្យចាប់ផ្តើមឡើងជាមួយនឹងចំណេះដឹងដែលយើងទទួលបានតាមរយៈអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ ។ បន្ទាប់មក យើងទទួលបានអំណោយទាននៃពាក្យសំដីនៃប្រាជ្ញា ដែលតាមរយៈអំណោយទាននេះយើងនឹងឃើញថា ខ្លួនយើងនឹងធ្វើការអស្ចារ្យមួយមុនពេលដែលការអស្ចារ្យនោះកើតឡើង ។ អំណោយទាននៃសេចក្តីជំនឿត្រូវបានបង្ហាញ ហើយយើងចាប់ផ្តើមធ្វើអ្វីដែលយើងឃើញថាខ្លួនយើងបានធ្វើនៅពេលដែលយើងទទួលបានអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាដោយក្លាហាន ។

២. អំណោយទាននេះត្រូវបានហៅថា "ការធ្វើការអស្ចារ្យ" ព្រោះយើងគឺជាអ្នករួមចំណែកដ៏សកម្មនៅក្នុងរឿងអស្ចារ្យនោះ ។ អ្វីដែលយើងបាន"ឃើញ"ថា ខ្លួនយើងបានធ្វើតាមរយៈអំណោយទាននៃពាក្យសំដីនៃប្រាជ្ញា ដែលអំណោយទាននេះបើកអោយមានអំណោយទាននៃសេចក្តីជំនឿ យើងនឹងចាប់ផ្តើម"សំរេច"អោយបានដោយក្លាហាន នៅពេលយើងបំពេញព័ន្ធកិច្ចក្នុងស្ថានភាពនោះ ។

ខ. មានភាពងាយស្រួលក្នុងការធ្វើការអស្ចារ្យ

នៅពេលដែលការកើតឡើងត១ក្នាដ៏ឆាប់រហ័ស និង ងាយស្រួលនៃអំណោយទានរបស់ព្រះវិញ្ញាណបរិសុទ្ធមានដំណើរការ យើងរកឃើញថា ការប្រើអំណោយទាននៃការធ្វើការអស្ចារ្យគឺមានភាពងាយស្រួលដូចការថ្លែងព្រះរាជសារជាភាសាដទៃ និង ការប្រើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដទៃទៀតដែរ ។

គ. គំរូរបស់លោកម៉ូសេ (និក្ខមនំ ៧:៩, ១៤:១៣-១៦)

ឃ. គំរូរបស់លោកអេលីយ៉ា និង លោកអេលីសេដែលញែកទន្លេយ័រដាន់ (២ពង្សាវតាក្សត្រ ២:៨, ១៣-១៤)

ង.	ការអស្ចារ្យផ្សេងៗរបស់ព្រះយេស៊ូ

១.	ការអស្ចារ្យដំបូងដែលព្រះយេស៊ូបានធ្វើគឺនៅភូមិកាណា ជាកន្លែងដែលព្រះអង្គបានធ្វើអោយទឹកក្លាយទៅជាស្រាទំពាំងបាយជូរ ។ មុនពេលដែលព្រះយេស៊ូប្រាប់អោយអ្នកបំរើចាក់ទឹកអោយពេញពាង អ្នកបំរើបានទទួលការបញ្ជាពីម៉ារី ដែលជាម្តាយរបស់ព្រះយេស៊ូថា "ការអ្វីដែលលោកប្រាប់អោយធ្វើ នោះត្រូវធ្វើចុះ" (យ៉ូហាន ២:៥) ។

២.	បើយើងនឹងប្រើអំណោយទាននៃការធ្វើការអស្ចារ្យ ដំបូងយើងត្រូវស្តាប់ឮព្រះអង្គមានបន្ទូលសិន បន្ទាប់មកគ្រាន់តែស្តាប់តាមអ្វីដែលព្រះអង្គមានបន្ទូលប៉ុណ្ណោះ ។ ការធ្វើការអស្ចារ្យគឺជាការប្រតិបត្តិតាមអ្វីដែលយើងបានឮពីព្រះជាម្ចាស់ ។

៣.	តាមរយៈអំណោយទាននៃការធ្វើការអស្ចារ្យ ព្រះយេស៊ូបានប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់អោយរស់ពីស្លាប់ឡើងវិញ ដើរនៅលើទឹក ផ្តល់អាហារដល់មនុស្សបួនពាន់អ្នកដោយប្រើនំប៉ុងប្រាំពីរដុំ និង ត្រីពីរបីកន្ទុយ ។

៤.	នៅពេលព្រះយេស៊ូប្រោសឡាសាអោយរស់ពីស្លាប់ឡើងវិញ ដំបូងព្រះអង្គបានទទួលអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ដែលធ្វើអោយព្រះអង្គជ្រាបថា ឡាសាបានស្លាប់ហើយ ។ បន្ទាប់មក ព្រះអង្គបានទទួលអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាដែលប្រាប់ព្រះអង្គពីពេលវេលា និង របៀបប្រោសឡាសាអោយរស់ពីស្លាប់ឡើងវិញ ។ អំណោយទាននៃពាក្យសំដីនៃប្រាជ្ញានេះបានបើកអោយមានអំណោយទាននៃសេចក្តីជំនឿ ។ ព្រះយេស៊ូបានឈរនៅមុខផ្នូររបស់ឡាសា ហើយក៏បានចាប់ផ្តើម "ធ្វើអោយសំរេច" នូវអ្វីដែលព្រះអង្គបានឃើញខ្លួនព្រះអង្គធ្វើតាមរយៈអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ ។ ព្រះអង្គបានប្រាប់ពួកគេអោយរមាលថ្មរចេញ ហើយបានមានបន្ទូលដោយក្លាហានយ៉ាងខ្លាំងៗថា "ឡាសាអើយ ចេញមក!" ។

## ៣.	អ្នកជឿប្រើអំណោយទាននៃការធ្វើការអស្ចារ្យ

ក.	ការដើរលើទឹក

១.	"កាលគេឃើញយាងលើទឹកដូច្នោះ នោះក៏ភ័យរំលំ ហើយនិយាយថា ខ្មោចលងហើយ រួចគេស្រែកឡើង ដោយសេចក្តីតក់ស្លុត តែព្រះយេស៊ូទ្រង់មានបន្ទូលដល់គេភ្លាមថា 'ចូរសង្ឃឹមឡើង គឺខ្ញុំទេតើ កុំភ័យឡើយ' ពេត្រុសទូលតបថា 'ព្រះអម្ចាស់អើយ បើជាទ្រង់មែន នោះសូមអោយទូលបង្គំដើរលើទឹកទៅឯទ្រង់ផង' ទ្រង់មានព្រះបន្ទូលថា 'ចូរមកចុះ' ពេត្រុសក៏ចុះចេញពីទូកដើរលើទឹក ដើម្បីទៅឯព្រះយេស៊ូ" (ម៉ាថាយ ១៤:២៧-២៩) ។

២.	ប្រសិនបើយើងនឹងប្រើអំណោយទាននៃការធ្វើការអស្ចារ្យ យើងត្រូវជំនះលើការភ័យខ្លាចបរាជ័យ និង ការដែលខ្លាចគេថាយើងកំពុងធ្វើរឿងឆ្កួតលីលា ។ យើងត្រូវតែឈានជើងចេញពីទូកដែលពេញដោយសេចក្តីកំសាន្តចិត្តរបស់យើង ។ ចូរកត់សំគាល់ថា លោកពេត្រុសចង់ប្រើអំណោយទានដ៏អស្ចារ្យទាំងនេះណាស់ នៅពេលលោកមានប្រសាសន៍ថា "បើជាទ្រង់ មែននោះសូមអោយទូលបង្គំដើរលើទឹកទៅឯទ្រង់ផង" ។ លោកពេត្រុសបានទទួលអំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ និង អំណោយទាននៃសេចក្តីជំនឿនៅពេលលោកបានឮសម្លេងថា

"ចូរចុះមក!" ។ លោកពេត្រុសក៏បានធ្វើតាមសម្លេងនោះភ្លាម ។ លោកបានឈានជើងចេញពីទូក ហើយបានចាប់ផ្ដើមធ្វើការអស្ចារ្យដោយដើរលើទឹក ។

ខ. ការចាប់ត្រីបានដ៏ច្រើន (លូកា ៥:៤-៧)

គ. ការធ្វើអស្ចារ្យសម្រាប់ពួកអ្នកជឿក្នុងពេលបច្ចុប្បន្ន

១. លោកពេត្រុសបាននេសាទត្រីពេញមួយយប់ ប៉ុន្តែ ចាប់មិនបានត្រីសោះឡើយ ។ អ្នកនេសាទផ្សេងៗទៀតបានព្យាយាមធ្វើតាមចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេ ។

២. យើងត្រូវនិយាយដូចលោកពេត្រុសថា "យ៉ាងណាក៏ដោយ គឺត្រូវធ្វើតាមព្រះបន្ទូល..." ។ យើងត្រូវចំណាយពេលស្ដាប់ព្រះអង្គមានបន្ទូល និង ទទួលព្រះបន្ទូលរបស់ព្រះអង្គតាមរយៈ អំណោយទាននៃការបើកសម្ដែងដូចជា អំណោយទាននៃការសង្កេតស្គាល់អស់ទាំងវិញ្ញាណ អំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ និង អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ ។ សេចក្ដីជំនឿនឹងកើតមាន ហើយយើងត្រូវតែស្ដាប់បង្គប់ និង បោះជំហានចូលក្នុងអំណោយទាននៃការធ្វើការអស្ចារ្យ ។

៣. "ប្រាកដមែនហើយ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ ក៏នឹងធ្វើការធំជាងការទាំងនោះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះវរបិតា" (យ៉ូហាន ១៤:១២) ។

## ការពិភាក្សាជាក្រុម

១. ចូរពិភាក្សាពីរបៀបដែលអំណោយទាននៃសេចក្តីជំនឿធ្វើការនៅក្នុងខ្លួនអ្នកជឿនាពេលបច្ចុប្បន្ន ។

២. ចូរពិភាក្សាពីទំនាក់ទំនងរវាងអំណោយទាននៃសេចក្តីជំនឿ និង អំណោយទានការធ្វើការអស្ចារ្យ ។

៣. ចូរធ្វើទីបន្ទាល់ពីការអស្ចារ្យដែលលោកអ្នកបានឃើញទាំងនៅក្នុងជីវិតរបស់លោកអ្នក និង ជីវិតរបស់អ្នកដទៃ ។

៤. តើអ្នកជឿថា ព្រះជាម្ចាស់នៅតែធ្វើការអស្ចារ្យតាមរយៈអ្នកជឿនាពេលបច្ចុប្បន្ននេះដែរឬទេ ?

៥. តើលោកអ្នកត្រូវការការអស្ចារ្យអ្វីទេនៅក្នុងជីវិត និង ស្ថានភាពរបស់លោកអ្នក ?

៦. ចូរស្រុះស្រួលគ្នាក្នុងក្រុមតូចរបស់លោកអ្នក ហើយចូរជឿតាមរយៈសេចក្តីអធិស្ឋានថា ព្រះជាម្ចាស់នឹងធ្វើការអស្ចារ្យដែលលោកអ្នកត្រូវការ ។

## ការសិក្សាដោយខ្លួនឯង

ចូរយកព្រះគម្ពីររបស់លោកអ្នកមក ហើយស្វែងរកឧទាហរណ៍ស្តីអំពីការប្រើអំណោយទាននៃសេចក្តីជំនឿ និងអំណោយទាននៃការធ្វើការអស្ចារ្យ ។ ចូរស្វែងរកឧទាហរណ៍ចំនួនបួនចេញពីសញ្ញាចាស់ និង ចំនួនបួនទៀតចេញពីសញ្ញាថ្មី (សូមជ្រើសរើសយកឧហារណ៍ណាដែលមិនមាននៅក្នុងមេរៀននេះ) ។

ឧទាហរណ៍នៅក្នុងសញ្ញាចាស់ :

ឧទាហរណ៍នៅក្នុងសញ្ញាថ្មី :

តើលោកអ្នកត្រូវការការអស្ចារ្យនៅក្នុងជីវិតដែលឬទេ ? ចូរសរសេរការអស្ចារ្យនោះនៅខាងក្រោម ហើយអធិស្ឋាន និង សុំការអស្ចារ្យនោះពីព្រះជាម្ចាស់ ។

# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី៦ : អំណោយទាននៃការប្រោសអោយជា

## សេចក្តីផ្តើម

អំណោយទាននៃការប្រោសអោយជាគឺជាការចែកចាយអំណាចនៃការប្រោសអោយជារបស់ព្រះជាម្ចាស់មកអោយមនុស្សដែលត្រូវការការប្រោសអោយជា ។ យើងប្រើអំណោយទាននេះក្នុងទំរង់ពហុវចនៈ ព្រោះអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធផ្សេងទៀតជាច្រើនមានការជាប់ទាក់ទងយ៉ាងសកម្មនៅពេលដែលយើងប្រោសអ្នកជំងឺអោយជា ។ អំណោយទាននេះត្រូវបានប្រើជាទំរង់ពហុវចនៈ ព្រោះមានរបៀបជាច្រើនត្រូវបាមប្រើដើម្បីចែកចាយការប្រោសអោយជាដល់មនុស្សដែលមានជំងឺ ។

<u>មនុស្សដែលទទួលបានការប្រោសអោយ</u>ជាគឺជាមនុស្សដែលទទួលបានអំណោយទាននៃការប្រោសអោយជា ។ វាហាក់ដូចជា យើងគឺគ្រាន់តែជាអ្នករត់សំបុត្រប្រៃសនីយ៍ដែលនាំយកសំបុត្រអោយអ្នកដ៏ទៃប៉ុណ្ណោះ ។

## គំរោងមេរៀន

### ១. ការប្រោសអោយជាតាមរយៈការស្គាល់អស់ទាំងវិញ្ញាណ

ជារើយៗ វិញ្ញាណនៃជំងឺគឺជាដើមហេតុដែលបណ្តាលអោយមនុស្សមានជំងឺ ។ វិញ្ញាណនៃជំងឺទាំងនេះត្រូវបានកំណត់អត្តសញ្ញាណដោយយោងទៅតាមមុខនាទីជាក់លាក់របស់វា ដូចជាវិញ្ញាណនៃជំងឺសន្លាក់ រឺ វិញ្ញាណនៃជំងឺមហារីក ។

ជាធម្មតា នៅពេលមនុស្សម្នាក់មានជំងឺមួយប្រភេទដែលវិទ្យាសាស្ត្រពេទ្យហៅថា ជំងឺមិនអាចព្យាបាលបាន ជំងឺនោះគឺបង្កឡើងដោយសារ<u>វិញ្ញាណនៃជំងឺ</u> ។ តាមរយៈការប្រើអំណោយទាននៃការស្គាល់អស់ទាំងវិញ្ញាណ ព្រះវិញ្ញាណបរិសុទ្ធនឹង "ដាក់ព្រះអង្គលីរបស់ព្រះអង្គ" នៅលើឫសគល់នៃបញ្ហា ។

"ប៉ុន្តែ បើខ្ញុំដេញអារក្សដោយសារអង្គុយលីព្រះហស្តនៃព្រះវិញ នោះច្បាស់ជានគរព្រះបានមកដល់អ្នករាល់គ្នាហើយ" (លូកា ១១:២០) ។

- ព្រះអង្គលីនៃព្រះជាម្ចាស់អាចជាអំណោយទាននៃការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

តាមរយៈការប្រោសលោះ វិញ្ញាណអាក្រក់នឹងត្រូវបានបណ្តេញចេញ ហើយមនុស្សនោះនឹងត្រូវបានដោះលែងអោយមានសេរីភាពរួចផុតពីជំងឺ និង រោគសញ្ញាជំងឺនោះ ។

ក. គំរូរបស់ស្ត្រីដែលមានវិញ្ញាណនៃជំងឺ (លូកា ១៣:១១-១៣,១៦) ។

ខ. គំរូនៃការដេញវិញ្ញាណគថ្លង់របស់ព្រះយេស៊ូ ។

១. "កំពុងដែលអ្នកទាំងពីរចេញទៅនោះ មានគេនាំមនុស្សគដែលមានអារក្សចូលមកឯទ្រង់ រួច

កាលដេញអារក្សចេញហើយ នោះមនុស្សគបាននិយាយឡើងបាន"( ម៉ាថាយ ៩:៣២-៣៣) ។

២. បុរសម្នាក់នេះត្រូវបានគេនិយាយថា មានអារក្សចូល ប៉ុន្តែ រោគសញ្ញាតែមួយគត់ដែលគាត់មានគឺគាត់មិនអាចនិយាយបានរហូតដល់អារក្សនោះត្រូវបានបណ្តេញចេញពីខ្លួនគាត់ ។

៣. នៅក្នុងគំរូទាំងពីរនេះ ព្រះយេស៊ូបានធ្វើការយ៉ាងមានប្រសិទ្ធិភាព ព្រះអង្គបានប្រើអំណោយទាននៃការសង្កេតស្គាល់អស់ទាំងវិញ្ញាណត្រង់ចំឫសគល់នៃបញ្ហា ។

## ២. ការទទួលអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់សម្រាប់ការប្រោសអោយជា

ជារឿយៗ នៅពេលយើងប្រើអំណោយទាននៃការប្រោសអោយជា ព្រះជាម្ចាស់នឹងប្រទានអំណោយទាននៃចំណេះចេះស្ទាត់មកអោយយើងដើម្បីអោយយើងស្គាល់ជំងឺដែលព្រះអង្គចង់ព្យាបាលអោយជា ។ តាមរយៈអំណោយទាននេះ យើងអាចស្គាល់យ៉ាងអស្ចារ្យនូវឈ្មោះរបស់ជំងឺ សរីរាង្គ ផ្នែកផ្សេងៗនៃរូបកាយ រឺ ទីតាំងដែលមានការឈឺចាប់ ដែលត្រូវការការប្រោសអោយជា ។ ការដឹងនោះអាចតាមរយៈអារម្មណ៍បាក់ទឹកចិត្ត ការទទួលសម្ពាធពីខាងក្រៅ ឬ ការឈឺចាប់នៅក្នុងផ្នែកណាមួយនៃរូបកាយរបស់លោកអ្នក ។ ការដឹងនោះអាចតាមរយៈអារម្មណ៍ រឺ និម្មិត្ត ដែលប្រាប់អោយយើងដឹងពីផ្នែកណាមួយនៃរូបកាយរបស់មនុស្សដែលព្រះជាម្ចាស់ចង់អោយយើងប្រោសអោយជា ។

នៅពេលយើងប្រោសអ្នកណាម្នាក់អោយជា ព្រះវិញ្ញាណតែងតែដឹកនាំយើងអោយប្រាប់មនុស្សនោះពីអ្វីដែលព្រះជាម្ចាស់បានបើកសម្តែងអោយយើងឃើញ ហើយយើងត្រូវសួរគេថា តើយើងអាចប្រោសផ្នែកនៃរាងកាយរបស់គេនោះអោយជាបានទេ ។

ក. ការប្រោសអោយជាតាមរយៈអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់

១. នៅពេលយើងធ្វើការក្នុងចំណោមមនុស្ស ព្រះវិញ្ញាណនាំយើងអោយនិយាយថា "ព្រះជាម្ចាស់បង្ហាញខ្ញុំថា មាននរណាម្នាក់នៅទីនេះដែលកំពុងស្ថិតនៅក្នុងលក្ខណ្ឌនេះ ហើយព្រះជាម្ចាស់ចង់អោយអ្នកទទួលការព្យាបាលនៅពេលឥឡូវនេះ" ។

២. អ្វីដែលព្រះជាម្ចាស់បើកសំម្តែងគឺ ព្រះអង្គតែងតែប្រោសអោយជា ។

ខ. អំណោយទាននៃពាក្យសំដីនៃចំណេះស្ទាត់ជូនកាលបើកសម្តែងពីមនុស្សជាក់លាក់ណាម្នាក់

១. នៅឯស្រះទឹកមួយឈ្មោះថា បេថែសដា មានអ្នកជំងឺ មនុស្សខ្វាក់ និង មនុស្សពិការដៃជើងជាច្រើន ។ ទោះជាយ៉ាងណាក៏ដោយ ព្រះវិញ្ញាណបានដឹកនាំព្រះយេស៊ូអោយព្យាបាលបុរសម្នាក់ ។

២. "នៅទីនោះមានបុរសម្នាក់ដែលឈឺ៣៨ឆ្នាំមកហើយ កាលព្រះយេស៊ូឃើញគាត់ដេកនៅ ហើយជ្រាបថាគាត់នៅយ៉ាងនោះជាយូរមកហើយ នោះទ្រង់មានបន្ទូលថា "តើអ្នកចង់បានជាឬទេ?" ស្រាប់តែអ្នកនោះបានជាភ្លាម ក៏យកគ្រែដើរទៅ" ( យ៉ូហាន ៥:៥-៦, ៨-៩) ។

៣.	ជួនកាល ព្រះជាម្ចាស់បង្វែរចំណាប់អារម្មណ៍របស់យើងទៅរកមនុស្សណាម្នាក់នៅពេល យើងទទួលអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ ។ ព្រះអង្គប្រហែលជាប្រាប់ឈ្មោះមនុស្សម្នាក់នោះដល់យើង រឺ យើងប្រហែលជាមានអារម្មណ៍ថា "វិញ្ញាណរបស់យើងត្រូវបាន" ទាញទៅរកមនុស្សម្នាក់នោះ ។

## ៣. ការប្រោសអោយជា និង ពាក្យសំដីនៃប្រាជ្ញាវាងវៃ

អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ គឺជាការចែកចាយប្រាជ្ញា ដែលមកពីព្រះជាម្ចាស់ដែលនឹងបើកសម្តែងពីរបៀបអនុវត្តសកម្មភាពណាមួយដើម្បីបំពេញសេចក្តីត្រូវការណាមួយអោយមានប្រសិទ្ធិភាព ។ អំណោយទាននេះផ្តល់អោយយើងនូវប្រាជ្ញា ដើម្បីស្គាល់ពីអ្វីដែលយើងត្រូវធ្វើជាមួយនឹងចំណេះចេះស្ទាត់ដែលយើងបានទទួលទាំងដោយធម្មតា និង ដោយអស្ចារ្យ ។ អំណោយទាននេះបើកសម្តែងប្រាប់យើងពីរបៀបដែលយើងត្រូវបំពេញសេចក្តីត្រូវការរបស់យើងដោយយោងស្របតាមផែនការ និង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។

វាគឺសំខាន់ណាស់ក្នុងការចំណាយពេលដើម្បីស្តាប់ និង ស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដើម្បីអោយយើងដឹងថា តើនរណា ពេលណា កន្លែងណា និង របៀបណាដែលព្រះអង្គសព្វព្រះទ័យអោយយើងបំពេញតំរូវការ ។

"ដូច្នេះ ព្រះយេស៊ូវមានព្រះបន្ទូលថា កាលណាអ្នករាល់គ្នាបានលើកកូនមនុស្សឡើង នោះទើបនឹងដឹងថា គឺខ្ញុំនេះហើយជាព្រះ ហើយថា ខ្ញុំមិនធ្វើការអ្វីដោយអាងខ្លួនខ្ញុំ គឺខ្ញុំនិយាយសេចក្តីទាំងនេះតាមតែព្រះវរបិតាបានបង្រៀនខ្ញុំវិញ" (យ៉ូហាន ៨:២៨) ។

"តើអ្នកមិនជឿថា ខ្ញុំនៅក្នុងព្រះវរបិតា ហើយព្រះវរបិតាគង់នៅក្នុងខ្ញុំទេឬអី អស់ទាំងពាក្យដែលខ្ញុំប្រាប់ដល់អ្នករាល់គ្នា នោះខ្ញុំមិនមែនប្រាប់ដោយអាងខ្លួនខ្ញុំទេ គឺព្រះវរបិតាដែលគង់ក្នុងខ្ញុំ ទ្រង់ធ្វើការទាំងនោះវិញ" (យ៉ូហាន ១៤:១០) ។

តាមរយៈពាក្យសំដីនៃប្រាជ្ញាវាងវៃ ព្រះយេស៊ូមិនត្រឹមតែត្រូវបានដឹកនាំទៅកាន់បុរសម្នាក់ នៅជិតស្រះទឹកបេថេសតានោះទេ ប៉ុន្តែ ព្រះអង្គថែមទាំងបានប្រោសមនុស្សអោយជាតាមរយៈវិធីផ្សេងៗជាច្រើន ។ ព្រះអង្គបានដាក់ដៃលើពួកគេ ព្រះអង្គដាក់ម្រាមដៃក្នុងត្រចៀករបស់ពួកគេ ព្រះអង្គស្តោះទឹកមាត់ និង ពាល់អណ្តាតរបស់ពួកគេ ព្រះអង្គដេញអារក្ស ហើយព្រះអង្គសូម្បីតែប្រោសអោយជាគ្រាន់តែតាមរយៈការមានបន្ទូលតែប៉ុណ្ណោះ ។

ក.	ពាក្យសំដីនៃប្រាជ្ញាវាងវៃនៅក្នុងពន្ធ័កិច្ចនៃការប្រោសអោយជារបស់លោកប៉ុល

១.	ដូចគ្នាផងដែរ លោកប៉ុលបានប្រោសមនុស្សអោយជាតាមរបៀបជាច្រើននៅពេលដែលលោកត្រូវបានដឹកនាំអោយធ្វើ តាមរយៈការប្រើអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ ។ លោកប៉ុលបានប្រោសមនុស្សអោយជាតាមរយៈការដាក់ដៃលើអ្នកជំងឺ និង ការប្រើកន្សែងដៃ រឺ ក្រណាត់ដែលប៉ះលោក ហើយយកមកដាក់លើអ្នកជំងឺ ។ លោកបានប្រោសក្មេងជំទង់ម្នាក់ឈ្មោះអើទីកុសអោយរស់ពីស្លាប់ឡើងវិញដោយលោកបានទ្រោបពីលើគេ ហើយអោបត្រកងគេ ។

២. មុនពេលលោកប៉ុលប្រោសឪពុករបស់ពូព្លាសអោយជា លោកបានអធិស្ឋានជាមុនសិន (ដើម្បីទទួលពាក្យសំដីនៃប្រាជ្ញាវាងវៃស្តីអំពីរបៀបប្រោសបុរសម្នាក់នេះអោយជា) បន្ទាប់មក លោកបានដាក់ដៃលើគាត់ដើម្បីប្រោសគាត់អោយជា ។

៣. "គាប់ចួនជាឪពុកពូព្លាសដេកគ្រុន ហើយមួលផង ប៉ុលក៏ចូលទៅអធិស្ឋាន ដាក់ដៃលើគាត់អោយបានជា" (កិច្ចការ ២៨:៨) ។

ខ. ការទទួលពាក្យសំដីនៃចំណេះចេះស្ទាត់សម្រាប់ការប្រោសអោយជា

ចំណេះដឹងប្រើដើម្បីប្រោសជំងឺណាមួយអោយជាអាចទទួលដោយធម្មតា រឺ ដោយអស្ចារ្យតាមរយៈអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ ។ ពេលនោះ យើងត្រូវឈប់ ហើយចាំស្តាប់ព្រះវិញ្ញាណដើម្បីអោយបានដឹងថា តាមរយៈពាក្យសំដីនៃប្រាជ្ញាវាងវៃ តើព្រះអង្គមានប្រទានអោយយើងនូវរបៀបដើម្បីប្រោសមនុស្សនោះអោយជាដែរឬទេ ។

ពាក្យសំដីនៃប្រាជ្ញាវាងវៃជាធម្មតាតែងតែកើតមានក្នុងទំរង់ជាអារម្មណ៍ ឬ និម្មិត្តដែលតាមរយៈអារម្មណ៍ ឬ និម្មិត្តនេះ យើងឃើញខ្លួនយើងប្រោសមនុស្សដែលត្រូវការការប្រោសព្យាបាលអោយជាតាមរបៀបជាក់លាក់ណាមួយ ។ ជួនកាល ព្រះជាម្ចាស់ប្រទានព្រះបន្ទូលដល់យើងដើម្បីដឹកនាំយើងអោយទៅដោះស្រាយជាមួយនឹងឬសគល់នៃបញ្ហាជាក់លាក់ណាមួយ ជាជាងគ្រាន់តែដោះស្រាយជាមួយនឹងរោគសញ្ញា ដែលយើងមើលឃើញ ។

## ៤. ការប្រោសអោយជា និង អំណោយទាននៃសេចក្តីជំនឿ

អំណោយទាននៃសេចក្តីជំនឿគឺជាសេចក្តីជំនឿដ៏អស្ចារ្យសម្រាប់ពេលវេលា និង គោលបំណងជាក់លាក់ណាមួយ ។ អំណោយទាននេះគឺជាអំណោយទាននៃអំណាចដើម្បីសំរេចកិច្ចការណាមួយ នៅក្នុងស្ថានភាពណាមួយ និងនៅពេលដ៏ជាក់លាក់ណាមួយ ។

ជួនកាល នៅពេលយើងត្រូវការការអស្ចារ្យអ្វីមួយ រឺ នៅពេលដែលការប្រោសមនុស្សម្នាក់អោយជាទាមទាអោយមានសេចក្តីជំនឿដែលមានកំរិតខ្ពស់ជាងសេចក្តីជំនឿធម្មតារបស់យើង ព្រះជាម្ចាស់នឹងប្រទានសេចក្តីជំនឿពិសេសនេះដល់យើងដើម្បីអោយមនុស្សអាចធ្វើបានសព្វគ្រប់អ្វីៗទាំងអស់ ។ យើងដឹងដោយគ្មានបន្ទិលសង្ស័យថា នឹងមានការបើកសម្តែងពីការប្រោសអោយជានោះ ។

ជួនកាល មានមនុស្សដែលបាត់ផ្នែកណាមួយនៃរូបកាយរបស់គេតាំងពីកំណើត ដោយសារការវះកាត់ ឬ គ្រោះថ្នាក់អ្វីមួយមកជួបយើង ។ ប្រហែលជាសេចក្តីជំនឿរបស់យើងមិនអាចរីកចំរើនឡើងរហូតដល់ចំណុចមួយដែលយើងអាចជឿថា ព្រះជាម្ចាស់អាចធ្វើការអស្ចារ្យបែបនេះបាន ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈពាក្យសំដីនៃប្រាជ្ញាវាងវៃ យើងប្រហែលជាមាននិម្មិត្ត ហើយក្នុងនិម្មិត្តនោះ យើងឃើញខ្លួនយើងកំពុងប្រោសមនុស្សនោះអោយជាជាមួយនឹងការអស្ចារ្យមួយ ។

នៅពេលយើងទទួលពាក្យសំដីនៃប្រាជ្ញាវាងវៃតាមរយៈនិម្មិត្ត អំណោយទាននៃសេចក្តីជំនឿនឹងត្រូវបើកអោយមាន ហើយយើងនឹងដឹងដោយគ្មានការសង្ស័យថា ការអស្ចារ្យនឹងកើតមានឡើងនៅពេលដែលយើងប្រោសមនុស្សនោះអោយជា សូម្បីតែយើងបានឃើញការអស្ចារ្យនោះកើតឡើងក្នុងនិម្មិត្តហើយក៏ដោយ ។

- ដំណើរការនៃអំណោយទាននៃសេចក្តីជំនឿ

លោកពេត្រុស និង លោកយ៉ូហានបានទទួលអំណោយទាននៃសេចក្តីជំនឿនៅថ្ងៃដែលពួកលោកបានឃើញបុរសខ្វិនជើងម្នាក់នៅមាត់ទ្វាររបងព្រះវិហារ ។

"តែលោកពេត្រុសនិយាយថា "ឯប្រាក់ហើយនិងមាស ខ្ញុំគ្មានទេ តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងអោយដល់អ្នក គឺដោយសារព្រះនាមព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត ចូរអ្នកក្រោកឡើងដើរទៅចុះ" រួចក៏ចាប់ដៃលើកគាត់ឡើង ស្រាប់តែប្រអប់ជើង និង ភ្នែកគោររបស់គាត់មានកម្លាំងឡើងភ្លាម គាត់ក៏ស្ទុះឈរឡើងដើរទៅមក ហើយចូលទៅក្នុងព្រះវិហារជាមួយនឹងអ្នកទាំងពីរនោះ ទាំងដើរ ទាំងលោត ទាំងសរសើរដល់ព្រះផង" (កិច្ចការ ៣:៦-៨) ។

## ៥. ការប្រោសអោយជា និង ការធ្វើការអស្ចារ្យ

ដោយបានទទួលពាក្យសំដីនៃចំណេះចេះស្ទាត់ តាមរយៈនិម្មិត្ត និង អារម្មណ៍ យើងបានឃើញការអស្ចារ្យកើតឡើងមុនពេលដែលយើងចាប់ផ្តើមប្រោសមនុស្សដែលត្រូវការការប្រោសព្យាបាលអោយជាទៅទៀត ។

ភ្លាម១នោះ យើងទទួលអំណោយទាននៃសេចក្តីជំនឿ ។ យើងនឹងដឹងដោយគ្មានសង្ស័យថា នៅពេលយើងប្រោសមនុស្សនោះអោយជាតាមរបៀបដែលយើងបានឃើញខ្លួនយើងធ្វើនៅក្នុងនិម្មិត្ត នោះការអស្ចារ្យនឹងកើតឡើង ។

យើងចាប់ផ្តើមធ្វើតាមអ្វីដែលយើងបានឃើញខ្លួនយើងធ្វើនៅក្នុងនិម្មិត្តដោយក្លាហាន ។ តាមរយៈការធ្វើដូច្នេះ យើងកំពុងប្រើអំណោយទាននៃការធ្វើការអស្ចារ្យ ។

"ទ្រង់មានបន្ទូលទៅមនុស្សស្វិតដៃថា ចូរអ្នកក្រោកឡើង ឈរនៅកណ្តាលទីនុ៎ះចោះ ទ្រង់ក៏មានបន្ទូលទៅកាន់មនុស្សនោះថា ចូរអ្នកលាតដៃទៅ អ្នកនោះក៏លាត ហើយដៃគាត់បានជាដូចម្ខាង" (ម៉ាកុស ៣:៣, ៥) ។

អំណោយទាននៃការប្រោសអោយជាទាក់ទងនឹងការហ្វឹកហាត់ និង ជំរុញលើកទឹកចិត្តអោយអ្នកជឿទាំងអស់ប្រើអំណោយទាននៃការបើកសម្តែង និង អំណោយទាននៃអំណាចទាំងអស់របស់ព្រះវិញ្ញាណបរិសុទ្ធ ។

## ការពិភាក្សាជាក្រុម

១. ចូលរួមគ្នាជាក្រុម រួចសិក្សាពីរបៀបធ្វើអោយអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធមានសកម្មភាពតាមរយៈការធ្វើអោយអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ អំណោយទាននៃពាក្យសំដីនៃប្រាជ្ញាវាងវៃ និង អំណោយទាននៃសេចក្តីជំនឿបង្កើតអោយមានអំណោយទាននៃការប្រោសអោយជា និង អំណោយ ទាននៃការធ្វើការអស្ចារ្យ ។

២. ចូរបំពេញព័ន្ធកិច្ចចំពោះគ្នាទៅវិញទៅមក ។ ចាប់ពីពេលនេះតទៅ នៅក្នុងស្ថានភាពនៃព័ន្ធកិច្ចរបស់លោកអ្នក ចូរធ្វើការទាក់ទងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ហើយអនុញ្ញាតអោយព្រះអង្គចាក់បង្ហូរអំណោយទានរបស់ព្រះអង្គតាមរយៈលោកអ្នក ។

## ការសិក្សាដោយខ្លួនឯង

១. តើលោកអ្នកមានទស្សនៈយ៉ាងណាដែរចំពោះអ្នកដែលបំពេញព័ន្ធកិច្ចនៃការប្រោសអោយជា ? តើគេគ្រាន់តែជាយានចំលងដែលប្រើសម្រាប់ដឹកនាំអំណោយទាននេះមែនទេ ?

២. ចំពោះលោកអ្នក តើលោកអ្នកយល់ថា មនុស្សចាំបាច់ត្រូវមានអាកាប្បកិរិយាបែបណាដើម្បីប្រើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធបាន ?

៣. ចូរសរសេរពីការចាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់លោកអ្នកនៅពេលលោកអ្នកព្យាយាមធ្វើអោយអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្ទាត់ ពាក្យសំដីនៃប្រាជ្ញាវាងវៃ សេចក្តីជំនឿ ការប្រោសអោយ ជា និង ការធ្វើការអស្ចារ្យមានសកម្មភាពនៅក្នុងក្រុមសិក្សា ឬ ស្ថានភាពព័ន្ធកិច្ចរបស់លោកអ្នក ។

# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី៧ ៖ ការប្រោសអោយជា និង បេសកកម្មដ៏អស្ចារ្យ

## សេចក្តីផ្តើម

នៅមេរៀននេះ យើងនឹងសិក្សាពីការប្រោសអោយជា និង បេសកកម្មដ៏អស្ចារ្យ ។

## គំរោងមេរៀន

១. បេសកកម្មដ៏អស្ចារ្យរួមមានទាំងការប្រោសអោយជា ( ម៉ាកុស ១៦:១៥-២០)

ពេលព្រះយេស៊ូវរៀបនឹងយាងចាកចេញពីផែនដីនេះដើម្បីទៅកាន់ឯព្រះវរបិតាវិញ ព្រះអង្គបានប្រមូលផ្តុំអ្នកជឿព្រះអង្គទាំងអស់នៅលើភ្នំដើមអូលីវ ហើយបានប្រទានការបង្រៀនចុងក្រោយដល់ពួកគេ ។ យើងហៅការនេះថា "បេសកកម្មដ៏អស្ចារ្យ" ។

ក. សម្រាប់អ្នកជឿគ្រប់គ្នា

បេសកកម្មនេះមិនមែនគ្រាន់តែសម្រាប់ពួកសាវ័កជំនាន់មុន១ប៉ុណ្ណោះទេ ។ បេសកកម្មនេះក៏ត្រូវបានប្រទានមកអោយអស់អ្នកដែលមានមុខងារពាក់ព័ន្ធទៅនឹងព័ន្ធកិច្ចទាំងប្រាំគឺ សាវ័ក ព្យាការី គ្រូគង្វាល អ្នកបង្រៀនព្រះបន្ទូល និង អ្នកផ្សព្វផ្សាយដំណឹងល្អ ។ ព្រះយេស៊ូវបានបញ្ជាក់ទៀតថា បេសកកម្មនេះគឺសម្រាប់អស់អ្នកដែលជឿ ។ បេសកកម្មដ៏អស្ចារ្យនេះគឺសម្រាប់អ្នកជឿគ្រប់រូបនាពេលបច្ចុប្បន្ននេះ ។

ខ. សម្រាប់គ្រប់ជាតិសាសន៍ទាំងអស់

១. អ្នកជឿគ្រប់គ្នាត្រូវប្រកាសដំណឹងល្អនេះដោយក្លាហានប្រាប់ដល់គ្រប់ជាតិសាសន៍ទាំងអស់ ។ ព្រះយេស៊ូវមានបន្ទូលថា ៖ "ដំណឹងល្អ ដែលសំដែងពីនរគ នឹងត្រូវប្រកាសប្រាប់ទូទៅគ្រប់ក្នុងលោកីយ ទុកជាទីបន្ទាល់ដល់អស់ទាំងសាសន៍ នោះទើបនឹងបានដល់ចុងបំផុត" ( ម៉ាថាយ ២៤: ១៤) ។

២. ការប្រកាសដំណឹងល្អគឺជាការចែកចាយដំណឹងល្អដល់មនុស្សគ្រប់រូបមិនថានៅក្នុងក្រុមធំ រឺ តូចនោះទេ គឺត្រូវធ្វើដូចលោកភីលីពបានធ្វើនៅពេលលោកអង្គុយក្បែរមហាត្លឹកសាសន៍អេធីយ៉ូពីម្នាក់ដែលកំពុងធ្វើដំណើរដោយរទេះជាមួយលោក ។

គ. ទីសំគាល់តែងតែនៅជាប់នឹងអ្នកជឿជានិច្ច

១. គ្រប់ទីកន្លែងដែលព្រះយេស៊ូវបានយាងទៅ ព្រះអង្គបានដេញអារក្សចេញ ហើយបានប្រោសអ្នកជំងឺអោយជា ។ ឥឡូវនេះ ព្រះអង្គចាត់អោយអស់អ្នកដែលជឿព្រះអង្គធ្វើរឿងដូចគ្នានឹងព្រះអង្គបានធ្វើដែរ ។ អស់អ្នកដែលជឿត្រូវតែដេញអារក្សចេញ និង និយាយភាសាដទៃ.... ។

២. ព្រះយេស៊ូមិនបានមានបន្ទូលថា ទីសំគាល់ទាំងនេះនឹងនៅជាប់ជាមួយអស់អ្នកដែលមានបន្ទិលសង្ស័យថា តើទីសំគាល់ទាំងនេះនឹងកើតឡើងតាមរយៈដៃរបស់ពួកគេដោយរបៀបណានោះទេ ។ ព្រះអង្គក៏មិនបានមានបន្ទូលថា ទីសំគាល់ទាំងនេះនឹងស្ថិតនៅជាមួយអស់អ្នកដែលសង្ឃឹមថាទីសំគាល់ទាំងនេះអាចនឹងកើតឡើងនោះទេ ។ ព្រះអង្គមានបន្ទូលថា ទីសំគាល់ទាំងនេះនឹងស្ថិត នៅជាប់ជាមួយអស់អ្នកទាំងឡាយណាដែលជឿថាទីសំគាល់ទាំងនេះប្រាកដជានឹងកើតឡើង ។

៣. សេចក្តីជំនឿនឹងលេចឡើងនៅក្នុងវិញ្ញាណរបស់យើង នៅពេលព្រះជាម្ចាស់ធ្វើអោយព្រះបន្ទូលទាំងនេះក្លាយទៅជាព្រះបន្ទូលនៃការបើកសម្តែងផ្ទាល់ខ្លួនសម្រាប់យើង ។ ប្រសិនបើយើងដែលជាអ្នកជឿពោរពេញទៅដោយព្រះវិញ្ញាណ ពិតជាមានសេចក្តីជំនឿលើព្រះបន្ទូលរបស់ព្រះយេស៊ូទាំងអស់នេះពិតមែន នោះទីសំគាល់ទាំងឡាយនឹងស្ថិតនៅជាប់ជាមួយនឹងយើង។ បន្ទាប់មកទៀត យោងតាមកណ្ឌគម្ពីរម៉ាកុស ព្រះយេស៊ូបានមានព្រះបន្ទូលជាលើកចុងក្រោយ។ ព្រះបន្ទូលជាលើកចុងក្រោយទាំងអស់នេះហើយ ដែលជាការបង្រៀនជាលើកចុងក្រោយ របស់ព្រះយេស៊ូមុនពេលព្រះអង្គយាងឡើងទៅឯព្រះវរបិតាវិញនោះ ។ ព្រះបន្ទូលចុងក្រោយទាំងនេះហើយដែលជាសេចក្តីបង្រៀនសំខាន់បំផុតរបស់ព្រះអង្គ និង ដែលព្រះអង្គចង់អោយអ្នកជឿគ្រប់គ្នាចងចាំជានិច្ច ។

- "........ហើយគេនឹងដាក់ដៃលើមនុស្សជំងឺអោយបានជាផង" (ម៉ាកុស ១៦:១៨) ។

ឃ. បញ្ជាក់ព្រះបន្ទូលជាមួយនឹងទីសំគាល់

១. "ឯពួកសិស្ស គេចេញទៅប្រកាសប្រាប់នៅសព្វគ្រប់អន្លើ ដោយមានព្រះអម្ចាស់ធ្វើការជាមួយទាំងបញ្ជាក់ព្រះបន្ទូល ដោយទីសំគាល់ដែលកើតមកតាមក្រោយផង" (ម៉ាកុស ១៦:២០) ។

២. ទីសំគាល់នឹងស្ថិតនៅជាប់ជាមួយអ្នកជឿគ្រប់គ្នា នៅពេលដែលយើងប្រកាស និង ចែកចាយដំណឹងល្អ ។ ការដាក់ដៃលើអ្នកជំងឺដើម្បីអោយគេបានជានៅតែជាទីសំគាល់មួយដែលសំខាន់ជាងគេបំផុតនៅពេលយើងបំពេញព័ន្ធកិច្ចជាអ្នកជឿនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។

៣. នៅពេលយើងចេញទៅប្រកាសដំណឹងល្អ ព្រះយេស៊ូនឹងធ្វើការជាមួយយើង និង បញ្ជាក់ព្រះបន្ទូលរបស់ព្រះអង្គប្រាប់ដល់អស់អ្នកបាត់បង់តាមរយៈទីសំគាល់ ការអស្ចារ្យនៃការប្រោសអោយជា និង ការអស្ចារ្យផ្សេងៗទៀតជាច្រើនដែលតែងតែស្ថិតនៅជាប់ជាមួយនឹងអស់អ្នកដែលជឿលើព្រះយេស៊ូគ្រិស្ត ។

## ២. ព័ន្ធកិច្ចនៃការប្រោសអោយជារបស់ព្រះយេស៊ូ

គ្រប់ទីកន្លែងទាំងអស់ដែលព្រះយេស៊ូបានយាងទៅកាលពីព្រះអង្គនៅបំពេញព័ន្ធកិច្ចលើផែនដីនេះនៅឡើយ ទីសំគាល់ទាំងនេះបាននៅជាប់ជាមួយនឹងព្រះអង្គ ។

"ព្រះយេស៊ូវ ទ្រង់ក៏យាងទៅដល់គ្រប់ក្រុងគ្រប់ភូមិ ព្រមទាំងបង្រៀនក្នុងសាលាប្រជុំទាំងប៉ុន្មាន ហើយប្រកាសប្រាប់ដំណឹងល្អពីនគរ ទ្រង់ក៏ប្រោសអស់ទាំងជំងឺរោគា នឹង ជរាពិការ ក្នុងពួកបណ្តាជនអោយបានជា" (ម៉ាថាយ ៩:៣៥) ។

"ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំអោយផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំអោយមកដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ និង សេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយអោយដោះមនុស្សដែលត្រូវគេជិះជាន់អោយរួច ព្រមទាំងប្រកាសប្រាប់ពី ឆ្នាំដែលព្រះអម្ចាស់កំណត់ទុក" (លូកា ៤:១៨-១៩) ។

ក. ព្រះយេស៊ូជាគំរូរបស់យើង

១. ព្រះយេស៊ូបានមានបន្ទូលថា "ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ ក៏នឹងធ្វើការធំជាងការទាំងនោះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះវរបិតា" (យ៉ូហាន ១៤:១២) ។

២. មនុស្សជាច្រើនបានអានព្រះបន្ទូលទាំងនេះ និង គិតថា "តើយើងអាចធ្វើការដូចដែលព្រះយេស៊ូបានធ្វើយ៉ាងដូចម្តេចកើត ? តើព្រះយេស៊ូអាចធ្វើជាគំរូដល់យើង ហើយព្រះអង្គរំពឹងថាយើងនឹងធ្វើកិច្ចការដែលទ្រង់បានធ្វើនោះយ៉ាងណាដូចម្តេចទៅ ? ព្រះអង្គគឺជាបុត្រាដ៏មានអំណាច និង អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់" ។

ខ. លះបង់សិទ្ធិជាព្រះជាម្ចាស់ជាបណ្តោះអាសន្ន

១. វាមានសារៈសំខាន់ណាស់ក្នុងការយល់ថា នៅពេលព្រះយេស៊ូយាងមកកាន់ផែនដីនេះ ព្រះអង្គបានយាងមកក្នុងនាមជា"លោកអ័រដាមចុងក្រោយ"។ ព្រះអង្គនៅតែជាព្រះជាម្ចាស់ដដែលទេ ប៉ុន្តែ ព្រះអង្គបានលះបង់សិទ្ធិជាព្រះជាម្ចាស់របស់ព្រះអង្គជាបណ្តោះអាសន្នសិន ហើយបានយាងមកយកសញ្ជាតិជាមនុស្ស ។

២. ក្នុងនាមជាព្រះជាម្ចាស់ ព្រះអង្គគង់នៅគ្រប់ទីកន្លែងក្នុងពេលតែមួយ ប៉ុន្តែ ក្នុងនាមជាមនុស្ស ព្រះអង្គគង់នៅកន្លែងតែមួយក្នុងពេលតែមួយ ។ ក្នុងនាមជាព្រះជាម្ចាស់ ព្រះអង្គយល់ដឹងគ្រប់អ្វីៗទាំងអស់ ប៉ុន្តែ ក្នុងនាមជាមនុស្ស នៅពេលស្ត្រីដែលមានជំងឺធ្លាក់ឈាមប៉ះព្រះអង្គ ព្រះយេស៊ូបានសួរថា "នរណាប៉ះខ្ញុំ ? " ហើយព្រះអង្គបានរកមើលជុំវិញខ្លួនព្រះអង្គដើម្បីចង់ដឹងថា តើនរណាប៉ះព្រះអង្គ ។ ក្នុងនាមជាព្រះជាម្ចាស់ ព្រះអង្គមានគ្រប់ទាំងអំណាចទាំងអស់ ។ ប៉ុន្តែ ក្នុងនាមជាមនុស្ស គ្មានការអស្ចារ្យណាមួយត្រូវបានកត់ត្រាសម្រាប់រយៈពេល ៣០ឆ្នាំដំបូងនៃជីវិតរបស់ព្រះអង្គ ។

៣. ប៉ុន្តែ នៅពេលព្រះយេស៊ូបានទទួលពិធីជ្រមុជទឹកនៅទន្លេយ័រដាន់ ហើយព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើព្រះអង្គ ការអស្ចារ្យបានចាប់ផ្តើមកើតឡើងនៅគ្រប់ទីកន្លែងដែលព្រះអង្គយាងទៅ ។ ព្រះយេស៊ូក៏បានធ្វើការជាមួយនឹងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធដូចយើងដែរ ។ ព្រះអង្គអាចយល់ដឹងគ្រប់អ្វីៗទាំងអស់យ៉ាងអស្ចារ្យដោយសារអំណោយទាននៃការបើកសម្តែងរបស់ព្រះវិញ្ញាណដូចយើងដែរ ។

គ. ប្រសិនបើព្រះយេស៊ូអាចធ្វើបាន យើងក៏អាចធ្វើបានដែរ !

ព្រះយេស៊ូគឺជាមនុស្សតែម្នាក់គត់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើជាគំរូរបស់យើងបាន ។ ព្រះអង្គមិនបានបំពេញព័ន្ធកិច្ចទាំងអស់ដោយអំណាចរបស់ព្រះអង្គជាបុត្រានៃព្រះជាម្ចាស់នោះទេ ប៉ុន្តែ

ព្រះអង្គបានបំពេញព័ន្ធកិច្ចក្នុងនាមព្រះអង្គជាមនុស្សសាមញ្ញម្នាក់ ដោយព្រះអង្គបានប្រើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ ដូច្នេះ យើងអាចនិយាយបានដោយក្លាហានថា "ប្រសិនបើព្រះយេស៊ូអាចធ្វើបាន យើងក៏អាចធ្វើបានដែរ! "។ យើងអាច ហើយយើងនឹងធ្វើកិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គនៅលើផែនដីនេះ ។ សូមចងចាំអ្វីដែលព្រះយេស៊ូមានបន្ទូល "អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ..." ។

ឃ. សេចក្តីមេត្តាករុណារបស់ព្រះយេស៊ូចំពោះមនុស្សបាត់បង់ ( ម៉ាថាយ ៩:៣៦-៣៨)

ព្រះយេស៊ូមិនសព្វព្រះទ័យអោយនរណាម្នាក់ត្រូវវិនាសឡើយ ។ ព្រះអង្គចង់អោយមនុស្សគ្រប់គ្នាឮដំណឹងល្អនៃការសង្គ្រោះរបស់ព្រះអង្គ ។ ព្រះអង្គបានសំរេចថានឹងមិនធ្វើរឿងនោះដោយខ្លួនព្រះអង្គផ្ទាល់នោះឡើយ ប៉ុន្តែ ព្រះអង្គបានសំរេចថានឹងធ្វើរឿងនោះតាមរយៈយើងវិញ ។

## ៣. ការចាត់អោយទៅបំពេញបេសកកម្មចាប់ផ្តើមដំបូងជាមួយនឹងសាវ័កទាំងដប់ពីរ

ព្រះយេស៊ូចាប់ផ្តើមបញ្ជូនកម្មករចូលទៅក្នុងទីចំរូតរបស់ព្រះអង្គតាមរយៈការបញ្ជូនសិស្សទាំងដប់ពីរនាក់របស់ព្រះអង្គ ។ ព្រះអង្គបានបង្រៀនពួកគេអោយធ្វើរឿងដូចគ្នាដែលព្រះអង្គបានធ្វើ ( ម៉ាថាយ ១០:១, ៧-៨) ។

ក. បន្ទាប់មកចិតសិបនាក់ ( លូកា ១០:១,៩)

- នៅពេលយើងប្រោសអ្នកជំងឺអោយជា យើងបាននាំយកនគររបស់ព្រះជាម្ចាស់មកកាន់ផែនដី ។

ព្រះយេស៊ូបានបំលែងអង្គកាយរបស់ព្រះអង្គជាដប់ពីរនាក់ ហើយបន្ទាប់មកទៀត ជាចិតសិបនាក់ ។ ពួកគេត្រូវបានចាត់អោយទៅប្រកាសដំណឹងល្អអំពីនគររបស់ព្រះជាម្ចាស់ ។ ពួកគេត្រូវបានចាត់អោយទៅធ្វើរឿងតែមួយដែលព្រះយេស៊ូបានធ្វើ ។

ខ. ឥឡូវនេះ អ្នកជឿគ្រប់គ្នា

១. ឥឡូវនេះ កិច្ចការរបស់ព្រះយេស៊ូនៅលើផែនដីនេះបានបញ្ចប់ហើយ ។ ព្រះអង្គបានយាងចាកចេញពីផែនដីនេះហើយ ប៉ុន្តែ កិច្ចការរបស់ព្រះអង្គពុំទាន់បានចប់សព្វគ្រប់នៅឡើយទេ ។ កិច្ចការនោះគឺទើបតែចាប់ផ្តើមប៉ុណ្ណោះ ។ ព្រះអង្គបានបំលែងអង្គកាយរបស់ព្រះអង្គ និង ព័ន្ធកិច្ចរបស់ព្រះអង្គចូលទៅក្នុងជីវិតរបស់អ្នកជឿទាំងអស់ ។

២. អ្នកជឿទាំងអស់ត្រូវតែចេញទៅទូទាំពិភពលោកនេះ ហើយប្រកាសដំណឹងល្អ ។ អ្នកជឿទាំងអស់និងដេញអារក្សចេញ និយាយភាសាដទៃ និង ដាក់ដៃលើអ្នកជំងឺដើម្បីប្រោសពួកគេអោយជា ។

៣. លោកពេត្រុស និង លោកយ៉ូហាន ដែលជាអ្នកជឿ បានចាប់ដៃស្តាំរបស់បុរសខ្វិនជើងពីកំណើតម្នាក់ដោយនិយាយថា " គឺដោយសារព្រះនាមព្រះយេស៊ូគ្រិស្ត ពីស្រុកណាសារ៉ែត ចូរអ្នកក្រោកឡើងដើរទៅចុះ" ។ បុរសនោះក៏ស្ទុះឈរឡើងដើរទៅមក ទាំងលោតនឹងសរសើរដល់ព្រះជាម្ចាស់ផង ។ បន្ទាប់ពីនោះមក នៅថ្ងៃដដែល ក្រុមជំនុំបានកើនឡើងចំនួនប្រាំពាន់នាក់ ។

៤.	លោកភីលីព ដែលជាអ្នកជឿ និង ជាអ្នកជំនួយនៅក្នុងក្រុមជំនុំក្រុងយេរូសាឡឹម បានធ្វើដំណើរទៅកាន់ស្រុកសាំម៉ារី ហើយបានប្រកាសដំណឹងល្អអំពីព្រះគ្រិស្តប្រាប់ដល់ពួកគេ ។

៥.	"ហើយបណ្តាមនុស្សក៏ស្រុះចិត្តគ្នា និង ប្រុងស្តាប់អស់ទាំងសេចក្តីដែលភីលីពនិយាយ ។ ដោយគេឮ ហើយឃើញទីសំគាល់ដែលគាត់ធ្វើ ព្រោះមានអារក្សអសោចិ៍ដែលបានចូលមនុស្សជាច្រើន វាស្រែកឡើងជាខ្លាំង រួចចេញមក ក៏មានមនុស្សស្លាប់ដៃជើង និង មនុស្សខ្វិនជាច្រើនបានជាដែរ ហើយនៅទីក្រុងនោះ គេមានសេចក្តីអំណរជាខ្លាំង" (កិច្ចការ ៨: ៦-៨) ។

៦.	លោកប៉ុលបានធ្វើដំណើរទៅកាន់ក្រុងអេភេសូរដើម្បីបង្រៀនដំណឹងល្អ ហើយ "ព្រះអម្ចាស់បានធ្វើការអស្ចារ្យដ៏ធំជាច្រើន តាមរយៈលោកប៉ុល គឺបើគេគ្រាន់តែបានយកក្រណាត់ ឬ កន្សែងដែលបានប៉ះលោកប៉ុលមកដាក់ពីលើអ្នកជំងឺ អ្នកជំងឺនឹងបានជា ហើយខ្មោចក៏នឹងចេញពីគេទៅដែរ" (កិច្ចការ ១៩:១១-១២) ។

៧.	លទ្ធផលគឺថា អស់អ្នកដែលរស់នៅក្នុងស្រុកអាស៊ីបានឮព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តទាំងសាសន៍យូដា នឹង សាសន៍ក្រិក (កិច្ចការ ១៩:១០) ។

៨.	សព្វថ្ងៃនេះ ព្រះជាម្ចាស់កំពុងរៀបចំសាវ័ក អ្នកផ្សព្វផ្សាយដំណឹងល្អ គ្រូគង្វាល និង គ្រូបង្រៀនព្រះបន្ទូលដើម្បីបំពាក់បំប៉នពួកប្រជារាស្ត្របរិសុទ្ធសម្រាប់ព័ន្ធកិច្ចរបស់ព្រះអង្គ ។ ព័ន្ធកិច្ចនេះគឺសម្រាប់ប្រជារាស្ត្របរិសុទ្ធទាំងអស់ ។ សព្វថ្ងៃនេះ អ្នកជឿទាំងអស់បានរីកលូតលាស់ឡើងដូចជាកងទ័ពមួយដ៏មានឫទ្ធានុភាព ហើយបានហ្វឹកហ្វឺន និង បានប្រដាប់ខ្លួនសម្រាប់ការផ្សាយដំណឹងល្អ ។

៩.	នៅពេលអ្នកជឿទាំងអស់គ្នាកំពុងបន្តផ្សាយដំណឹងល្អដល់គ្រប់ជាតិសាសន៍ទាំងអស់ យើងក៏អាចផ្សាយដំណឹងល្អស្តីអំពីព្រះយេស៊ូគ្រិស្តប្រាប់ដល់ទីក្រុង ប្រជាជាតិ និង ពិភពលោកទាំងមូលរបស់យើងមុនការយាងត្រលប់មកវិញក្នុងពេលឆាប់ៗខាងមុខនេះរបស់ព្រះអង្គបានដែរ ។

## ការពិភាក្សាជាក្រុម

១. តើការប្រោសអោយជាមានទំនាក់ទំនងអ្វីជាមួយនឹងបេសកកម្មដ៏អស្ចារ្យ ?

២. តើអ្នកជឿអាចធ្វើរឿងដូចគ្នានឹងព្រះយេស៊ូយ៉ាងដូចម្តេចទៅ ?

៣. តើអ្នកជឿសព្វថ្ងៃនេះត្រូវធ្វើអ្វីមុនពេលទីសំគាល់ដែលមាននៅក្នុងម៉ាកុស ១៦:១៥-២០ ស្ថិតនៅជាប់នឹងពួកគេ ?

៤. សូមអធិស្ឋានអោយគ្នាទៅវិញទៅមក ។

## ការសិក្សាដោយខ្លួនឯង

១. សូមសិក្សា ម៉ាកុស ១៦:១៥-២០ រួចរៀបរាប់ពីបញ្ជា និង សេចក្តីសន្យាដែលមាននៅក្នុងអត្ថបទគម្ពីរនោះ ។

| ការបញ្ជា | សេចក្តីសន្យា |
|---|---|
| ក. | ក. |
| ខ. | ខ. |
| គ. | គ. |
| ឃ. | ឃ. |
| ង. | ង. |

២. តើអ្នកណាដែលត្រូវធ្វើតាមការបញ្ជា និង ប្រកាសសេចក្តីសន្យាទាំងនេះ ?

៣. តើលោកអ្នកមានធ្វើតាមការបញ្ជា និង មានបានប្រកាសសេចក្តីសន្យាទាំងនេះនៅក្នុងស្ថានភាពនៃព័ន្ធកិច្ចរបស់លោកអ្នកដែរឬទេ ?

៤. សូមអធិស្ឋានសម្រាប់ការឆ្លើយតបរបស់លោកអ្នក ។

# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី៨ ៖ អំណាចនៃការប្រោសអោយជារបស់ព្រះជាម្ចាស់

## សេចក្តីផ្តើម

លោកប៉ុលបានសរសេរថា "...ឯពាក្យសំដី និង សេចក្តីអធិប្បាយរបស់ខ្ញុំក៏មិនមែនដោយពាក្យឧត្តុង្គឧត្តមដែលពូកែបញ្ចុះបញ្ចូលនោះដែរ គឺដោយការសម្តែងចេញជាព្រះវិញ្ញាណ និង ព្រះចេស្តាវិញទេតើ .." (១កូរិនថូស ២:៤) ។

លោកប៉ុលបានទទួលជ័យជំនះដោយសារការបើកសម្តែងពីអំណាចនៃការប្រោសអោយជារបស់ព្រះជាម្ចាស់នៅក្នុង និង តាមរយៈព័ន្ធកិច្ចរបស់លោក ។ ព្រះពន្ធលដែលលោកប៉ុលបានប្រកាសត្រូវបានបញ្ជាក់ដោយទីសំគាល់ និង ការអស្ចារ្យផ្សេងៗជាច្រើន ។ ការផ្សាយដំណឹងល្អតាមរយៈការអស្ចារ្យ ដូចដែលមានកត់ត្រានៅក្នុងកណ្ឌគម្ពីរកិច្ចការ គឺជាគន្លឹះមួយដើម្បីឈោងចាប់មនុស្សដែលបាត់បង់ ។

## គំរោងមេរៀន

១. អំណោចនៃការប្រោសអោយជានៅក្នុងព្រះយេស៊ូ (ម៉ាកុស ៥:២៥-៣៤)

ក. អំណាចដ៏អស្ចារ្យនៅក្នុងព្រះយេស៊ូ

១. ពាក្យថា "ព្រះចេស្តា" ដែលត្រូវបានប្រើនូវនៅក្នុងខទី៣០ ជាភាសាក្រិកគឺជាពាក្យថា "ឌូណាមីស" ។ ពាក្យនេះគឺជាពាក្យឫសនៃពាក្យថា ឌីណាមីត និង ឌីណាម៉ូ ។ នៅក្នុងភាសាក្រិកពាក្យនេះត្រូវបានប្រើសម្រាប់ពិពណ៌នាអំណាចដ៏អស្ចារ្យ ។

២. ពាក្យជាភាសាក្រិកដដែលនេះត្រូវបានប្រើសម្រាប់ពិពណ៌នាអំពីព្រះយេស៊ូនៅក្នុង លូកា ៤:១៤ បន្ទាប់ពីព្រះវិញ្ញាណបានយាងមកសណ្ឋិតលើព្រះអង្គនៅត្រង់ទន្លេយ័រដាន់ ៖ "ឯព្រះយេស៊ូវទ្រង់វិលទៅស្រុកកាឡីលេវិញ ទាំងមានព្រះចេស្តានៃព្រះវិញ្ញាណសណ្ឋិតលើទ្រង់..." ។

៣. នៅពេលព្រះវិញ្ញាណបានយាងចុះមកសណ្ឋិតលើព្រះយេស៊ូ ព្រះអង្គបានពេញទៅដោយអំណាចរបស់ព្រះជាម្ចាស់ ។ ព្រះអង្គបានក្លាយជាឈើច្រត់នៃអំណាចនោះ ។

៤. "យ៉ូហានក៏ធ្វើបន្ទាល់ថា ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីលើមេឃ មានរូបដូចជាព្រាប មកសណ្ឋិតលើទ្រង់" (យ៉ូហាន ១:៣២) ។

ខ. អំណាចប្រោសអ្នកជំងឺអោយជា

១. អំណាចនៃព្រះវិញ្ញាណបរិសុទ្ធដែលសណ្ឋិតនៅក្នុងព្រះយេស៊ូ គឺជាអំណាចដែលប្រោសអ្នកជំងឺអោយជា ។ មានថ្ងៃមួយ នៅពេលដែលព្រះយេស៊ូកំពុងបង្រៀន មានមនុស្សជាច្រើនដោយ

រួមទាំងអ្នកដឹកនាំសាសនាផង បានចេញពីក្រុងនៃស្រុកកាឡីលេ ស្រុកយូដា នឹង ក្រុងយេរូសាឡឹមមកស្តាប់ព្រះយេស៊ូ ។

២. លោកលូកាបានកត់ត្រាថា ".......ហើយព្រះចេស្តានៃព្រះអម្ចាស់ក៏នៅទីនោះ បំរុងនឹងប្រោសគេអោយជាដែរ" (លូកា ៥:១៧)។ នៅក្នុងជំពូកក្រោយ មានការកត់ត្រាទៀតថា "...ហ្វូងមនុស្សទាំងអស់បានចោមប៉ះទ្រង់ដើម្បីទទួលនូវ"ចេស្តា" (ដូណាមីស) ដែលចេញពីទ្រង់ទៅព្យាបាល ពួកគេ" (លូកា ៦:៩) ។

## ២. អំណាចដ៏អស្ចារ្យនៅក្នុងលោកប៉ុល

".....ពេលនោះព្រះអម្ចាស់បានធ្វើការអស្ចារ្យដ៏ធំជាច្រើន តាមរយៈលោកប៉ុល គឺបើគេគ្រាន់តែយកក្រណាត់ ឬកន្សែងដែលបានប៉ះលោកប៉ុលមកដាក់ពីលើអ្នកជំងឺ អ្នកជំងឺនឹងបានជា ហើយខ្មោចក៏នឹងចេញពីគេទៅដែរ" (កិច្ចការ ១៩:១១-១២) ។

អំណាចនៃការប្រោសអោយជា ដែលសណ្ឋិតនៅក្នុងព្រះយេស៊ូនោះ បានហូរចេញមកតាមរយៈដៃរបស់ប៉ុល ។ អំណាចនៃការប្រោសអោយរបស់ព្រះជាម្ចាស់គឺជាអំណាចពិតប្រាកដ ហើយអស្ចារ្យយ៉ាងខ្លាំង ដែលអាចចម្លងចូលទៅក្នុងក្រណាត់ ហើយអាចយកទៅទីក្រុងដែលនៅឆ្ងាយបាន ។ នៅពេលគេដាក់ក្រណាត់នោះនៅលើខ្លួនប្រាណរបស់អ្នកជំងឺ អ្នកជំងឺនោះនឹងបានជា ហើយ ត្រូវបានប្រោសលោះមួយរំពេច ។

ក. អំណាចនៃការប្រោសអោយជាគឺជាអំណាចដែលពិតប្រាកដ និង ជាក់ស្តែង

១. អំណាចរបស់ព្រះជាម្ចាស់ដែលសណ្ឋិតនៅក្នុងព្រះយេស៊ូគឺជាអំណាចដែលពិតប្រាកដ និង ជាក់ស្តែង ។ ព្រះអង្គមានអារម្មណ៏ថា អំណាចនោះ បានហូរចេញពីអង្គចូលទៅស្ត្រីម្នាក់ដែលមានជំងឺធ្លាក់ឈាម ។ ទោះបីជាព្រះអង្គកំពុងធ្វើដំណើរទៅប្រោសកូនស្រីរបស់យ៉ៃរ៉ុសអោយរស់ពីស្លាប់ឡើងវិញក៏ដោយ ក៏ព្រះអង្គបានឈប់ ហើយមានព្រះបន្ទូលសួរថា "អ្នកណាពាល់ខ្ញុំធ្វើអ្វី?" ។ ព្រះអង្គមានអារម្មណ៏ថា អំណាចដ៏អស្ចារ្យបានហូរចេញពីខ្លួនរបស់ព្រះអង្គ ។

២ អំណាចនៃការប្រោសអោយជាដែលសណ្ឋិតនៅក្នុងខ្លួនរបស់សាវ័កប៉ុលគឺជាអំណាចដែលជាក់ស្តែង និង អស្ចារ្យ ។ អំណាចនោះអាចត្រូវបានបញ្ជូនតាមរយៈក្រណាត់ដើម្បីប្រោសលោះ និងប្រោសអ្នកជំងឺអោយជា ។

ខ. ចុះខ្ញុំវិញ តើមានអ្វីទាក់ទងជាមួយអំណាចនេះ ?

១. មនុស្សជាច្រើនបានគិតថា "មែនហើយ ខ្ញុំដឹងថាអំណាចនេះសណ្ឋិតនៅក្នុងព្រះយេស៊ូ ! ខ្ញុំដឹងថាអំណាចនេះសណ្ឋិតនៅក្នុងសាវ័កប៉ុល ។ ប៉ុន្តែ តើវាមានជាប់ទាក់ទងអ្វីនឹងខ្ញុំ ? ខ្ញុំគ្រាន់តែជាអ្នកជឿធម្មតាម្នាក់ប៉ុណ្ណោះ" ។

២. ព្រះយេស៊ូមានបន្ទូលថា "ប៉ុន្តែ កាលណាព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយធ្វើជាទីបន្ទាល់ពីខ្ញុំនៅក្រុងយេរូសាឡឹម ព្រមទាំងស្រុកយូដា និង ស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង" (កិច្ចការ ១:៨) ។

៣. ពាក្យថា "ព្រះចេស្តា"ដែលប្រើនៅក្នុងខនេះគឺពាក្យក្រិកថា "ដូណាមីស" ។ ព្រះយេស៊ូកំពុងមានបន្ទូលថា នៅពេលយើងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ យើងពិតជាទទួលបានអំណាចតែមួយដូចគ្នានឹងអំណាចដែលហូរចេញពីព្រះយេស៊ូចូលទៅក្នុងស្រីធ្លាក់ឈាមដែរ ។

៤. ក្នុងនាមជាអ្នកជឿដែលពេញដោយព្រះវិញ្ញាណ យើងពិតជាមានអំណាចដូចគ្នានឹងអំណាចដែលលោកប៉ុលមាននៅក្នុងខ្លួនរបស់លោក នៅពេលដែលគេយកកន្សែង ឬ ក្រណាត់មកប៉ះលោក ហើយយកទៅគ្រប់លើអ្នកជំងឺ ។

៥. ក្នុងនាមជាអ្នកជឿដែលពេញដោយព្រះវិញ្ញាណ យើងគឺជាឈើច្រត់នៃអំណាចដ៏អស្ចារ្យ !

## ៣. កុងតាក់នៃសេចក្តីជំនឿ

មនុស្សជាច្រើនបានសួរថា "ប្រសិនបើខ្ញុំមានអំណាចនោះនៅក្នុងខ្លួនរបស់ខ្ញុំពិតមែន ហេតុអ្វីក៏ខ្ញុំមិនឃើញមនុស្សជាច្រើនត្រូវបានប្រោសអោយជា ? ហេតុអ្វីក៏ខ្ញុំមិនមានការអស្ចារ្យនៅក្នុងជីវិតរបស់ខ្ញុំ ?" ។

ការនេះគឺដូចគ្នានឹងការដែលមនុស្សម្នាក់អង្គុយនៅក្នុងបន្ទប់ដ៏ងងឹតមួយដែលមានបណ្តាញអគ្គិសនី និង អំពូលអគ្គិសនីគ្រប់គ្រាន់នៅក្នុងនោះ ។ មនុស្សជាច្រើនកំពុងអង្គុយនៅក្នុងទីងងឹតនោះសព្វថ្ងៃនេះ ដោយមិនដឹងថាក្នុងខ្លួនរបស់ពួកគេមានអំណាចនោះទេ ។ ដូច្នេះ គេគ្រាន់តែបើកកុងតាក់ ហើយទុកអោយអំណាចនោះហូរប៉ុណ្ណោះ សេចក្តីជំនឿគឺជាកុងតាក់នោះហើយ !

ព្រះយេស៊ូបានមានបន្ទូលទៅកាន់ស្ត្រីដែលធ្លាក់ឈាមថា "ចូរសង្ឃឹមឡើងកូនស្រីអើយ ដ្បិតសេចក្តីជំនឿនាងបានសង្គ្រោះនាងហើយ ចូរនាងទៅដោយសុខសាន្តចុះ" ។ ការទទួល ឬ ការបើកអោយអំណាចនៃការប្រោសអោយជារបស់ព្រះជាម្ចាស់ហូរគឺជាការបើកកុងតាក់នៃសេចក្តីជំនឿ ។

ក. ស្ត្រីដែលធ្លាក់ឈាម

១. ឥឡូវនេះ សូមយើងបកទៅមើលរឿងរ៉ាវស្តីអំពីស្ត្រីធ្លាក់ឈាមនៅក្នុងម៉ាកុសជំពូកប្រាំឡើងវិញ ដើម្បីឃើញពីរបៀបដែលសេចក្តីជំនឿថា នឹងទទួលបានការប្រោសអោយជា ចូលមកក្នុងវិញ្ញាណរបស់នាង ។ ស្ត្រីម្នាក់នេះមានរោគធ្លាក់ឈាមជាង២០ឆ្នាំមកហើយ ។ យោងតាមច្បាប់ក្នុងសញ្ញាចាស់ នាងគឺជាស្ត្រីដែល "មិនស្អាត" ។ នាងត្រូវបានគេបំបែកចេញពីគ្រួសារ និង មិត្តភ័ក្តរបស់នាង ។ ប្រសិនបើមេដឹកនាំសាសនាឃើញនាងនៅទីសាធារណៈ នាងនឹងត្រូវគេគប់ដុំថ្មសម្លាប់ជាមិនខាន ។

២. ទោះបីជាមានគ្រូពេទ្យមួយណាអាចព្យាបាលនាងអោយជាក៏ដោយ ក៏នាងមិនអាចដើរចេញទៅកាន់ទីសាធារណៈបានដែរ លុះត្រាតែនាងទៅព្រះវិហារ ហើយធ្វើពិធីលាងជំរះអោយបានបរិសុទ្ធជាមុនសិន ។ ដូច្នេះ នាងឯកោ និង អស់សង្ឃឹមជាខ្លាំង ។

៣. ស្ត្រីនេះបានចំណាយប្រាក់ទាំងអស់ទៅលើការព្យាបាល ។ គ្រប់ពេល ក្តីសង្ឃឹមរបស់នាងត្រូវបានបំផ្លាញដោយការបាក់ទឹកចិត្ត ។ "គ្រូពេទ្យជាច្រើនបានព្យាបាលនាង តែនាងឈឺចុកចាប់រីតតែខ្លាំង ។ នាងបានចំណាយទ្រព្យសម្បត្តិទាំងប៉ុន្មានដែលនាងមាន តែជំងឺរបស់នាងនៅតែមិនបានធូរស្រាលទេ ផ្ទុយទៅវិញ នាងកាន់តែឈឺខ្លាំងឡើងៗ"(ម៉ាកុស ៥:២៦) ។

៤. ឥឡូវនេះ នាងអស់លុយហើយ បើទោះជាមានគ្រូពេទ្យជំនាញណាម្នាក់អាចជួយនាងបានក៏ដោយ ក៏នាងគ្មានលទ្ធភាពទៀតដែរ ។ នាងនឹងស្លាប់ទៅទាំងអស់សង្ឃឹម ។ នាងមិនបានធូរស្បើយឡើយ តែកាន់តែធ្ងន់ធ្ងរឡើង ។ នៅពេលនាងចុះខ្សោយពីមួយថ្ងៃទៅមួយថ្ងៃ ហើយនាងដឹងថា នាងនឹងស្លាប់ វាហាក់ដូចជាថា ក្តីសង្ឃឹមទាំងអស់បានរលាយអស់ហើយ ។

ខ. សេចក្តីជំនឿកើតឡើងតាមរយៈការឮព្រះបន្ទូល

១. ថ្ងៃមួយ នៅពេលនាងកំពុងដេកដោយអស់សង្ឃឹម នាងបានឮពីព្រះយេស៊ូ ។

ក. "នាងបានឮនិយាយពីព្រះយេស៊ូ ក៏ចូលមកក្នុងហ្វូងមនុស្សពីក្រោយ ទៅពាល់ព្រះពស្ត្រទ្រង់" (ម៉ាកុស ៥:២៧) ។ រឿងអស្ចារ្យបានកើតឡើងបន្ទាប់ពីនាងបានឮព្រះបន្ទូល ។

ខ. "ដូច្នេះ សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ" (រ៉ូម ១០:១៧) ។

២. ពាក្យជាភាសាក្រិកដែលបកប្រែថា "ព្រះបន្ទូល" នៅក្នុងខនេះគឺ "រ៉េម៉ា" (ព្រះបន្ទូលដែលមិនមានចែងនៅក្នុងព្រះគម្ពីរ) ។ ផ្ទុយពីព្រះបន្ទូលទូទៅរបស់ព្រះជាម្ចាស់ "ឡូកូស" (ព្រះបន្ទូលដែលមានចែងនៅក្នុងព្រះគម្ពីរ) ខគម្ពីរនេះបានចែងប្រាប់យ៉ាងច្បាស់ថា សេចក្តីជំនឿកើតឡើងតាមរយៈការស្តាប់ឮព្រះបន្ទូលដែលមិនមានចែងចែងទុកក្នុងព្រះគម្ពីរ (រ៉េមា) របស់ព្រះជាម្ចាស់ ។

៣. យើងដឹងថា ព្រះបន្ទូលមួយជាព្រះបន្ទូលដែលមិនមានចែងទុកក្នុងព្រះគម្ពីរ គឺនៅពេលដែលព្រះជាម្ចាស់<u>មានបន្ទូលមកកាន់វិញ្ញាណរបស់យើងដោយផ្ទាល់តាមរយៈការបើកសម្តែង</u> ។ ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើអោយព្រះបន្ទូលនោះរស់នៅក្នុងខ្លួនរបស់យើង ។ ខណៈនោះ យើងនឹងយល់ដឹងពីសេចក្តីពិតភ្លាម ហើយវាហាក់បីដូចជាភ្លើងទើបនឹងត្រូវបានបើកអោយឆេះ ។ យើងអាចនឹងលាន់មាត់ថា "អូ ! ព្រះជាម្ចាស់ទើបតែដាក់ខគម្ពីរថ្មីចូលក្នុងព្រះគម្ពីរខ្ញុំ ! ខ្ញុំមិនដែលធ្លាប់ឃើញខគម្ពីរនេះទេកាលពីមុន ។ នេះជាចម្លើយរបស់ខ្ញុំ !" ។

## ៤. ដំណើរការនៃសេចក្តីជំនឿ

នៅពេលស្ត្រីធ្លាក់ឈាមម្នាក់នេះបានឮពីព្រះយេស៊ូ នាងបានទទួលព្រះបន្ទូលរ៉េម៉ារបស់ព្រះជាម្ចាស់ ។ សេចក្តីជំនឿបានលោតចូលទៅក្នុងវិញ្ញាណរបស់នោង ហើយនាងបានសម្តែងចេញជាសកម្មភាព ។

គម្ពីរយ៉ាកុបបានចែងថា "...... សេចក្តីជំនឿដែលឥតមានការប្រព្រឹត្តតាម (សកម្មភាពឆ្លើយតប) នោះឈ្មោះថាស្លាប់ហើយ" (យ៉ាកុប ២:២០) ។

នៅពេលស្ត្រីម្នាក់នេះចេញដំណើរពីផ្ទះរបស់នាង ក្រុមគ្រួសាររបស់នាងប្រហែលជាព្យាយាមបញ្ឈប់នាងដោយនិយាយថា "ម៉ែ ត្រឡប់ទៅសំរាន្តយកកំលាំងលើគ្រែវិញទៅ ។ តើម៉ែមិនដឹងទេឬ ថាម៉ែនឹងស្លាប់ ? គេនឹងសម្លាប់ម៉ែដោយចោលនឹងដុំថ្ម ប្រសិនបើមេដឹកនាំសាសនាណាម្នាក់ឃើញម៉ែនោះ !" ។

នៅពេលសេចក្តីជំនឿកើតមាននៅក្នុងខ្លួនយើង យើងដឹងច្បាស់ថា យើងនឹងជាពីជំងឺ ។ នៅពេលសេចក្តីជំនឿកើតមានឡើង យើងក៏ដូចជាស្ត្រីម្នាក់នោះដែរ យើងមិនឈប់ឡើយ ។ ទោះបីជានាងមានសុខភាពទន់ខ្សោយក៏ដោយ ក៏នាងបានច្រានគេឯងនៅក្នុងហ្វូងមនុស្សពីក្រោយព្រះយេស៊ូដើម្បីរកផ្លូវទៅរកព្រះអង្គដែរ ។ ភ្លាម១នោះ នាងប្រហែលជាបានដឹងថា បុរសដែលនៅជាមួយព្រះយេស៊ូនោះគឺយៃរ៉ូស ដែលជាអ្នកដឹកនាំម្នាក់នៅក្នុងសាលាប្រជុំ ។ ទោះបីនាងដឹងថា ខ្លួនអាចនឹងត្រូវគេគប់នឹងដុំថ្មសម្លាប់ក៏ដោយ ក៏នាងមិនព្រមឈប់ដែរ ។ នាងបានឈោងដៃទៅកាន់អាវរបស់ព្រះយេស៊ូ ។

ក. សេចក្តីជំនឿនឹងនិយាយសំដីដែលពេញដោយសេចក្តីជំនឿ

១. បើជាសេចក្តីជំនឿមែន នោះនឹងត្រូវនិយាយចេញ ។ លោកប៉ុលបានថែងថា "តែសេចក្តីសុចរិតដែលមកដោយសេចក្តីជំនឿនោះថាដូច្នេះវិញ........." (រ៉ូម ១០:៦) ។

២. ស្ត្រីនោះពុំបានស្រដីដោយមានទុក្ខព្រួយទេ ប៉ុន្តែ នាងបានស្រដីដោយមានសេចក្តីជំនឿ ។ នាងបានប្រកាសដោយក្លាហានឡើងថា "បើគ្រាន់តែពាល់ព្រះពស្ត្រទ្រង់ប៉ុណ្ណោះ នោះនឹងបានជាហើយ" (ម៉ាកុស ៥:២៨) ។

ខ. សេចក្តីជំនឿគឺនៅពេលឥឡូវនេះ

១. ប្រសិនបើជាសេចក្តីជំនឿមែន នោះគឺកើតនៅពេលឥឡូវនេះ ។ កណ្ឌគម្ពីរហេព្រើរ ១១:១ បានចាប់ផ្តើមដោយពាក្យថា "រីឯសេចក្តីជំនឿ....." ។ "រីឯសេចក្តីជំនឿនោះគឺជាចិត្តដែលដឹងជាក់ថានឹងបានដូចសង្ឃឹម ជាសំគាល់ពីការដែលមើលមិនឃើញ" ។

២. ស្ត្រីនោះបានដឹងថា បើគ្រាន់តែពាល់ជាយព្រះពស្ត្រព្រះយេស៊ូ នាងនឹងបានជាភ្លាម ។ នៅពេលដែលស្ត្រីនោះបានពាល់ព្រះយេស៊ូដោយសេចក្តីជំនឿដែលមិនអាចឃាត់បាន និង ដែលបានជំរុញអោយនាងនិយាយពាក្យសំដីដែលពេញដោយសេចក្តីជំនឿយ៉ាងក្លាហាន អំណាចដ៏អស្ចារ្យដែលស្ថិតនៅក្នុងព្រះយេស៊ូបានហូរចូលមកក្នុងរូបកាយរបស់នាង ។ នាងក៏បានជាសះស្បើយភ្លាម ។ ព្រះយេស៊ូវបានលាន់មាត់ឡើងថា "កូនស្រីអើយ សេចក្តីជំនឿនាងបានជួយសង្គ្រោះនាងហើយ ចូរទៅអោយបានប្រកបដោយសេចក្តីសុខចុះ ហើយអោយនាងបានរួចពីសេចក្តីវេទនារបស់នាងទៅ" (ម៉ាកុស ៥:៣៤) ។

៣. នៅពេលសេចក្តីជំនឿកើតឡើង អ្វីដែលយើងសង្ឃឹមនោះនឹងក្លាយទៅជាការពិត ។

គ. សេចក្តីជំនឿបើកអោយអំណាចនៃការប្រោសអោយជាហូរ

ព្រះយេស៊ូមានបន្ទូលថា "អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងមានទន្លេទឹករស់ហូរចេញពីពោះខ្លួនមក ។ តែសេចក្តីនេះគឺទ្រង់មានព្រះបន្ទូលពីព្រះវិញ្ញាណ ........" (យ៉ូហាន ៧:៣៨-៣៩) ។

**សង្ខេប :**

- យើងដែលជាអ្នកជឿ និង ដែលពេញដោយអំណាចដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ត្រូវតែស្តាប់បង្គាប់ព្រះយេស៊ូ ។

- យើងត្រូវដាក់ដៃរបស់យើងលើអ្នកជំងឺ ។

- យើងត្រូវតែបើកកុងតាក់នៃសេចក្តីជំនឿ ហើយទុកអោយអំណាចនៃការប្រោសអោយជាហូរចេញមក ។

- នៅពេលយើងធ្វើដូច្នេះ ព្រះជាម្ចាស់នឹងគង់នៅជាមួយយើង ហើយបញ្ជាក់ព្រះបន្ទូលរបស់ព្រះអង្គជាមួយនឹងទីសំគាល់ផ្សេងៗ ។

- "ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់ហួសពីសេចក្តីសុំ និង ហួសពីអ្វីៗដែលយើងនឹកគិតដោយឫទ្ធានុភាពរបស់ព្រះអង្គដែលបំពេញសកម្មភាពនៅក្នុងយើង" (អេភេសូរ ៣:២០) ។

## ការពិភាក្សាជាក្រុម

១. សព្វថ្ងៃនេះ ហេតុអ្វីបានជាមនុស្សជាច្រើនបានសារភាពសេចក្តីជំនឿរបស់ពួកគេហើយ តែនៅតែមិនបានទទួលអំណាចនៃការប្រោសអោយជាដែលយើងបានរៀននៅក្នុងមេរៀននេះ ?

២. តើយើងបើកកុងតាក់នៃសេចក្តីជំនឿនៅក្នុងជីវិតយើងដើម្បីទទួលការហូរចេញនៃអំណាចនៃការប្រោសអោយជារបស់ព្រះជាម្ចាស់ដោយរបៀបណាទៅ ?

៣. សព្វថ្ងៃនេះ ក្នុងនាមយើងជាអ្នកជឿដែលពេញដោយព្រះវិញ្ញាណ តើវាជាការពិតដែរឬទេ ដែលថាយើងមានអំណាចដូចគ្នានឹងអំណាចដែលលោកប៉ុលមាននៅក្នុងសម័យកាលរបស់លោក ? ប្រសិនបើជាការពិតមែន តើយើងអាចបើកអោយអំណាចនេះហូរចូលទៅក្នុងជីវិត និង ស្ថានភាពរបស់មនុស្សយ៉ាងដូចម្តេចទៅ ?

## ការសិក្សាដោយខ្លួនឯង

១. សូមសិក្សាអត្ថបទគម្ពីរដែលនិយាយអំពីការប្រោសអោយជាខាងក្រោម រួចសរសេរពីវិធីសាស្ត្រដែលប្រើនៅក្នុងអត្ថបទគម្ពីរនិមួយៗ :

ជនគណនា ២១:៤-៩

២ ពង្សាវតារក្សត្រ ៥:១-១៤

អេសាយ ៣៨:១-៤, ២១

ម៉ាកុស ៥:២៥-៣៤

យ៉ូហាន ៩:១-៧

កិច្ចការ ១៩:១១-១២

២. តើលោកអ្នកអាចគិតឃើញពីកន្លែងដទៃទៀតនៅក្នុងខគម្ពីរដែលប្រើប្រាស់វិធីសាស្ត្រទាំងនេះដែរឬទេ?

៣. តើលោកអ្នកអាចរៀនបានអ្វីខ្លះពីគំរូស្តីអំពីវិធីសាស្ត្រក្នុងការប្រោសអ្នកជំងឺអោយជារបស់ព្រះជាម្ចាស់ ?

# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី៩ ៖ ការអធិប្បាយព្រះបន្ទូលនៃការប្រោសអោយជា

## សេចក្តីផ្តើម

មានអំណាចដ៏អស្ចារ្យនៅក្នុងពាក្យសំដីដែលយើងនិយាយ ។ ពាក្យសំដីអវិជ្ជមានរបស់យើងអាចនាំអោយមានមហន្តរាយ ។ "ពាក្យសំដីដែលចេញពីមាត់មនុស្ស ធៀបដូចជាទឹកជ្រៅ ហើយទីបញ្ចេញប្រាជ្ញាក៏ដូចជាជ្រោះទឹកហូរ ។ មាត់របស់មនុស្ស ល្ងីល្ងើជាហេតុនាំអោយខ្លួនត្រូវវិនាសទៅ ហើយបបូរមាត់ក៏ជាអន្ទាក់ដល់ព្រលឹងខ្លួនដែរ" (សុភាសិត ១៨:៤, ៧) ។

តាមរយៈពាក្យសំដីដែលយើងនិយាយ យើងបើកអោយមានអំណាចនៃសេចក្តីស្លាប់ រឺ អំណាចនៃជីវិត ។

"មនុស្សនឹងបានឆ្អែតពោះ ដោយផលនៃមាត់ខ្លួន គឺនឹងបានស្កប់ចិត្ត ដោយផលចំរើននៃបបូរមាត់ ។ ទោះទាំងសេចក្តីស្លាប់ ហើយនឹងជីវិតក៏នៅក្នុងអំណាចនៃអណ្តាតដែរ អ្នកណាដែលចូលចិត្តប្រើ នោះនឹងស៊ីផលនៃអណ្តាតនោះឯង" (សុភាសិត ១៨:២០-២១) ។

យើងបានសិក្សាពីមេរៀនមុនថា សេចក្តីជំនឿ ដូចជាសេចក្តីជំនឿរបស់ស្ត្រីដែលធ្លាក់ឈាម តែងតែនិយាយ ។ នៅពេលសេចក្តីជំនឿនិយាយ រឿងអស្ចារ្យជាច្រើននឹងកើតឡើង ។ នៅពេលយើងដាក់ដៃលើអ្នកជំងឺ យើងបើកកុងតាក់នៃសេចក្តីជំនឿ ហើយបើកអោយអំណាចរបស់ព្រះជាម្ចាស់ហូរ ។

## គំរោងមេរៀន

១. ការប្រោសអោយជាតាមរយៈការប្រកាសព្រះនាមព្រះយេស៊ូ (ភីលីព ២:៩:១១)

ក. សិទ្ធិប្រើព្រះនាមព្រះយេស៊ូ

ជំងឺទាំងអស់មានឈ្មោះ ។ ជំងឺមហារីកគឺជាឈ្មោះ ។ ជំងឺសន្លាក់ឆ្អឹងគឺជាឈ្មោះ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះនាមរបស់ព្រះយេស៊ូគឺជានាមដែលលើសអស់ទាំងនាមនានា ។ នៅពេលយើងប្រកាសព្រះនាមព្រះយេស៊ូដោយសេចក្តីជំនឿគ្រប់ទាំងជំងឺត្រូវតែអោនចុះ ! ជំងឺមហារីកត្រូវតែអោនចុះ ។ ជំងឺសន្លាក់ឆ្អឹងត្រូវតែអោនចុះ !

ព្រះយេស៊ូប្រទានសិទ្ធិអោយយើងប្រកាសព្រះនាមរបស់ព្រះអង្គ ។ ព្រះអង្គមានបន្ទូលថា "ទីសំគាល់ទាំងនេះនឹងតាមអស់អ្នកដែលជឿ.....ហើយគេនឹងដាក់ដៃលើមនុស្សជំងឺអោយបានជាផង" (ម៉ាកុស ១៦: ១៧-១៨) ។

ខ. បុរសខ្វិនជើងពីកំណើតត្រូវបានប្រោសអោយជាដោយព្រះនាមព្រះយេស៊ូ (កិច្ចការ ៣:៦-៨)

គន្លឹះក្នុងការប្រោសបុរសនោះអោយជាគឺជាសេចក្តីជំនឿរបស់លោកពេត្រុស និង លោកយ៉ូហានលើព្រះនាមរបស់ព្រះយេស៊ូ ។ លោកពេត្រុសមានប្រសាសន៍ថា "ហើយគឺដោយសារ សេចក្តីជំនឿជឿដល់ព្រះ

នាមទ្រង់ នោះព្រះនាមទ្រង់បានប្រោសមនុស្សនេះ ដែលអ្នករាល់គ្នាឃើញ ហើយស្គាល់ អោយមានកំឡាំងឡើង គឺជាសេចក្តីជំនឿដែលកើតមកដោយសារព្រះអង្គនោះឯង បានធ្វើអោយគាត់ជាស្រឡះនៅមុខអ្នករាល់គ្នា ដូច្នេះ" (កិច្ចការ ៣:១៦) ។

## ២. ការប្រោសអោយជាតាមរយៈការបញ្ចេញវិញ្ញាណនៃជំងឺអោយចេញ !

មារសាតាំង ដែលមកដើម្បីលួច សម្លាប់ និង បំផ្លាញ តែងតែចាត់អោយមានវិញ្ញាណនៃជំងឺផ្សេងៗ ដើម្បីនាំយកចំណងនៃជំងឺ និង សេចក្តីស្លាប់មកដាក់លើមនុស្ស (លូកា ១៣:១១-១៣) ។

នៅពេលពួកមេដឹកនាំសាសនាប្រឆាំងនឹងព្រះយេស៊ូពីការដែលព្រះអង្គប្រោសអ្នកជំងឺអោយជានៅថ្ងៃសប្ប័ទ ព្រះអង្គបានមានបន្ទូលតបវិញថា "ឯស្ត្រីនេះ ជាពូជលោកអ័ប្រាហាំ ដែលអារក្សសាតាំងបានចងគាត់១៨ឆ្នាំហើយ ដូច្នេះ តើមិនគួរនឹងស្រាយអោយរួចពីចំណងនេះនៅថ្ងៃឈប់សំរាកដែរទេឬអី ? " ។

ក. ព្រះយេស៊ូប្រោសអោយជាតាមរយៈការដេញវិញ្ញាណអាក្រក់ចេញ

១. "........ព្រះបានចាក់ព្រះវិញ្ញាណបរិសុទ្ធ និង ព្រះចេស្តាអោយមកសណ្ឋិតលើទ្រង់ ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងបានប្រោសអោយអស់អ្នក ដែលត្រូវអារក្សសង្កត់សង្កិនបានជាផង..."(កិច្ចការ ១០:៣៨) ។

- ភាគច្រើននៃព័ន្ធកិច្ចរបស់ព្រះយេស៊ូគឺការដេញវិញ្ញាណអាក្រក់ចេញ ។

២. វិញ្ញាណនៃជំងឺគ ។ "កំពុងដែលអ្នកទាំងពីរចេញទៅ នោះមានគេនាំមនុស្សគ ដែលមានអារក្សចូលមកឯទ្រង់ រួចកាលបានដេញអារក្សចេញហើយ នោះមនុស្សគបាននិយាយឡើងបាន" ។ (ម៉ាថាយ ៩:៣២-៣៣) ។

៣. ជំងឺគ និង ថ្លង់ ។ "........នោះទ្រង់កំហែងទៅអារក្សអសោចថា នែ៎ អារក្សគថ្លង់អើយ អញបង្គាប់អោយឯងចេញពីវាទៅ កុំអោយចូលវាទៀតឡើយ វាក៏ស្រែកឡើងទាំងជាន់ក្មេងនោះអោយប្រកាច់ជាខ្លាំង រួចក៏ចេញទៅ" (ម៉ាកុស ៩:២៥-១៦) ។

៤. ជំងឺឆ្កួតជ្រូក ។ ក្មេងប្រុសដែលមានជំងឺឆ្កួតជ្រូកបានរងទុក្ខវេទនាក្រៃលែងដោយសារអារក្សចេះតែធ្វើអោយក្មេងនោះដួលទៅក្នុងភ្លើង និង ក្នុងទឹក ។ "នោះព្រះយេស៊ូវទ្រង់បន្ទោសដល់អារក្ស ហើយវាក៏ចេញពីក្មេងនោះទៅ រួចក្មេងនោះបានជាចាប់តាំងពីវេលានោះមក" (ម៉ាថាយ ១៧:១៨) ។

៥. ជំងឺខ្វាក់ និង គ ។ "នោះគេនាំមនុស្សម្នាក់មានអារក្សចូល ដែលខ្វាក់ហើយគ មកឯទ្រង់ ទ្រង់ក៏ប្រោសអោយបានជា គឺអោយមនុស្សខ្វាក់ហើយគនោះបានទាំងនិយាយ ហើយមើលឃើញ ផង" (ម៉ាថាយ ១២:២២) ។

ខ. ព្រះយេស៊ូប្រោសអោយជាតាមរយៈការដេញអារក្សចេញ

១.	ប្រភេទជំងឺដែលជំនាញពេទ្យហៅថា "ជំងឺដែលមិនអាចព្យាបាលបាន" គឺតែងតែបណ្តាលមកពីវិញ្ញាណនៃជំងឺ ។ យើងអាចស្គាល់ និង ដេញវិញ្ញាណទាំងនោះចេញបានតាមរយៈការអនុវត្តអំណោយទាននៃការស្គាល់អស់ទាំងវិញ្ញាណ ។

២.	"ទីសំគាល់ទាំងនេះ នឹងជាប់តាមអស់អ្នកដែលជឿ គឺថាគេនឹងដេញអារក្សដោយនូវឈ្មោះខ្ញុំ.......” (ម៉ាកុស ១៦:១៧) ។

៣.	ព្រះយេស៊ូវបានប្រទានអំណាចអោយយើងចង និង ស្រាយចំណងនៅលើលោកីយ៍នេះ ។ ព្រះយេស៊ូវមានបន្ទូលថា "ខ្ញុំនឹងអោយកូនសោរនៃនគរស្ថានសួគ៌ដល់អ្នក បើអ្នកនឹងចងទុកអ្វីៗនៅលើផែនដី នោះនឹងត្រូវចងទុកនៅលើស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ" (ម៉ាថាយ ១៦:១៩) ។

៤.	ដោយយើងមានអំណាចទាំងនេះ យើងអាចប្រកាសថា "អារក្សសាតាំង យើងនឹងចងឯងនៅក្នុងព្រះនាមព្រះយេស៊ូ ! វិញ្ញាណនៃជំងឺមហារីកអើយ យើងបញ្ជាអោយឯងចេញពីមនុស្ស នេះដោយក្នុងព្រះនាមព្រះយេស៊ូ!" ។ យើងក៏អាចប្រកាសផងដែរថា "នាងអើយ នាងត្រូវបានស្រាយពីចំណងនៃជំងឺរបស់នាងហើយ" ។

## ៣.	ការប្រកាសពីការអស្ចារ្យនៃការបង្កើត

មនុស្សជាច្រើនបាត់ផ្នែកខ្លះនៃរូបកាយរបស់ពួកគេតាំងពីកំណើត ដោយគ្រោះថ្នាក់ ឬដោយការវះកាត់ ។ ព្រះជាម្ចាស់ ដែលបានបង្កើតយើងអោយមានរូបកាយដូចព្រះអង្គបានបង្កើតយើងដោយព្រះបន្ទូល ដែលចេញពីមាត់របស់ព្រះអង្គ ។ ដូច្នេះ យើងក៏អាចធ្វើការអស្ចារ្យនៃការបង្កើតដោយនៅក្នុងព្រះនាមរបស់ព្រះយេស៊ូតាមរយៈពាក្យសំដីដែលយើងនិយាយប្រកបដោយសេចក្តីជំនឿផងដែរ ។ លោកអេសាយបានសរសេរថា ".....អញដែលបង្កើតពាក្យចេញពីបបូរមាត់....." (អេសាយ ៥៧:១៩) ។ ខគម្ពីរនេះបានបញ្ចប់ដោយពាក្យថា "អញនឹងប្រោសគេអោយជា" ។

ក.	លោកអ្នកប្រោសអ្នកជំងឺអោយជា !

១.	មនុស្សជាច្រើនបាននិយាយថា " ខ្ញុំមិនអាចព្យាបាលជំងឺថៃបានទេ" ។ ទោះជាយ៉ាងណាក៏ដោយព្រះយេស៊ូមានបន្ទូលថា "......អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ......" (យ៉ូហាន ១៤:១២) ។

២.	ព្រះយេស៊ូបានមានបន្ទូលទៅកាន់បុរសស្វិតដៃថា "ចូរលាតដៃអ្នកមើល៍ ។ បុរសនោះលាតដៃហើយដៃរបស់គាត់ក៏បានជាដូចដើមវិញ" (ម៉ាកុស ៣:៥) ។

៣.	ព្រះយេស៊ូបានប្រទានអំណាចដើម្បីប្រោសអោយជាដូចគ្នានេះដែរដល់សិស្សរបស់ព្រះអង្គ ។

៤.	"ព្រះយេស៊ូត្រាស់ហៅសាវ័កទាំងដប់ពីររូបមក ព្រះអង្គប្រទានអោយគេមានអំណាចដេញខ្មោចព្រមទាំងមានអំណាចប្រោសអ្នកជំងឺគ្រប់យ៉ាង និង អ្នកពិការគ្រប់ប្រភេទអោយបានជាផង" (ម៉ាថាយ ១០:១) ។

៥. ព្រះយេស៊ូក៏បានបញ្ជាតទៀតថា "ចូរមើលអ្នកជំងឺអោយបានជា ប្រោសមនុស្សស្លាប់អោយរស់ឡើងវិញ ធ្វើអោយមនុស្សឃ្លង់បានជាស្អាតបរិសុទ្ធ ដេញខ្មោចចេញពីមនុស្ស ។ អ្នករាល់គ្នាបានទទួលអំណាចដោយឥតបង់ថ្លៃត្រូវជួយគេវិញដោយឥតគិតថ្លៃដែរ" ( ម៉ាថាយ ១០:៨) ។

ខ. និយាយទៅកាន់ភ្នំ

១. "ព្រះយេស៊ូវទ្រង់ឆ្លើយថា ចូរមានសេចក្តីជំនឿដល់ព្រះចុះ ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នកណានិយាយទៅកាន់ភ្នំនេះថា ចូររើចេញពីទីនេះទៅធ្លាក់ក្នុងសមុទ្រចុះ ដោយឥតសង្ស័យក្នុងចិត្ត គឺជឿជាក់ថា សេចក្តីអ្វីដែលខ្លួនថា នឹងបានកើតមកពិត នោះនឹងបានដូចប្រាថ្នាគ្រប់ជំពូកទាំងអស់" ( ម៉ាកុស ១១:២២-២៣) ។

២. ជារឿយៗ "ជំងឺដែលមិនអាចព្យាបាលបាន"ហើយត្រូវការការអស្ចារ្យនៃការបង្កើត គឺប្រៀបដូចជាភ្នំចំពោះអស់អ្នកដែលត្រូវការការប្រោសអោយជា រឺ ដល់អស់អ្នកដែលគេសុំអោយប្រោសអ្នកទាំងនោះអោយជា ។ ខគម្ពីរនេះមិនមែននិយាយថា យើងត្រូវអធិស្ឋានអោយភ្នំនេះរើចេញទេ ។ យើងត្រូវ "និយាយទៅកាន់ភ្នំនេះថា ចូររើចេញពីទីនេះទៅធ្លាក់ក្នុងសមុទ្រចុះ" និយាយនេះគឺសំដៅលើការបញ្ជាដោយអំណាច !

៣. នៅពេលជួបប្រទះកាលៈទេសៈទាំងនេះ មនុស្សជាច្រើនហាក់ដូចជាជឿថា យើងត្រូវតែ "អធិស្ឋាន" ហើយសុំព្រះជាម្ចាស់អោយប្រោសអោយជា ។ តែខគម្ពីរនេះមិនបានចែងថា "អធិស្ឋាន"នោះទេ ។ ប៉ុន្តែ ចែងថា "និយាយ" វិញ ។ នៅក្នុងព័ន្ធកិច្ចរបស់ព្រះយេស៊ូ រឺ នៅក្នុងកណ្ឌគម្ពីរកិច្ចការ មិនមានឧទាហរណ៍ស្តីអំពីការដែលអ្នកណាម្នាក់ត្រូវបានប្រោសអោយជាដោយសារយើងអធិស្ឋានសម្រាប់ពួកគេនោះទេ ។

៤. សព្វថ្ងៃនេះ ព្រះយេស៊ូកំពុងមានបន្ទូលទៅកាន់អស់អ្នកជឿដែលពេញដោយព្រះវិញ្ញាណថា "ខ្ញុំបានប្រទានអោយអ្នករាល់គ្នានូវអំណាចដូចខ្ញុំដែរ គឺអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ និង អំណាច នៃការអធិប្បាយរបស់ខ្ញុំ ។ ចូរប្រោសអ្នកជំងឺអោយជា ! ចូរដាក់ដៃរបស់អ្នកលើអ្នកជំងឺ នោះពួកគេនឹងជាសះស្បើយ " ។

## ៤. ការប្រោសអោយជាតាមរយៈការអធិប្បាយព្រះបន្ទូល

- "ទ្រង់ចាត់ព្រះបន្ទូលទៅប្រោសគេអោយជា ក៏ដោះអោយគេរួចពីសេចក្តីវិនាស" (ទំនុកតម្កើង ១០៧:២០) ។

ក. អធិប្បាយព្រះបន្ទូលដោយសេចក្តីជំនឿ

យើងផ្សព្វផ្សាយព្រះបន្ទូលតាមរយៈការអធិប្បាយយ៉ាងក្លាហានចេញពីមាត់របស់យើង ។ នៅពេលយើងអធិប្បាយព្រះបន្ទូលដោយសេចក្តីជំនឿ ព្រះបន្ទូលពិតជានឹងបង្កើតផលផ្លែ ( អេសាយ ៥៥:១០-១១, រ៉ូម ១០:៨-១១ ) ។

ខ. គ្រាន់តែមានបន្ទូលមួយព្រះឱស្ឋមក នោះបាវទូលបង្គំនឹងបានជាហើយ ( ម៉ាថាយ ៨:៥-៨)

១.	គំរូដ៏ប្រសើរបំផុតនៃ "កុងតាក់" សេចក្តីជំនឿ គឺជាសេចក្តីជំនឿដែលស្គាល់អំណាច ។

២.	មេទ័ពក៏បានបន្តដោយនិយាយថា គាត់យល់ច្បាស់ពីអំណាចនៃការអធិប្បាយព្រះបន្ទូល ព្រោះខ្លួនគាត់ផ្ទាល់ក៏ស្ថិតនៅក្រោមអំណាចនេះដែរ ។

៣.	"កាលព្រះយេស៊ូបានឮពាក្យនោះហើយ ទ្រង់មានសេចក្តីអស្ចារ្យក្នុងព្រះហឫទ័យ រួចមានបន្ទូលទៅពួកអ្នកដែលតាមទ្រង់ថា "ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំមិនដែលឃើញសេចក្តីជំនឿជាខ្លាំងដល់ម៉្លេះទេ ទោះទាំងនៅក្នុងសាសន៍អ៊ីស្រាអែលផង" " (ម៉ាថាយ ៨:១០) ។

**សង្ខេប :**

- នៅពេលយើងប្រោសអ្នកណាម្នាក់អោយជា យើងត្រូវតែអធិប្បាយព្រះបន្ទូលដោយសេចក្តីជំនឿ ។

- យើងត្រូវតែប្រកាសព្រះនាមព្រះយេស៊ូ !

- យើងត្រូវតែបញ្ជាវិញ្ញាណអាក្រក់នៃជំងឺ អោយចេញ !

- យើងត្រូវតែប្រកាសពីការអស្ចារ្យនៃការបង្កើត ហើយយើងត្រូវតែអធិប្បាយព្រះបន្ទូលរបស់ព្រះអង្គ ។

- សេចក្តីជំនឿដែលនិយាយ និង សម្តែងចេញដោយក្លាហាន គឺជាកុងតាក់ដែលបើកអោយអំណាចហូរ !

## ការពិភាក្សាជាក្រុម

១. តើអ្នកណាទទួលសិទ្ធិដើម្បីប្រើអំណាចនៃព្រះនាមព្រះយេស៊ូ ?

២. ព្រោះតែព្រះគ្រិស្តបានបញ្ជា និង ផ្តល់អោយយើងនូវអំណាចនៃព្រះនាមរបស់ព្រះអង្គដើម្បីអោយយើងអាចប្រោសអ្នកជំងឺអោយជា តើយើងគួរតែអធិស្ឋានសុំអោយព្រះអង្គយាងមកដើម្បីប្រោសអ្នកជំងឺអោយជាទៀតទេ ?

៣. ចូរពិភាក្សាពីប្រយោគខាងក្រោមនេះ :
"នៅក្នុងព័ន្ធកិច្ចរបស់ព្រះយេស៊ូ រឺ នៅក្នុងកណ្ឌគម្ពីរកិច្ចការ មិនមានឧទាហរណ៍ស្តីអំពីការដែលអ្នកណាម្នាក់ត្រូវបានប្រោសអោយជាដោយសារយើងអធិស្ឋានសម្រាប់ពួកគេនោះទេ "។

ប្រសិនបើមាននរណាម្នាក់នៅក្នុងក្រុមរបស់លោកអ្នកមានភ្នំនៃបញ្ហា រឺ ជំងឺណាមួយ សូមប្រើអំណាចនៃព្រះបន្ទូលនៃសេចក្តីជំនឿនៅក្នុងមាត់របស់លោកអ្នក ហើយនិយាយទៅកាន់ភ្នំនោះថា "ចូររើចេញ" ។

## ការសិក្សាដោយខ្លួនឯង

វិធីមួយដើម្បីរីកចំរើនខាងវិញ្ញាណគឺការបង្កើតអោយមានទម្លាប់មួយដូចអ្នកក្រុងបេរានៅក្នុង កិច្ចការ ១៧:១០-១១ ។ សូមយកព្រះគម្ពីររបស់លោកអ្នកមក រួចស្វែងរកខគម្ពីរយោងដែលនិយាយអំពីការប្រោសអោយជានៅក្នុងកណ្ឌ គម្ពីរដំណឹងល្អ និង កណ្ឌគម្ពីរកិច្ចការ ។

តើលោកអ្នកអាចរកឃើញឧទាហរណ៍ណាមួយដែលនរណាម្នាក់ត្រូវបានគេអធិស្ឋានអោយមុនពេលទទួលការប្រោសអោយជាដែរឬទេ ? បើមាន ចូររៀបរាប់ខគម្ពីរយោងទាំងនោះនៅខាងក្រោមនេះ ។

# ការរស់នៅដោយអស្ចារ្យ
# មេរៀនទី១០ ៖ ការចែកចាយតាមរយៈការដាក់ដៃ

## សេចក្តីផ្តើម

ការអស្ចារ្យនឹងកើតឡើងនៅពេលយើងធ្វើតាមព្រះវិញ្ញាណ ហើយដាក់ដៃលើមនុស្សណាម្នាក់ដោយសេចក្តីជំនឿ ។ ការចែកចាយដ៏ពិតប្រាកដនឹងកើតមានឡើង ។ ការដាក់ដៃបង្កើតអោយមានការតភ្ជាប់សម្រាប់អោយការបញ្ជូនអំណាចរបស់ព្រះជាម្ចាស់ហូរ ។ នេះត្រូវបានគេហៅថា ច្បាប់នៃការតភ្ជាប់ និង ការបញ្ជូន ។

ព្រះយេស៊ូមានបន្ទូលថា "....បើគេដាក់ដៃលើអ្នកជំងឺ អ្នកជំងឺនឹងបានជាសះស្បើយ" (ម៉ាកុស ១៦:១៨) ។

## គំរោងមេរៀន

### ១. គំរូនៃការដាក់ដៃនៅក្នុងព្រះគម្ពីរ

គោលការណ៍ជាមូលដ្ឋាន ៖ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានពិពណ៌នាការដាក់ដៃថាជាគោលការណ៍មួយក្នុងចំណោម គោលការណ៍ជាមូលដ្ឋានផ្សេងៗរបស់ព្រះគ្រីស្ត (ហេព្រើរ ៦:១-២) ។

ការបញ្ជូនបាបទៅអោយសត្វពពែ ៖ នៅថ្ងៃធ្វើអោយបានធួន លោកអើរ៉ុន ដែលជាសម្តេចសង្ឃ បានដាក់ដៃទាំងពីររបស់លោកលើក្បាលពពែរស់ ហើយបានលន់តួអស់ទាំងសេចក្តីទុច្ចរិត និង សេចក្តីរំលងរបស់កូនចៅអ៊ីស្រាអែល (លេវីវិន័យ ១៦:២១)។ សត្វពពែគឺជារូបភាពមួយនៃព្រះគ្រិស្តដែលបានទទួលយកសេចក្តីទុច្ចរិត និង សេចក្តីរំលងរបស់មនុស្ស ។

វិញ្ញាណនៃប្រាជ្ញាត្រូវបានបញ្ជូនមកអោយលោកយ៉ូស្វេ "ឯយ៉ូស្វេជាកូននុន លោកមានចិត្តពេញដោយប្រាជ្ញា ពីព្រោះម៉ូសេបានដាក់ដៃលើលោក ........" (ចោទិយកថា ៣៤:៩) ។

ក. ពិធីបុណ្យជ្រមុជទឹក និង ការចែកចាយអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

១. លោកប៉ុលបានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធដល់ពួកអ្នកជឿនៅក្រុងអេភេសូរដោយការដាក់ដៃ ។

២. "រួចប៉ុលដាក់ដៃលើគេ ហើយព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើគេ នោះគេចាប់តាំងនិយាយភាសាដទៃ ហើយអធិប្បាយផង" (កិច្ចការ ១៩:៦) ។

៣. លោកប៉ុលបានបញ្ជូនអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដល់លោកធីម៉ូថេដោយការដាក់ដៃ។

៤. "ដោយហេតុនោះ បានជាខ្ញុំរំឭកដល់អ្នកអោយដាស់តឿនអំណោយទានរបស់ព្រះ ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ" (២ធីម៉ូថេ ១:៦) ។

ខ. ការដាក់ដៃលើមិនត្រូវធ្វើដោយងាយៗឡើយ

១. លោកប៉ុលបានសរសេរទៅកាន់លោកធីម៉ូថេថា "កុំអោយប្រញាប់ដាក់ដៃលើអ្នកណា..."(១ ធីម៉ូថេ ៥:២២) ។

២. មុនពេលយើងដាក់ដៃលើអ្នកណាម្នាក់សម្រាប់ការទទួលស្គាល់នៅក្នុងព័ន្ធកិច្ច យើងត្រូវប្រុងប្រយ័ត្ន ។ ដំបូង យើងត្រូវដឹង និង ទទួលស្គាល់អត្តចារិក ក៏ដូចជាផលផ្លែនៃព័ន្ធកិច្ចរបស់ពួកគេសិន ។ លោកប៉ុលបានសរសេរថា "....យើងខ្ញុំអង្វរអ្នករាល់គ្នាថា ចូរចំណាំអោយស្គាល់ពួកអ្នកដែលខំធ្វើកិច្ចការក្នុងពួកអ្នករាល់គ្នា....." (១ ថែស្សាឡូនីច ៥:១២) ។

គ. ព្រះយេស៊ូប្រោសអោយជាដោយការដាក់ដៃ

១. មនុស្សកើតឃ្លង់ : "គ្រានោះ មានមនុស្សឃ្លង់ម្នាក់មកឯព្រះយេស៊ូវ លុតជង្គង់ទូលអង្វរថា បើទ្រង់សព្វព្រះហឫទ័យ ទ្រង់អាចនឹងប្រោសអោយទូលបង្គំជាស្អាតបាន ដូច្នេះ ទ្រង់មានព្រះហឫទ័យក្តួលអាណិត ក៏លូកព្រះហស្តទៅពាល់គាត់ដោយបន្ទូលថា ខ្ញុំចង់ដែរ អោយជាស្អាតទៅ" (ម៉ាកុស ១:៤០-៤១) ។

២. កូនស្រីរបស់លោកយ៉ៃរ៉ូស : នៅពេលព្រះយេស៊ូធ្វើដំណើរទៅជាមួយនឹងលោកយ៉ៃរ៉ូសដើម្បីប្រោសកូនស្រីរបស់លោកអោយមានជីវិតរស់ឡើងវិញ ដំបូង ព្រះអង្គបានបណ្តេញពួកអ្នកចំអក និង ពួកអ្នកដែលមិនជឿ ។ "ព្រះអង្គចាប់ដៃក្មេងស្រីនោះ ទាំងមានព្រះបន្ទូលថា "ថាលីថាគូម" (ប្រែថា នាងតូចអើយ ខ្ញុំប្រាប់នាងថា ចូរក្រោកឡើង) ។ ក្មេងស្រីក៏ក្រោកឡើងដើរមួយរំពេច ដ្បិតនាងមានអាយុដប់ពីរឆ្នាំហើយ" (ម៉ាកុស ៥:៤១-៤២) ។

៣. បុរសគថ្លង់ : ព្រះយេស៊ូបានប្រោសបុរសគថ្លង់អោយជាដោយការដាក់ម្រាមដៃរបស់ព្រះអង្គលើផ្នែករាងកាយរបស់គាត់ដែលទទួលការប៉ះទង្គិច ។ "ព្រះអង្គបានយកអង្គុលីព្រះហស្តដាក់ក្នុងត្រចៀកគាត់ រួចស្តោះទឹកព្រះឱស្ឋ ហើយពាល់អណ្តាតគាត់ កាលទ្រង់បានងើបទតទៅលើមេឃហើយនោះ ទ្រង់ថ្ងូរ រួចមានព្រះបន្ទូលទៅគាត់ថា "អិបផាថា" គឺថា អោយបើកឡើង ស្រាប់តែត្រចៀកក៏បើក សរសៃអណ្តាតបានធូរ នោះគាត់និយាយបានយ៉ាងច្បាស់" (ម៉ាកុស ៧:៣៣-៣៥) ។

## ២. ការណែនាំសម្រាប់ការប្រោសអោយជាតាមរយៈការដាក់ដៃ

ក. ស្វែងរកតំរូវការ

១. លោកអ្នកត្រូវតែស្វែងរកអោយឃើញនូវតំរូវការជាមុនសិន មិនថាតាមរយៈអំណោយទាននៃពាក្យសំដីនៃចំណេះចេះស្មាត់ រឺ អ្នកដែលមកដើម្បីទទួលព័ន្ធកិច្ចនោះទេ ។

២. ជួនកាល មនុស្សមិនបានមកដើម្បីទទួលការប្រោសអោយជាសម្រាប់អ្វីដែលពិតជាក់ស្តែងនោះទេ ។ មនុស្សដែលអង្គុយក្នុងកៅអីកង់ គេប្រហែលជាមកសម្រាប់ការប្រោសអោយជាពីជំងឺទឹកនោមផ្អែម ។ នៅពេលដែលមានឱកាស ចូរសាកសួរ និង ស្វែងរកអោយឃើញថាតើពួកគេកំពុងជឿលើអ្វីក្នុងពេលឥឡូវនេះ ។

៣. ចូរសួរសំនួរដែលធ្វើអោយពួកគេផ្តល់ "ការឆ្លើយតបនៃសេចក្តីជំនឿ" ជំនួសអោយការឆ្លើយតបអវិជ្ជមាន ។ ចូរធ្វើអោយពួកគេនិយាយពីសេចក្តីជំនឿរបស់ពួកគេ ជំនួសអោយការបន្ទិលសង្ស័យរបស់ពួកគេនៅពេលដែលពួកគេប្រាប់លោកអ្នកពីសេចក្តីលំអិតអវិជ្ជមានទាក់ទងនឹងលក្ខណ្ឌរបស់ពួកគេ ។ ចូរធ្វើអោយពួកគេនិយាយដោយសេចក្តីជំនឿពីអ្វីដែលពួកគេសង្ឃឹមចង់បាន ។ ចូរធ្វើអោយពួកគេបង្ហាញពីសេចក្តីជំនឿរបស់ពួកគេក្នុងពេលឥឡូវនេះ ។

៤. ជំនួសអោយការសួរថា "តើអ្នកឈឺអ្វី ?" ចូរសួរថា "តើអ្នកជឿថា ព្រះជាម្ចាស់នឹងធ្វើអ្វីនៅពេលឥឡូវនេះ" ។ ការឆ្លើយតបដែលប្រកបដោយសេចក្តីជំនឿប្រហែលជា : "ខ្ញុំជឿថាព្រះជាម្ចាស់នឹងប្រោសខ្ញុំអោយជាពីជំងឺទឹកនោមផ្អែមរបស់ខ្ញុំនាពេលឥឡូវនេះ !" ។

ខ. ប៉ះផ្នែកណាមួយនៃរាងកាយដើម្បីប្រោសអោយជា

១. អំណាចនៃការប្រោសអោយជាត្រូវបានបញ្ជូនដោយប្រើប្រាស់ច្បាប់នៃការតភ្ជាប់ និង ការបញ្ជូន ។ នោះគឺដូចជាការដែលយើងយកខ្សែភ្លើងពីរមកតផ្ជាប់គ្នា ដើម្បីអោយចរន្តអគ្គិសនីអាចហូរឆ្លងកាត់បានដូច្នេះដែរ ។

២. "នោះទ្រង់ក៏ពាល់ភ្នែកគេ ដោយបន្ទូលថា ចូរអោយបានជាដូចសេចក្តីជំនឿរបស់អ្នកចុះ" (ម៉ាថាយ ៩:២៩) ។

៣. យើងចង់អោយអំណាចនៃការប្រោសអោយជានេះហូរដោយផ្ទាល់ចូលទៅក្នុងផ្នែកណាមួយនៃរាងកាយដែលត្រូវការការប្រោសអោយជានោះ ។ ប្រសិនបើផ្នែកនៃរាងកាយដែលត្រូវការការប្រោសអោយជានោះមានលក្ខណៈផ្ទាល់ខ្លួន ហើយគេមានភេទខុសគ្នាពីយើង យើងគួរតែប្រើប្រាជ្ញា ឬ ដាក់ដៃរបស់យើងលើក្បាលរបស់អ្នកជំងឺ រឺ អោយពួកគេដាក់ដៃរបស់ពួកគេលើផ្នែកនោះ បន្ទាប់មក យើងដាក់ដៃរបស់យើងលើដៃរបស់ពួកគេ ។ វាជាការល្អបំផុតក្នុងការអោយស្ត្រីដាក់ដៃលើស្ត្រី ហើយបុរសដាក់ដៃលើបុរស ។

គ. នឹកស្រម៉ៃ រួចបើកអោយអំណាចហូរ

១. នៅពេលលោកអ្នកដាក់ដៃលើអ្នកជំងឺ ហើយអធិប្បាយព្រះបន្ទូលដោយសេចក្តីជំនឿ នោះចូរនឹកស្រម៉ៃថា ផ្នែកនៃរាងកាយរបស់ពួកគេនោះត្រូវបានប្រោសអោយជា រឺ បានស្អាតដូចដើមវិញ ។ ដោយសារសេចក្តីជំនឿ ចូរបើកអោយអំណាចនៃការប្រោសអោយជានៅក្នុងខ្លួនរបស់លោកអ្នកហូរចូលទៅក្នុងរូបកាយរបស់គេ ។

២. ចូរបើកអោយសេចក្តីជំនឿរបស់លោកអ្នកប្រោសគេអោយជា មិនមែនដើម្បីសម្លាប់ពួកគេដោយអំណាចនោះទេ ។ មនុស្សជាច្រើនបានទទួលការប្រោសអោយជាដោយសារអំណាចរបស់ព្រះជាម្ចាស់ ។ ចំណែកឯអ្នកខ្លះទៀតបានស្លាប់ដោយសារអំណាចនោះ ដោយមិនបានទទួលការប្រោសអោយជាទេ ។

៣. ចូរផ្តោតសេចក្តីជំនឿរបស់លោកអ្នកអោយការនិយាយចំៗទៅកាន់ផ្នែកណាមួយនៃរាងកាយ ។ ជួនកាល ព្រះវិញ្ញាណដឹកនាំយើងអោយប៉ះ និង ធ្វើសកម្មភាពយ៉ាងរហ័ស ពេលខ្លះទៀត

ព្រះវិញ្ញាណដឹកនាំយើងអោយបន្តដាក់ដៃលើអ្នកជំងឺដើម្បីអោយអំណាចហូរក្នុងរយៈពេលមួយ ។

ឃ. ចូរបើកភ្នែករបស់លោកអ្នក ហើយរងចាំមើលការបើកសំម្តែងកើតឡើង

១. នៅក្នុងន័យសាសនា ការបិទភ្នែកគឺជាការសម្តែងអោយឃើញពីការសង្ស័យ និង ការមិនជឿ ។ ព្រះយេស៊ូមានបន្ទូលថា "ចូរចាំយាម ហើយអធិស្ឋានចុះ..." (ម៉ាថាយ ២៦:៤១) ។ ប្រសិនបើលោកម៉ាថាយ លោកម៉ាកុស និង លោកយ៉ូហានបិទភ្នែកនៅពេលព្រះយេស៊ូប្រោសអ្នកជំងឺអោយជានោះ ពួកគេពិតជាមិនអាចពិពណ៌នាពីការអស្ចារ្យនោះបានឡើយ ។

២. នៅពេលខ្លះ យើងត្រូវការប្រោសមនុស្សជាច្រើនអោយជាក្នុងរយៈពេលដ៏ខ្លី ។ ក្នុងពេលនោះ ការចាក់ប្រេងតាំងដ៏អស្ចារ្យនឹងមកដើម្បីប្រោសអ្នកជំងឺអោយជា ។ នៅពេលនោះ យើងត្រូវប្រុងប្រយ័ត្នកុំអោយនរណាម្នាក់បញ្ឈប់យើង ដើម្បីប្រាប់យើងពីសេចក្តីលំអិតដ៏វែងឆ្ងាយរបស់ពួកគេ ។ ការនេះធ្វើអោយព្រះវិញ្ញាណបរិសុទ្ធមិនសប្បាយព្រះទ័យ ។ យើងត្រូវបន្តទៅមុខជាមួយនឹងរលកនៃការចាក់ប្រេងតាំង ហើយដាក់ដៃលើមនុស្សអោយបានច្រើនតាមតែលោកអ្នកអាចធ្វើទៅបាន ។

ង. ការប្រោសហ្វូងមនុស្សអោយជា

១. នៅពេលយើងប្រោសហ្វូងមនុស្សអោយជា ព្រះជាម្ចាស់នឹងដឹកនាំយើងអោយហៅការប្រោសអោយជាតាមរយៈពាក្យសំដីនៃចំណេះចេះស្មាត់ ហើយបន្ទាប់មក ប្រកាសដោយក្លាហានពីអ្វីដែលព្រះជាម្ចាស់នឹងធ្វើ ។ ជួនកាល ព្រះជាម្ចាស់នឹងដឹកនាំយើងអោយបញ្ជាអោយវិញ្ញាណនៃជំងឺចេញដោយនូវព្រះនាមរបស់ព្រះយេស៊ូ ។ ជួនកាល មនុស្សជាច្រើននឹងធ្លាក់ចូលទៅក្នុងរលកក្រោមអំណាចរបស់ព្រះជាម្ចាស់ ។ គន្លឹះសំខាន់គឺការស្តាប់តាមព្រះវិញ្ញាណបរិសុទ្ធ ហើយបន្តទៅមុខជាមួយនឹងការចាក់ប្រេងតាំងរបស់ព្រះអង្គ ។

២. ទោះជាយ៉ាងណាក៏ដោយ យើងត្រូវចាំថា ការផ្សាយដំណឹងល្អដោយការអស្ចារ្យចំពោះមនុស្សជាច្រើននឹងមិនអាចសំរេចកិច្ចការដោយខ្លួនឯងបានឡើយ ។ គំរូនៃការផ្សាយដំណឹងល្អនៅក្នុងសញ្ញាថ្មីគឺជាការផ្សាយដំណឹងល្អដោយការអស្ចារ្យចំពោះមនុស្សម្នាក់ៗ ដោយទីសំគាល់ ហើយការអស្ចារ្យនឹងស្ថិតនៅជាប់ជាមួយនឹងអ្នកជឿគ្រប់គ្នានៅពេលពួកគេធ្វើបន្ទាល់នៅគ្រប់ទីកន្លែងដែលពួកគេទៅ ។

ច. ការប្រោសអោយជាដោយសកម្មភាពដ៏ក្លាហាននៃសេចក្តីជំនឿ

យើងបានរៀនរួចមកហើយថា នៅពេលមានសេចក្តីជំនឿ នឹងតែងតែមានសកម្មភាព ។ លោកយ៉ាកុបបានមានប្រសាសន៍ថា "ជំនឿដែលគ្មានទង្វើ (ទង្វើឆ្លើយតបនៃជំនឿ) គឺជាជំនឿដែលស្លាប់ (មិនរស់រវើក)" ។

១. បុរសខ្វិនជើងនៅឯស្រះទឹកបេថែសដា : ព្រះយេស៊ូមានបន្ទូលទៅកាន់បុរសខ្វិនជើងថា "ចូរក្រោកឡើង យកគ្រែអ្នកដើរទៅ" (យ៉ូហាន ៥:៨) ។

២. បុរសពិការភ្នែក : ព្រះយេស៊ូមានបន្ទូលទៅកាន់បុរសពិការភ្នែក បន្ទាប់ពីបានលៀបភ្នែករបស់គាត់ជាមួយនឹងភក់ដែលធ្វើពីទឹកព្រះឱស្ឋរបស់ព្រះអង្គថា : "ចូរទៅលាងក្នុងស្រះស៊ីឡោមទៅ" (យ៉ូហាន ៩:៧) ។

៣. បុរសស្វិតដៃ : ព្រះយេស៊ូបានមានបន្ទូលទៅកាន់បុរសស្វិតដៃថា "ចូរលាតដៃមើល៍ ! បុរសនោះលាតដៃ ហើយដៃគាត់ក៏បានជាដូចដៃម្ខាងទៀត" (ម៉ាថាយ ១២:១៣) ។

ក. ព្រះយេស៊ូកំពុងមានបន្ទូលថា "ចូរសម្តែងសេចក្តីជំនឿរបស់អ្នក ! ចូរធ្វើអ្វីដែលអ្នកមិនអាចធ្វើបាន ! ចូរធ្វើសកម្មភាពនោះដោយក្លាហាន ! ជាធម្មតា នៅពេលយើងប្រោសអ្នកណាម្នាក់អោយជា យើងនិយាយដោយក្លាហានថា "ចូរសាកល្បងរូបកាយរបស់អ្នកមើល ! ចូរធ្វើអ្វីដែលអ្នកមិនអាចធ្វើកាលពីមុន ! ចូរកំរើកដៃរបស់អ្នក ! ចូរបត់ចុះឡើង !" ។

ខ. បន្ទាប់មកទៀត យើងសួរដោយក្លាហានថា "តើមានអ្វីកើតឡើងចំពោះការឈឺចាប់របស់អ្នកដែលឬទេ ?" ។ ប្រសិនបើអាការៈរោគមិនទាន់បាត់នៅឡើយ យើងនិយាយដោយក្លាហានទៀតថា "ចូរសាកល្បងម្តងទៀត ! ចូរបត់ចុះឡើងម្តងទៀតទៅ !" ។

## ៣. ការអស្ចារ្យ ឬការប្រោសអោយជា

ជាញឹកញាប់ នៅពេលយើងប្រោសអ្នកជំងឺអោយជា យើងគឺកំពុងប្រឆាំងនឹងការមានមន្ទិលសង្ស័យ និង ភាពមិនមានសេចក្តីជឿដូចដែលព្រះយេស៊ូបានធ្វើនៅភូមិណាសារ៉ែតដែលព្រះអង្គមិនអាចធ្វើការអស្ចារ្យអ្វីបានឡើយ ។ ដំបូង យើងត្រូវដោះស្រាយជាមួយនឹងការមានបន្ទិលសង្ស័យ និង ភាពមិនមានសេចក្តីជឿជាមុនសិនដើម្បីអោយយើងអាចធ្វើការនៅក្នុងបរិយាកាសនៃសេចក្តីជំនឿបាន ។ មានម្តងនោះ ព្រះយេស៊ូបានដេញពួកអ្នកចំអក (អ្នកដែលមានបន្ទិលសង្ស័យ) ចេញពីបន្ទប់ ។

ជាញឹកញាប់ ដំបូង យើងត្រូវចំណាយពេលកសាងសេចក្តីជំនឿ ដោយបង្រៀនពីអ្វីដែលព្រះបន្ទូលបានចែងទាក់ទងនឹងការប្រោសអោយជា បន្ទាប់មក ប្រាប់ពួកគេពីរឿងរ៉ាវស្តីអំពីអ្នកដែលត្រូវបានប្រោសអោយជា ។ យើងអាចជៀសវាងបរាជ័យបាន ប្រសិនបើយើងចំណាយពេលស្តាប់ពាក្យសំដីនៃចំណេះចេះស្ទាត់ និង ប្រាជ្ញាមុនពេលធ្វើការប្រោសអោយជា ។

ក. ឈរក្នុងសេចក្តីជំនឿ

១. ជួនកាល យើងមិនឃើញមានការផ្លាស់ប្តូរភ្លាមៗនៅក្នុងអាករៈរោគទេ ។ ការធ្វើកុំអោយអ្នកជំងឺបាក់ទឹកចិត្ត និង អស់សេចក្តីជំនឿលើការប្រោសអោយជាគឺជាការសំខាន់បំផុតនៅក្នុងពេលនេះ ។

២. អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានចែងថា "ដ្បិតបើយើងរាល់គ្នាកាន់ខ្ជាប់តាមសេចក្តីជំនឿដើមដរាបដល់ចុងបំផុតមែន" (ហេព្រើរ ៣:១៤) ។

៣. ចូរពន្យល់ប្រាប់ពួកគេពីភាពខុសគ្នារវាងការអស្ចារ្យដែលកើតឡើងភ្លាមៗ និង ការប្រោសអោយជាដែលអាការៈរោគត្រូវបានធ្វើអោយធូរស្បើយក្នុងរយៈពេលមួយ ។ អំណាចរបស់ព្រះ

ជាម្ចាស់ដែលបានចូលទៅក្នុងខ្លួនរបស់មនុស្សនោះ នៅពេលយើងដាក់ដៃ នឹងបន្តធ្វើការរហូតដរាបណាយើងនៅមានសេចក្តីជំនឿ ។

៤. យើងឃើញការប្រោសអោយជាដ៏គួរអោយកត់សំគាល់ជាច្រើនកើតឡើង ក្នុងកំឡុងពេលដែលមនុស្សបន្តមានសេចក្តីជំនឿ : ជឿ និយាយ និង ប្រព្រឹត្តដោយផ្អែកលើសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

ខ. ការប្រកាសរបស់ខ្ញុំ :

"ព្រះបន្ទូលរបស់ព្រះយេស៊ូគឺសម្រាប់អស់អ្នកដែលមានសេចក្តីជំនឿ ។ ពួកគេនឹងដាក់ដៃលើអ្នកជំងឺ ហើយអ្នកជំងឺនឹងបានជា ។ ខ្ញុំជាអ្នកជឿ មិនមែនជាអ្នកមានបន្ទិលសង្ស័យទេ ។ ព្រះយេស៊ូមានបន្ទូលយ៉ាងដូច្នេះ ។ ខ្ញុំជឿថា អ្វីដែលព្រះយេស៊ូមានបន្ទូលគឺជាសេចក្តីពិត ។ ខ្ញុំគឺជាស្មរបន្ទាល់ដ៏ក្លាហានរបស់ព្រះយេស៊ូ ! នៅពេលខ្ញុំធ្វើតាមការបញ្ជារបស់ព្រះយេស៊ូ ដែលបញ្ជាអោយខ្ញុំប្រកាស និង ចែកចាយដំណឹងល្អ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នឹងស្ថិតនៅជាប់ជាមួយនឹងខ្ញុំ ដើម្បីបញ្ជាក់ព្រះបន្ទូលរបស់ព្រះអង្គតាមរយៈទីសំគាល់នៃការប្រោសអោយជា ហើយការអស្ចារ្យជាច្រើនទៀតនឹងស្ថិតនៅជាប់ជាមួយខ្ញុំគ្រប់ទីកន្លែងដែលខ្ញុំទៅ ។ ខ្ញុំគឺជាការអស្ចារ្យ ជាស្មរបន្ទាល់ដែលធ្វើការសម្រាប់ព្រះយេស៊ូគ្រិស្ត !

## ពិភាក្សាជាក្រុម

១. ត្រង់ចំណុចនេះ សូមបំបែកគ្នាជាក្រុមតូចៗ រួចដាក់ដៃលើគ្នាទៅវិញទៅមកដើម្បីចែកចាយព័ន្ធកិច្ចរបស់ព្រះគ្រិស្ត ដែលពេញទៅដោយអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

២. សូមសរសើរតម្កើងព្រះអង្គសម្រាប់ការបំពេញលោកអ្នក និង ប្រទានអោយលោកអ្នកនូវអំណោយទានដែលប្រសើរបំផុតសម្រាប់ព័ន្ធកិច្ចដែលព្រះអង្គបានត្រាស់ហៅលោកអ្នកអោយធ្វើ ។

## ការសិក្សាដោយខ្លួនឯង

១. ចូរសិក្សា ហេព្រើរ ៦:១-២ ។ តើអត្ថបទគម្ពីរនេះថ្កោលទោសគោលលទ្ធិជាមូលដ្ឋាននៃការដាក់ដៃដែរឬទេ?

២. តើអត្ថបទគម្ពីរនេះបង្រៀនយើងអំពីអ្វី ?

៣. ចូរផ្តល់ឧទាហរណ៍ដែលដកស្រង់ចេញពីព្រះគម្ពីរ ឧទាហរណ៍ផ្សេងក្រៅពីឧទាហរណ៍ដែលមាននៅក្នុងមេរៀននេះ ដែលបញ្ជាក់ថា ការដាក់ដៃកើតមានមុនការប្រោសអោយជា ពិធីជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ រឺ ការចាក់ប្រេងតាំងសម្រាប់ការបំរើ ។